**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Science Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌ របស់អគ្គការអយ្យការអមសាលាដំបូង

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

តាក់តែងឡើងដោយ

និស្សិតឈ្មោះ លោក **ជា សុខរាជ្យ**

កញ្ញា **តេង ចាន្ទី**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ **ជា សុខរាជ្យ** និងនាងខ្ញុំឈ្មោះ **តេង ចាន្នី** ដែលជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

**យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណ**

**និងសំដែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះ**

**លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សារូបកូនឱ្យធំដឹងក្តី យ៉ាងយកចិត្តទុកដាក់បំផុត ដែលធ្វើឱ្យយើងខ្ញុំបានរៀនសូត្របន្តការសិក្សារហូតមកដល់សព្វថ្ងៃនេះ ចំពោះមហាទិគុណរបស់លោកទាំងទ្វេ រូបកូនពុំអាចរកអ្វីយកមកប្រៀបស្មើគុណដ៏ធំធេងរបស់លោកទាំងទ្វេបានឡើយ ហើយកូនក៏មិនអាចបំភ្លេចនូវគុណរបស់លោកទាំងពីរបានឡើយ។ លោកទាំងពីរបានខិតខំជួយឧបត្ថម្ភក្នុងការសិក្សាតាំងពីឆ្នាំទីមួយ រហូតមកដល់ឆ្នាំទីបួន ផ្នែកនីតិសាស្រ្តនេះ ហើយព្រមទាំងបានទូន្មានប្រៀនប្រដៅ និងផ្តល់នូវ សម្ភារៈ ក៏ដូចជាផ្តល់នូវកម្លាំងកាយចិត្ត គ្រប់ពេលវេលា ក្នុងការទំនុកបម្រុងដល់ការសិក្សារបស់យើងខ្ញុំ។

រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងការអភិវឌ្ឍវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំក៏សូមថ្លែងអំណរអរគុណចំពោះ ឯកឧត្តមសាកលវិទ្យាធិការ **លុយ ចណ្ណា** និងសាកលវិទ្យាធិការរង លោកគ្រូ និងអ្នកគ្រូ ដែលលោកបានបង្ហាត់បង្រៀនយើងខ្ញុំ ដោយពុំគិតចង់បានអ្វីជាការតបស្នងក្រៅពីការខិតខំបំពេញ ភារកិច្ចរបស់គាត់អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ព្រមទាំងមន្រ្តី និងបុគ្គលិកទាំងអស់ដែលបម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

ជាពិសេស លោកសាស្រ្តាចារ្យ **ជួន ម៉ុនធី** ជាសាស្រ្តាចារ្យ ផ្នែកនីតិសាស្រ្តដែលទទួលបន្ទុកដឹកនាំក្នុងការសរសេរសារណាដែលលោកបានខិតខំទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការផ្តល់យោបល់ ចំណេះដឹង និងបទពិសោធន៍នានាដែលលោកមានមកឱ្យយើងខ្ញុំទាំងពីរនាក់ ដោយនេះជាកត្តាដ៏សំខាន់ ដែលយើងខ្ញុំទាំងពីរនាក់អាចឈានទៅដល់ការសរសេរសារណាប្រកបដោយភាពជោគជ័យ។

ជាចុងបញ្ចប់ យើងខ្ញុំសូមគោរពនូវការដឹងគុណ និងសូមជូនពរដល់លោកឪពុក អ្នកម្តាយ លោកគ្រូ និងអ្នកគ្រូទាំងអស់ឱ្យប្រកបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀង ឃ្លាតឡើយ។

# **អារម្ភកថា**

ក្រោយពីបានឆ្លងកាត់ការសិក្សា និងក្រេបជញ្ជក់ចំណេះដឹងរយៈពេល ៤ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំក៏សម្រេចចិត្ត ជ្រើសរើសយកប្រធានបទស្ដីពី "**ចំណាត់ការលើរឿងក្ដីព្រហ្មទណ្ឌរបស់អង្គការអយ្យការអមសាលាដំបូង**" ដែលមានសាស្ត្រាចារ្យណែនាំលោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ។ ការជ្រើសរើសយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវ ពុំមែនជារឿងចៃដន្យនោះទេ ប៉ុន្តែជាការពិចារណាយ៉ាងហ្មត់ចត់តាមរយៈការសិក្សាលើអត្ថបទច្បាប់ដែលពាក់ព័ន្ធ គឺដោយសារតែយើងខ្ញុំយល់ឃើញថា**អង្គការអយ្យការ** គឺជាស្ថាប័នមួយ ដែលនៅអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ ហើយមានតួនាទីការពារថែរក្សាសណ្ដាប់ធ្នាប់សាធារណៈនិងមានតួនាទីធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងការសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរនិងយុត្តាធិការជំនុំជម្រះ។

ខ្ញុំបាទ/នាងខ្ញុំ ពិតជាមានសេចក្ដីរីករាយយ៉ាងខ្លាំង ដែលបានសរសេរសារណាស្ដីអំពី **ចំណាត់ការលើរឿងក្ដីព្រហ្មទណ្ឌរបស់អង្គការអយ្យការអមសាលាដំបូង** ដោយមានសាស្ត្រាចារ្យណែនាំលោក **ជួន ម៉ុនធី** ជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយលើកទឹកចិត្ត និងបង្ហាត់បង្រៀនការពន្យល់ណែនាំយ៉ាងយកចិត្តទុកដាក់ ក៏ដូចជាផ្ដល់នូវឯកសារដល់យើងខ្ញុំទាំងពីរនាក់ ដើម្បីអាចសរសេរសារណានេះទៅដោយរលូនបានល្អ ។ យើងខ្ញុំសង្ឃឹមថាសារណាមួយនេះ នឹងក្លាយជាឯកសារស្រាវជ្រាវដល់សិស្សនិស្សិតជំនាន់ក្រោយៗ ដើម្បីសិក្សាស្រាវជ្រាវពីចំណាត់ការលើរឿងក្ដីព្រហ្មទណ្ឌរបស់អង្គការអយ្យការអមសាលាដំបូង។

បើទោះបីជាមានការខិតខំសិក្សាស្រាវជ្រាវ និងការត្រួតពិនិត្យយ៉ាងហ្មត់ចត់យ៉ាងណាក៏ដោយ ក៏ការសរសេរសារណានេះ អាចនឹងមិនទាន់មានសេចក្ដីពេញលេញគ្រប់ជ្រុងជ្រោយនៅឡើយទេ ដូចនេះយើងខ្ញុំទាំងពីរនាក់ក៏សូមអភ័យទោសទុកជាមុនប្រសិនបើ មាននូវកំហុសខុសឆ្គង ក៏ដូចជាភាពខ្វះចន្លោះដោយប្រការណាមួយដែលកើតមានឡើងនៅក្នុងសារណាមួយនេះ។ ហើយយើងខ្ញុំទាំងពីរនាក់ រង់ចាំទទួលការរិះគន់ដើម្បីស្ថាបនារាល់ចំណុចទាំងឡាយពីសំណាក់សាស្ត្រាចារ្យក៏ដូចជាមិត្តសិស្សនិស្សិតអ្នកអាន ដើម្បីកែលម្អក្នុងន័យធ្វើឱ្យសារណាមួយនេះកាន់តែមានលក្ខណៈល្អប្រសើរបន្ថែមទៀត។

ជាកិច្ចបញ្ចប់ មុននឹងធ្វើការបកស្រាយលើប្រធានបទខាងលើនេះ យើងខ្ញុំទាំងពីរនាក់ សូមគោរពជូនពរដល់លោកសាស្ត្រាចារ្យ ក៏ដូចជាមិត្តសិស្សនិស្សិតអ្នកអាន គ្រប់រូបឱ្យជួបប្រទះតែសំណាងល្អ និងទទួលបានភាពជោគជ័យគ្រប់ភារកិច្ចទាំងអស់ផងដែរ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................ ០១

## ជំពូកទី១

## អង្គការអយ្យការ

**ផ្នែកទី១៖ ការរៀបចំនៃអង្គការអយ្យការ** ........................................ ១១

១. រចនាសម្ព័ន្ធនៃអង្គការអយ្យការ ........................................ ១១

១.១. អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ........................................ ១១

១.២. អង្គការមហាអយ្យការអមតុលាការជាន់ខ្ពស់ ........................................ ១២

**ផ្នែកទី២៖ សមត្ថកិច្ច តួនាទី ភារកិច្ច និងសិទ្ធិអំណាចនៃអង្គការអយ្យការ** ........................................ ១៥

១ . សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា ........................................ ១៥

២. តួនាទីរបស់ព្រះរាជអាជ្ញា ........................................ ១៥

៣. ភារកិច្ចរបស់ព្រះរាជអាជ្ញា ........................................ ១៦

៤. សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា ........................................ ១៦

**ផ្នែកទី៣៖ គោលការណ៍នៃការរៀបចំអង្គការអយ្យការ** ........................................ ១៧

១. គោលការណ៍ ឋានានុក្រម ឬ គោលការណ៍ឯកភាព ........................................ ១៧

២. គោលការណ៍អវិភាគឬគោលការណ៍នៃភាពមិនអាចចែកដាច់ពីគ្នា ........................................ ១៨

៣. គោលការណ៍ឯករាជ្យរវាងអង្គការអយ្យការ និង តុលាការ ........................................ ១៨

## ជំពូកទី២

## លក្ខខណ្ឌនៃការចោទប្រកាន់

**ផ្នែកទី១៖ ការពិនិត្យទៅលើកាលានុវត្តភាពនៃការចោទប្រកាន់** ........................................ ២០

១. សេរីភាពក្នុងការសម្រេចរបស់ព្រះរាជអាជ្ញា ........................................ ២១

២. សេចក្តីសម្រេចរបស់អយ្យការទាក់ទងនឹងការចោទប្រកាន់ ........................................ ២១

**ផ្នែកទី២៖ ការតម្កល់រឿងទុកឥតចាត់ការរបស់អង្គការអយ្យការ** ........................................ ២១

១. សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ ........................................ ២១

១.១. អត្ថន័យនៃការតម្កល់រឿងទុកឥតចាត់ការ ....................................................២១
១.២. អាជ្ញាធរទទួលបន្ទុកក្នុងការតម្កល់រឿងទុកឥតចាត់ការ ........................................២២
២. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ ..........................................................២២
២.១. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលមិនមែនជាបទល្មើស ........................ ២៣
២.២. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើស...................................២៤
៣. នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ..........................................២៩
៣.១. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ ..........................................................២៩
៣.២. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ........................................................៣០
៤. យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ.....................................................៣០
៤.១. ការសើរើកែប្រែសេចក្តីសម្រេចរបស់តំណាងអយ្យការ............................................៣១
៤.២. ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ..............................................៣១
៤.៣. ការធ្វើអធិបញ្ញាតាមឋានានុក្រមនៃអង្គការអយ្យការ...............................................៣១
៤.៤. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី .............................................................. ៣២
៥. ផលវិបាកនៃនីតិវិធីតម្កល់រឿងទុកឥតចាត់ការចំពោះសង្គមជាតិ ............................ ៣២
៥.១. គុណសម្បត្តិនៃការតម្កល់រឿងទុកឥតចាត់ការចំពោះសង្គម ................................... ៣២
៥.២. គុណវិបត្តិនៃការតម្កល់រឿងទុកឥតចាត់ការចំពោះសង្គម....................................... ៣៣

## ជំពូកទី៣

## ការចោទប្រកាន់របស់តំណាងអយ្យការ

**ផ្នែកទី១៖ សញ្ញាណទូទៅនៃការចោទប្រកាន់** ......................................................៣៥
១. អត្ថន័យនៃការចោទប្រកាន់...................................................................................៣៥
២. អាជ្ញាធរទទួលបន្ទុកក្នុងការចោទប្រកាន់...................................................................៣៦
៣. ប្រភេទនៃការចោទប្រកាន់ ................................................................................... ៣៧
**ផ្នែកទី២៖ ការបញ្ជូនរឿងក្តីទៅចៅក្រមស៊ើបសួរ** ................................................... ៣៧
១. ការបើកការស៊ើបសួរ .......................................................................................... ៣៧
២. នីតិវិធីនៃការបើកការស៊ើបសួរ...............................................................................៣៨
២.១. លក្ខខណ្ឌនៃការបើកការស៊ើបសួរក្នុងបទល្មើសព្រហ្មទណ្ឌ ...................................... ៤០

២.២. ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ..................................................... ៤១

២.៣. ការចូលរួមរបស់អង្គការអយ្យការក្នុងការស៊ើបសួរ ................................................. ៤១

២.៤. ដីកាសន្និដ្ឋានស្ថាពរបញ្ចប់ការស៊ើបសួររបស់អង្គការអយ្យការ.................................៤២

**ផ្នែកទី៣៖ ការបញ្ជូនរឿងក្តីទៅចៅក្រមជំនុំជម្រះ** .......................................................... ៤៤

១. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់................................................................................... ៤៤

១.១. លក្ខខណ្ឌនៃការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់................................................ ៤៥

១.២. នីតិវិធីនៃការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ...................................................៤៧

២. នីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ........................................................................ ៤៩

២.១. លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម ............................................................................ ៤៩

២.២. នីតិវិធីនៃការបង្ហាញខ្លួនភ្លាម.............................................................................. ៥០

**សេចក្តីសន្និដ្ឋាន**..........................................................................................................៥៣

**អនុសាសន៍**.............................................................................................................. ៥៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ដូចដែលយើងបានដឹងរួចមកហើយ ដើម្បីគ្រប់គ្រងប្រទេសមួយឱ្យមានសណ្តាប់ធ្នាប់និងសុខសន្តិភាពជាមួយនិងការអភិវឌ្ឍន៍ផ្សេងៗនៅក្នុងសង្គមជាតិ ពិតណាស់ត្រូវតែមានច្បាប់ដើម្បីធ្វើការគ្រប់គ្រងប្រទេសជាតិនោះ ។ ច្បាប់គឺជា បណ្តុំនៃវិធានទាំងឡាយដែលរដ្ឋបានបង្កើតឡើង ដើម្បីគ្រប់គ្រង និងថែរក្សាសណ្តាប់ធ្នាប់ ឱ្យមានរបៀបរៀបរយនៅក្នុងសង្គមជាតិ។ ជាក់ស្តែងចាប់តាំងពី ព្រះរាជាណាចក្រកម្ពុជា បានទទួលឯករាជ្យយ៉ាងពេញលេញពីបារាំងមកព្រះរាជាណាចក្រកម្ពុជា ត្រូវបានទទួលស្គាល់ថាជាប្រទេសមួយដែលមានឯករាជ្យភាព និងបូរណភាពទឹកដីយ៉ាងពិតប្រាកដចាប់តាំងពីពេលនោះមក។ ដោយសារប្រទេសកម្ពុជា បានទទួលរងឥទ្ធិពលនៃការដាក់អាណានិគមពីប្រទេសបារាំងអស់រយៈពេលជាច្រើនទសវត្សរ៍ ដែលជាហេតុធ្វើឱ្យប្រទេស កម្ពុជាត្រូវកសាងនូវប្រព័ន្ធច្បាប់តាមបែបផែននៃប្រទេសបារាំង ដែលជាប្រទេសប្រើប្រាស់នូវប្រព័ន្ធច្បាប់ ស៊ីវិល ឡ (Civil Law) ។ ហេតុនេះហើយទើបប្រទេសកម្ពុជាបានជ្រើសរើស និងកសាងប្រព័ន្ធច្បាប់របស់ខ្លួន និងបន្សល់ទុកមកដល់បច្ចុប្បន្ននេះ គឺប្រព័ន្ធច្បាប់ ស៊ីវិល ឡ (Civil Law) ។

ពិតណាស់ក្រមនីតិវិធីព្រហ្មទណ្ឌអន្តរកាលឆ្នាំ ១៩៩៣ ជាក្រមមួយពុំបានចែងឱ្យបានលម្អិតអំពីនីតិវិធីក្នុងកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌនោះទេ ដែលជាចន្លោះប្រហោងផ្នែកច្បាប់តម្រូវនូវភាពអវិជ្ជមានទាំងនោះ ជាក់ស្តែងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានចូលជាធរមាននៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ មកច្បាប់និងបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលរួមមានក្រមព្រហ្មទណ្ឌអន្តរកាល និងក្រមនីតិវិធីព្រហ្មទណ្ឌអន្តរកាល ត្រូវបាននិរាករណ៍ដោយច្បាប់ថ្មីនេះ។ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ត្រូវបានចែកចេញជា **១១ គន្ថី** និងមាន **៦១២ មាត្រា**។ ក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាចំណាត់ការក្នុងការអនុវត្តទៅលើសំណុំរឿងក្តីទាំងឡាយណាដែលជាបទល្មើសព្រហ្មទណ្ឌ ឬអាចនិយាយបានថាក្រមនីតិវិធីព្រហ្មទណ្ឌគឺជាសំណុំវិធានទាំងឡាយដែលមានការបែងចែកពី តួនាទី ភារកិច្ចរបស់បុគ្គលិក ព្រមទាំងសកម្មភាពរបស់តុលាការព្រហ្មទណ្ឌ ចាប់តាំងពីនីតិវិធីនៃដំណាក់កាលដំបូង រហូតដល់ដំណាក់កាលនៃការផ្តន្ទាទោសតាមផ្លូវច្បាប់ដែលនេះជាផ្នែកមួយនៃតួនាទី និងភារកិច្ចដ៏សំខាន់របស់អង្គការអយ្យការដែលជាអ្នកចាប់ផ្តើមធ្វើការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌក្នុងគន្ថីទី **២** អំពី **អង្គការអយ្យការ** គឺជាស្ថាប័នឯករាជ្យដែលដឹកនាំដោយអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ជាសេនាធិការនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ជួយសម្របសម្រួល និងរក្សាសណ្តាប់ធ្នាប់សាធារណៈផងដែរ។ ចំពោះការចោទប្រកាន់ គឺជាតួនាទីចាំបាច់របស់ស្ថាប័នអយ្យការ។ ដោយអនុលោមតាម មាត្រា ១៣១ ថ្មីនៃរដ្ឋធម្មនុញ្ញ បានកំណត់ថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ដូចនេះមានតែអង្គការអយ្យការតែ

ប៉ុណ្ណោះ ដែលអាចធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌតាមរយៈការធ្វើបណ្តឹងអាជ្ញា។ អយ្យការត្រូវធ្វើការស៊ើបអង្កេតនិងចូលរួមក្នុងកិច្ចការស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងឱ្យបានគ្រប់គ្រាន់ក្នុងគោលដៅជានាដល់ការចោទប្រកាន់នៅពេលជំនុំជម្រះ។ ព្រះរាជអាជ្ញា គឺជាតួអង្គយ៉ាងសំខាន់ ដែលត្រូវបំពេញភារកិច្ចយ៉ាងសកម្មក្នុងកិច្ចដំណើរការនៃនីតិវិធីព្រហ្មទណ្ឌដូចជា៖

- ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ
- ការពិនិត្យលើនីត្យានុកូលភាពនៃការស៊ើបសួរ
- ការអនុវត្តសាលក្រម និងការបំពេញតួនាទីផ្សេងៗទៀត ក្នុងនាមជាអ្នកតំណាងការពារផលប្រយោជន៍សាធារណៈរបស់សង្គមជាតិ។

ចំពោះសារណាមួយនេះផងដែរ យើងខ្ញុំទាំងពីរ នឹងធ្វើការបង្ហាញថា " តើស្ថាប័នអយ្យការមានចំណាត់ការបែបណាខ្លះ នៅក្នុងរឿងក្តីព្រហ្មទណ្ឌរបស់អយ្យការអមសាលាដំបូង ពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលនៃការអនុវត្តទោសព្រហ្មទណ្ឌ "។

**ក).លំនាំបញ្ហានៃការស្រាវជ្រាវ**

អយ្យការអមសាលាដំបូង មានចំណាត់ការលើរឿងក្តីក្នុងដំណើរការនៃនីតិវិធីព្រហ្មទណ្ឌ ពោលគឺព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលតំណាងឱ្យអយ្យការអមសាលាដំបូង ជាតួអង្គយ៉ាងសកម្មនៅក្នុងដំណាក់កាលនេះ។ រាល់ការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ គឺជាតួនាទីរបស់តំណាងអយ្យការតែមួយគត់។

សារណាមួយនេះក្រុមយើងខ្ញុំបានខិតខំស្រាវជ្រាវ តាក់តែងឡើងដើម្បីបង្ហាញឱ្យមិត្តអ្នកអានទាំងអស់ដែលមានបំណងចង់បាននូវចំណេះដឹងទាក់ទងនឹងផ្នែកអយ្យការអមសាលាដំបូងនេះ ក្រុមយើងខ្ញុំនឹងធ្វើការបង្ហាញ អំពីសិទ្ធិអំណាច តួនាទី ភារកិច្ច ក៏ដូចជាចំណុចសំខាន់ៗជាច្រើនទៀតដែលជាចំណាត់ការរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង អមសាលាដំបូង។

ពិតណាស់សារណាមួយនេះក៏នឹងផ្តល់ជូនដល់មិត្តនិស្សិតអ្នកអាន អំពីលក្ខខណ្ឌនៃការចោទប្រកាន់ក៏ដូចជា ការពិនិត្យទៅលើកាលានុវត្តភាពនៃការចោទប្រកាន់ របស់អង្គការអយ្យការអមសាលាដំបូងផងដែរ។ ក្នុងនោះព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង មានសិទ្ធិសម្រេចក្នុងការតម្កល់រឿងទុកឥតចាត់ការ ឬក៏សម្រេចក្នុងការចោទប្រកាន់។ ចំណុចសំខាន់ៗទាំងនេះ នឹងបង្ហាញយ៉ាងលម្អិតដល់មិត្តនិស្សិតអ្នកអានឱ្យយល់កាន់តែច្បាស់នៅក្នុងសារណាមួយនេះ។

### ខ). ចំណោទបញ្ហានៃការដោះស្រាយ

ដូចដែលបានលើកឡើងខាងលើរួចមកហើយ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺតំណាងឱ្យអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដើរតួនាទីយ៉ាងសំខាន់ដែលមិនអាចខ្វះបាន ក្នុងនីតិវិធីនៃការធ្វើបណ្តឹងអាជ្ញា ឬហៅម្យ៉ាងទៀតថាបណ្តឹងព្រហ្មទណ្ឌ។

ដើម្បីឱ្យកាន់តែច្បាស់នូវចំណាត់ការរបស់អង្គការអយ្យការអមសាលាដំបូងលើរឿងក្តីព្រហ្មទណ្ឌ យើងគប្បីដឹងអំពីចំណុចសំខាន់ៗ ដូចជា ៖

- តើអង្គការអយ្យការជាអ្វី?
- តើព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលតំណាងឱ្យអង្គការអយ្យការអមសាលាដំបូងមានសិទ្ធិអំណាច តួនាទី ភារកិច្ច អ្វីខ្លះ?
- តើលក្ខខណ្ឌនៃការចោទប្រកាន់របស់អយ្យការអមសាលាដំបូងមានអ្វីខ្លះ?
- តើមានមូលហេតុអ្វីខ្លះ បានជាព្រះរាជអាជ្ញាសម្រេចមិនធ្វើការចោទប្រកាន់ ឬហៅម្យ៉ាងទៀតថាការតម្កល់រឿងទុកឥតចាត់ការ?
- ប្រសិនបើព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ តើព្រះរាជអាជ្ញាត្រូវអនុវត្តតាមនីតិវិធីអ្វីខ្លះ?

### គ). គោលបំណងនៃការស្រាវជ្រាវ

សម្រាប់ការខិតខំស្រាវជ្រាវតាក់តែងឡើងនូវសារណាមួយនេះ ក្រុមយើងខ្ញុំប្រាកដណាស់ថា ដើម្បីពង្រីកនូវចំណេះដឹង និងផ្សារភ្ជាប់ជាមួយការអនុវត្តនៃនីតិវិធីឱ្យកាន់តែច្បាស់ និងដើម្បីទទួលបាននូវបទពិសោធន៍ថ្មីៗ ពីការតាក់តែងសារណាមួយនេះឡើងមក។ ម្យ៉ាងវិញទៀតក៏មានគោលបំណងចង់ចែករំលែកនូវចំណេះដឹងទាក់ទងនឹងចំណាត់ការរបស់អយ្យការអមសាលាដំបូងលើរឿងក្តីព្រហ្មទណ្ឌ ដើម្បីបង្ហាញនូវដំណើរការនីតិវិធីនៃការចោទប្រកាន់របស់តំណាងអយ្យការ ដល់បងប្អូននិស្សិតជំនាន់ក្រោយៗ ក៏ដូចជាមិត្តអ្នកអាននូវចំណុចសំខាន់ៗមួយចំនួន ។

### ឃ). ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រាកដណាស់ប្រធានបទនៃការស្រាវជ្រាវនីមួយៗ ត្រូវតែមានវិសាលភាពគ្របដណ្តប់ទៅលើផ្នែកណាមួយ ជាក់ស្តែងប្រធានបទនៃការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ គ្របដណ្តប់ទៅលើអយ្យការអមសាលាដំបូងទាំងឡាយណាដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការស្រាវជ្រាវទាំងមូលនេះដែរ មិនបានផ្តោតទៅលើស្ថាប័នអយ្យការពិសេសណាមួយនោះទេ។ ការសិក្សាស្រាវជ្រាវមួយនេះគឺ ផ្តោតទៅលើតែចំណាត់ការរបស់អយ្យការអមសាលាដំបូង លើរឿងក្តីព្រហ្មទណ្ឌតែប៉ុណ្ណោះ។ ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ក៏បាន

រៀបរាប់ដោយសង្ខេបពីប្រវត្តិនៃអង្គការអយ្យការនៅព្រះរាជាណាចក្រកម្ពុជា ពីឆ្នាំ ១៩៣៧ ដល់ ឆ្នាំ ១៩៩៣ ផងដែរ និងធ្វើការសិក្សាផ្អែកទៅលើច្បាប់ដែលមានចែងជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន។

**ង). សារៈសំខាន់នៃការស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ មានសារៈសំខាន់ចំពោះរូបខ្ញុំផ្ទាល់ក៏ដូចជា បងប្អូនដែលជានិស្សិតជំនាន់ក្រោយៗ ដូចជា៖

- សារៈសំខាន់សម្រាប់រូបខ្ញុំផ្ទាល់
- ជួយពង្រឹងនូវចំណេះដឹងរបស់ខ្ញុំឱ្យកាន់តែយល់ដឹងច្បាស់អំពីនីតិវិធីរបស់អង្គការអយ្យការអមសាលាដំបូងចំពោះចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌ
- ដឹងអំពីតួនាទី ភារកិច្ចរបស់ព្រះរាជអាជ្ញានិងព្រះរាជអាជ្ញារង ដែលតំណាងឱ្យអយ្យការអមសាលាដំបូង
- ទទួលបានបទពិសោធន៍ថ្មីក្នុងការតាក់តែងសារណាបញ្ចប់ការសិក្សាមួយនេះឡើង
- សារៈសំខាន់ចំពោះបងប្អូន ដែលជានិស្សិតជំនាន់ក្រោយៗ
- បន្សល់ទុកជាឯកសារសម្រាប់បងប្អូន ដែលជានិស្សិតជំនាន់ក្រោយៗ ដែលមានបំណងធ្វើការសិក្សាចំពោះប្រធានបទសារណានេះ។

**ច). វិធីសាស្ត្រនៃការស្រាវជ្រាវ**

ចំពោះការប្រមូលទិន្នន័យឯកសារនានាដែលទាក់ទងនឹងការសិក្សាស្រាវជ្រាវនៃប្រធានបទនេះ ក្រុមយើងខ្ញុំ បានកំណត់ទិន្នន័យចំនួន ២ ដើម្បីដំណើរនៃការសិក្សាស្រាវជ្រាវប្រធានបទមួយនេះដោយជោគជ័យនោះគឺ៖

ទី១). ទិន្នន័យចម្បង

ការសាកសួរសុំយោបល់ពីសំណាក់សាស្ត្រាចារ្យណែនាំរបស់ក្រុមយើងខ្ញុំ ក៏ដូចជាសាកសួរនិស្សិតជំនាន់មុនដែលជាសិស្សច្បង។

ទី២). ទិន្នន័យបន្ទាប់បន្សំ

ឯកសារផ្សេងៗដែលធ្វើការសិក្សាស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណេត ក៏ដូចជាឯកសារ សារណារបស់សិស្សច្បងគ្រប់ជំនាន់។

**ឆ). រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**

នៅក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះ ក្រុមយើងខ្ញុំនឹងរៀបរាប់ត្រួសៗ អំពីអត្ថន័យនៃជំពូកនីមួយៗ។ សារណានេះចែកចេញជា **៣ជំពូក** ដូចតទៅៈ

- **ជំពូកទី១.** សញ្ញាណទូទៅនៃអង្គការអយ្យការ និងប្រវត្តិសង្ខេបនៃការបង្កើតអង្គការអយ្យការនៅព្រះរាជាណាចក្រកម្ពុជា។

  ផ្នែកទី ១. ការរៀបចំនៃអង្គការអយ្យការ រចនាសម្ព័ន្ធនៃអង្គការអយ្យការ។

  ផ្នែកទី ២. រៀបរាប់អំពី សមត្ថកិច្ច តួនាទីភារកិច្ច និងសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា។

  ផ្នែកទី ៣. គោលការណ៍នៃការរៀបចំអង្គការអយ្យការ។

- **ជំពូកទី២.** លក្ខខណ្ឌនៃការចោទប្រកាន់។

  ផ្នែកទី១. ការពិនិត្យទៅលើកាលានុវត្តភាពនៃការចោទប្រកាន់។ អំពីសេរីភាពក្នុងការសម្រេចរបស់ព្រះរាជអាជ្ញា។ អំពីសេចក្តីសម្រេចរបស់អយ្យការទាក់ទងនឹងការចោទប្រកាន់។

  ផ្នែកទី២. រៀបរាប់ អំពីការតម្កល់រឿងទុកឥតចាត់ការរបស់អង្គការអយ្យការ។

- **ជំពូកទី៣.** ការចោទប្រកាន់របស់តំណាងអយ្យការ។

  ផ្នែកទី១. សញ្ញាណទូទៅនៃការចោទប្រកាន់ អាជ្ញាធរទទួលបន្ទុកក្នុងការចោទប្រកាន់ និងប្រភេទនៃការចោទប្រកាន់។

  ផ្នែកទី២. ការបញ្ជូនរឿងក្តីទៅចៅក្រមស៊ើបសួរ មានដូចជាៈ ការបើកការស៊ើបសួរ។

  ផ្នែកទី៣. ការបញ្ជូនរឿងក្តីទៅចៅក្រមជំនុំជម្រះ មានដូចជាៈ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងតាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។

# ជំពូកទី ១

# អង្គការអយ្យការ

# ជំពូកទី១

# អង្គការអយ្យការ

អង្គការអយ្យការ គឺជាស្ថាប័នមួយរបស់រដ្ឋសម្រាប់ដំណើរការនៃបណ្តឹងអាជ្ញា ឬ បណ្តឹងព្រហ្មទណ្ឌ។ អង្គការអយ្យការគឺជាស្ថាប័នមួយដែលព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ធ្វើការដើម្បីឱ្យបានសម្រេចបេសកកម្មរបស់អង្គការអយ្យការនេះ។ មានទស្សនៈ ពីរខុសគ្នាដែលចោទសួរថា តើស្ថាប័ននេះតំណាងឱ្យរដ្ឋ សង្គម ឬរដ្ឋាភិបាល។ នេះមានន័យថា នៅពេលចាត់ការបណ្តឹងព្រហ្មទណ្ឌម្តងៗ តើព្រះរាជអាជ្ញា តំណាងឱ្យអង្គការមួយណា។ តាមន័យសាមញ្ញនៃពាក្យ "ព្រះរាជអាជ្ញា" យើងអាចយល់បានថា បុគ្គលនេះតំណាងឱ្យព្រះមហាក្សត្រដោយខ្លួនបាន "អាជ្ញា" ឬអំណាចពីព្រះមហាក្សត្រ[1]។ នេះជាការពិត នៅសម័យមុនៗក្នុងសម័យរាជាធិបតេយ្យផ្តាច់ការ ព្រះមហាក្សត្រ មានអំណាចអធិបតេយ្យ ដោយកាន់កាប់អំណាច បី គឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ។ ព្រះរាជអាជ្ញា ប្តឹងសុំឱ្យអនុវត្តច្បាប់ ក្នុងឋានៈជាព្រះរាជតំណាងនិងក្នុងនាមព្រះមហាក្សត្រដែលជាម្ចាស់អំណាចអធិបតេយ្យ ។ ប៉ុន្តែ នៅសម័យក្រោយៗមក ព្រះមហាក្សត្រលែងមានអំណាចអធិបតេយ្យបែបនេះទៀតហើយ។ ប្រទេសជាច្រើន ដែលរក្សាទុករាជានិយម បានប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដោយអំណាចទាំងអស់ត្រូវអនុវត្តដោយតំណាងប្រជាពលរដ្ឋ តាមរយៈសភា រដ្ឋាភិបាល និង តុលាការ។ ដោយកាលពីមុនព្រះរាជអាជ្ញាតំណាងឱ្យព្រះមហាក្សត្រដែលមានអំណាចអធិបតេយ្យ ហើយនៅពេលនេះអំណាចអធិបតេយ្យនេះធ្លាក់មកលើរាស្ត្រវិញនោះអំណាចរបស់ព្រះរាជអាជ្ញា ដែលតំណាងឱ្យព្រះមហាក្សត្រនោះ ត្រូវផ្ទេរមកជាអំណាចតំណាងឱ្យរាស្ត្រដែលមានអំណាចអធិបតេយ្យវិញ។

អង្គការអយ្យការ គឺជាស្ថាប័នអយ្យការទាំងឡាយដែលត្រូវបានដាក់ពង្រាយឱ្យអមនៅតាមសាលាជម្រះក្តីនីមួយៗគ្រប់ជាន់ថ្នាក់។ ចំណែកពាក្យថា អយ្យការ គឺជាស្ថាប័នមួយនៅក្នុងចំណោមអង្គការអយ្យការ។ អង្គការអយ្យការគឺជាស្ថាប័នមួយរបស់រដ្ឋ សម្រាប់ដំណើរការបណ្តឹងព្រហ្មទណ្ឌ។ ដោយអនុលោមតាមមាត្រា ១៣១ ថ្មីនៃរដ្ឋធម្មនុញ្ញ បានកំណត់ថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា[2]។ អង្គការអយ្យការ មានតួនាទីធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ[3]។ បានន័យថា អង្គការអយ្យការមានសិទ្ធិក្នុងការបង្ក្រាបរាល់បទល្មើស

---

[1] ឧទាហរណ៍ នៅក្នុងប្រទេសកម្ពុជា កាលនោះក៏មានបញ្ជាក់នៅក្នុងក្រមពិភាក្សាព្រហ្មទណ្ឌ ១៩៣៧ មាត្រា ៤ ដែលចែងថា ឯបណ្តឹងដែលសុំឱ្យធ្វើទោសនោះ ត្រូវតែមានមន្ត្រីដែលព្រះករុណាទ្រង់សព្វព្រះរាជហឫទ័យតាំងចាត់ចែងធ្វើបណ្តឹងនោះ។

[2] មាត្រា ១៣១ ថ្មីរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[3] មាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ទាំងឡាយណាដែលជាបទល្មើសព្រហ្មទណ្ឌ ដើម្បីការពារផលប្រយោជន៍សាធារណៈ និងប្រយោជន៍សង្គមជាតិ ។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួនដើម្បីធានាបានថាគ្រប់បុគ្គលត្រូវបានចាប់ខ្លួន ត្រូវបាននាំខ្លួនទៅកាន់តុលាការដើម្បីផ្តន្ទាទោសតាមច្បាប់។ ក្នុងករណីដែលអង្គការអយ្យការមានការលំបាកក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនក្នុងកាលៈទេសៈណាមួយនោះ អង្គការអយ្យការមានសិទ្ធិកេណ្ឌកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ ដើម្បីធានានូវប្រសិទ្ធភាពក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនឱ្យទទួលបានជោគជ័យតាមបញ្ញត្តិច្បាប់។ ហើយការអនុវត្តភារកិច្ចរបស់ខ្លួន អង្គការអយ្យការគឺ អនុវត្តភារកិច្ចតាមឋានានុក្រម របស់ខ្លួនពីខ្ពស់ទៅទាបតាមគោលការណ៍គតិយុត្តិ។ អង្គការអយ្យការ គឺជាស្ថាប័នមួយដែលនៅដាច់ដោយឡែកពីតុលាការថ្វីត្បិតតែស្ថាប័ននេះនៅក្នុងបរិវេណតុលាការក៏ពិតមែនតែស្ថាប័នអង្គការអយ្យការនេះមានអ្នកដឹកនាំដោយឡែកផ្សេងពីតុលាការ។ ក៏ប៉ុន្តែមន្ត្រី ដែលបម្រើការងារនៅក្នុងស្ថាប័នទាំងពីរនេះសុទ្ធសឹងតែជាអ្នកចេញពីសាលាចៅក្រមដូចគ្នាដោយគ្រាន់តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បែងចែកឱ្យបំពេញមុខងារផ្សេងៗគ្នាតែប៉ុណ្ណោះ។ ចៅក្រមដែលត្រូវ តែងតាំងឱ្យទៅបំពេញមុខងារនៅ ខាងស្ថាប័នតុលាការខ្លះជាចៅក្រមខ្លះជាប្រធានតុលាការនិងខ្លះជាអនុប្រធានតុលាការ។ ចំណែកចៅក្រមដែលត្រូវតែងតាំងឱ្យទៅបំពេញមុខងារនៅស្ថាប័នអង្គការអយ្យការខ្លះជាព្រះរាជអាជ្ញា និងខ្លះជាព្រះរាជអាជ្ញារង។

នៅក្នុងកំឡុងពេល ឡើងជំនុំជម្រះក្តី ឬហៅថាពេលសវនាការ ដែលមានវត្តមានមន្ត្រីទាំងពីរស្ថាប័នគឺស្ថាប័នតុលាការនិងស្ថាប័នអយ្យការខាងស្ថាប័នតុលាការគេហៅថាចៅក្រមជំនុំជម្រះ ខាងស្ថាប័នអយ្យការ គេហៅថាតំណាងអយ្យការមិនមែនហៅថា ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង នោះទេ។ គួរកត់សម្គាល់ផងដែរថាអ្នកដឹកនាំ ខ្ពស់ជាងគេនៅក្នុងស្ថាប័នអយ្យការអមសាលាដំបូង គឺជាព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គេមិនហៅថាជាប្រធានអយ្យការ ឬប្រធានព្រះរាជអាជ្ញានោះទេ។ ព្រះរាជអាជ្ញា ជាចៅក្រមវិជ្ជាជីវៈដែលមានភារកិច្ចបំពេញមុខងារជាចៅក្រមខាងចៅក្រមអយ្យការ។ តាមគោលការណ៍ ព្រះរាជអាជ្ញា ជាមន្ត្រីសាធារណៈដែលមានសិទ្ធិអំណាចធ្វើបណ្តឹងអាជ្ញា ចោទប្រកាន់ជនដែលប្រព្រឹត្តបទល្មើស តាមបញ្ញត្តិច្បាប់ដើម្បីការពារប្រយោជន៍សាធារណៈ និងប្រយោជន៍សង្គមជាតិ។

អង្គការអយ្យការជា យន្តការជាតិមួយសម្រាប់ជួយស្ថាប័នតុលាការ ក្នុងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ដើម្បីធានាឱ្យបាននូវអត្ថប្រយោជន៍សង្គមជាតិតាមរយៈការអនុវត្តបណ្តឹងអាជ្ញា ចោទប្រកាន់ជនដែលបានប្រព្រឹត្តបទល្មើសធ្វើសេចក្តីសន្និដ្ឋានវាយតម្លៃ បទល្មើស ដោយទាមទារឱ្យតុលាការពិនិត្យបទល្មើស រកឱ្យឃើញនូវពិរុទ្ធភាពនៃបទល្មើស និងផ្តន្ទាទោសជនល្មើសតាមផ្លូវច្បាប់។

## ក. ប្រវត្តិសង្ខេបនៃការបង្កើតអង្គការអយ្យការនៅប្រទេសកម្ពុជា

- **ពីឆ្នាំ ១៩៣៧ មកទល់ ឆ្នាំ ១៩៧០**

អង្គការអយ្យការត្រូវបានបង្កើតឡើងដំបូងបង្អស់នៅឆ្នាំ ១៩៣៧ ដោយការបញ្ចូលតំណែងនេះទៅក្នុងក្រមពិភាក្សាព្រហ្មទណ្ឌ ( ភាសាសម័យយើងនេះ គេហៅថាក្រមនីតិវិធីព្រហ្មទណ្ឌ) ។ មុនឆ្នាំ១៩៣៧ គេហៅថា(ក្រមលក្ខណពិភាក្សាព្រហ្មទណ្ឌ)។

យោងតាមក្រមនេះ នៅអមសាលាដំបូងនីមួយៗ មានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង។ ពេលនោះ តំណែងព្រះរាជអាជ្ញាមិនទាន់មាននៅគ្រប់សាលាដំបូងគ្រប់ខេត្តនៅឡើយទេ គឺមានតែនៅភ្នំពេញប៉ុណ្ណោះ។ ដោយមានការខ្វះខាតថវិកា គេបានជ្រើសយកប្រធានសាលាដំបូងឱ្យដើរតួនាទីពីរ ៖ ជាព្រះរាជអាជ្ញាអមសាលាដំបូងផង និងជាចៅក្រមជំនុំជម្រះផង[4]។

តួនាទីព្រះរាជអាជ្ញានេះមកជំនួស តួនាទីរបស់ចៅក្រមស៊ើបសួរ ឬសុភាចារបុរស ដែលដើមឡើយជាអ្នកបង្កសំណុំរឿងចោទប្រកាន់នៅសាលាមជ្ឈិម (ដែលជាផ្នែកនៃសាលាដំបូងសម្រាប់វិនិច្ឆ័យរឿងមជ្ឈិមដែលមានទោសពី ៥ (ប្រាំ) ថ្ងៃ ដល់ ៥ (ប្រាំ) ឆ្នាំ) ឬទៅសាលាក្រុមចោទ(ដែលជាសាខាមួយរបស់សាលាឧទ្ធរណ៍ដែលពិនិត្យរឿងឧក្រិដ្ឋ និងរឿងដែលប្តឹងជំទាស់នឹងដីការបស់សុភាចារបុរស)។

មន្ត្រីអយ្យការនៅអមសាលាដំបូងមានឈ្មោះថា ព្រះរាជអាជ្ញា ចំណែក សាលាឧទ្ធរណ៍ មន្ត្រីនេះមានឈ្មោះថា ព្រះរាជបំរើ។ ចំណែកនៅសាលាវិនិច្ឆ័យាធិតី(សមមូលនឹងតុលាការកំពូលយើងសព្វថ្ងៃ) វិញ ពុំមានព្រះរាជអាជ្ញានៅអមទេ។ ប៉ុន្តែ នៅសម័យក្រោយមកទៀត តំណែងអគ្គព្រះរាជអាជ្ញាអមសាលាវិនិច្ឆ័យត្រូវបានឃើញមាននៅក្នុងច្បាប់ស្តីពី លក្ខន្តិកៈស្តីពីយុត្តាធិការចៅក្រម និងក្រឡាបញ្ជីខាងផ្នែកតុលាការ ចុះថ្ងៃទី ៩ ខែមីនា ឆ្នាំ ១៩៥៤។ តាមច្បាប់លក្ខន្តិកៈនេះ អគ្គព្រះរាជអាជ្ញាអមសាលាវិនិច្ឆ័យគ្មានអំណាចលើសមាជិកនៃក្រសួងអយ្យការទេ ។ ដូចនេះ អគ្គព្រះរាជអាជ្ញាអមសាលាវិនិច្ឆ័យ យ៉ាងហោចណាស់ ចាប់មានអត្ថិភាពចាប់តាំងពីឆ្នាំនោះមក។

- **ពីឆ្នាំ ១៩៧០ មកទល់ ឆ្នាំ ១៩៧៥**

ថ្វីបើប្រទេសខ្មែរបានប្តូររបបពីរាជានិយមមកជាសាធារណរដ្ឋនិយម នៅក្នុងចន្លោះឆ្នាំ ១៩៧០ និង ឆ្នាំ ១៩៧៥ ក្តីក៏ប្រព័ន្ធច្បាប់នៅប្រទេសខ្មែរមិនបានផ្លាស់ប្តូរដូចនៅសម័យក្រោយៗទេ។ របបសាធារណរដ្ឋរបស់សេនាប្រមុខ លន់ ណុល បន្តនិរន្តរភាពនៃប្រព័ន្ធតុលាការរហូតដល់ពេលត្រូវបានកម្លាំងប្រដាប់អាវុធខ្មែរក្រហម ផ្តួល រំលំនិងឡើងកាន់អំណាចបន្តនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ ចំនួនរដ្ឋអាជ្ញានៅក្នុងសម័យ

[4] បុព្វកថាដែលចុះហត្ថលេខាដោយលោក ឡេស៊ែរ នៅថ្ងៃ ១៨ មករា ១៩៣៧ ចំពោះក្រមពិភាក្សាព្រហ្មទណ្ឌ ឆ្នាំ ១៩៣៧។

សាធារណរដ្ឋនោះ ដែលសល់បន្តពីសម័យមុនមកមានចំនួន ៣៨ នាក់ ក្នុងនោះមានស្ត្រីម្នាក់ជាភរិយារបស់លោកអ៊ឹង មឹង ដែលមាននាមដើម យស់ ឡាម្វែល។ រដ្ឋអាជ្ញាពីរនាក់ក្នុងចំណោមចំនួននេះ មានតំណែងនៅក្នុង ក្រសួងយុត្តិធម៌។ ចំណែកឯចៅក្រមវិញមានចំនួន ៩២ នាក់ ហើយពុំមានស្ត្រីទេ[5]។

- **ពីឆ្នាំ ១៩៧៥ មកទល់ ឆ្នាំ ១៩៧៩**

នេះជាសម័យដែលប្រទេសខ្មែរគ្មានប្រព័ន្ធច្បាប់ គ្មានប្រព័ន្ធតុលាការអ្វីទាំងអស់។ លើកលែងតែរដ្ឋធម្មនុញ្ញមួយគត់ ដែលអនុម័តដោយសភាខ្មែរក្រហម ប្រទេសខ្មែរក្នុងរយៈពេលនោះគ្មានអត្ថបទច្បាប់អ្វីទាំងអស់ដើម្បីអនុវត្ត ថ្វីបើរបបកម្ពុជាប្រជាធិបតេយ្យមិនបានប្រកាសនិរាករណ៍ច្បាប់ពីសម័យមុនៗក៏ដោយ។

ពួកខ្មែរក្រហមបានបង្កើតរដ្ឋធម្មនុញ្ញមួយយ៉ាងចម្លែកដែលមិនទទួលស្គាល់សិទ្ធិនិងសេរីភាពបុគ្គលអ្វីទាំងអស់។ ចំពោះប្រព័ន្ធតុលាការវិញ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានបង្កើតប្រព័ន្ធតុលាការមួយដែលមានឈ្មោះថា "តុលាការប្រជាជន"[6]។ គ្មានអ្នកណាម្នាក់យល់ពីសញ្ញាណនៃតុលាការប្រជាជន ក្រៅពីអ្នកតាក់តែងធម្មនុញ្ញនេះទេ។ ពាក្យ "តុលាការប្រជាជន" នេះត្រូវបានប្រើដោយកម្មាភិបាល ឬប្រជាពលរដ្ឋស្នូលរបស់ខ្មែរក្រហម ដែលអាចប្រដូចទៅនឹងប្រព័ន្ធយុត្តិធម៌មួយដែលធ្វើអ្វីតាមទំនើងចិត្ត និងអមនុស្សធម៌។ មនុស្សទាំងអស់នេះពន្យល់ថា ប្រជាជនជាអ្នកកាត់សេចក្តី។

ការជាក់ស្តែងគេមិនដែលឃើញមានការរួមប្រជុំប្រជាជនដើម្បីកាត់សេចក្តីអ្នកណាម្នាក់ឡើយ។ គេតែងតែសង្កេតឃើញកម្មាភិបាល ដូចជាប្រធានភូមិ ប្រធានក្រុម ប្រជាជនមូលដ្ឋាន (ប្រជាជនដែលបានរស់នៅក្នុងតំបន់ត្រួតត្រាដោយខ្មែរក្រហមក្នុងពេលចម្បាំងជាមួយរបបសាធារណរដ្ឋ) ឬ ឈ្លប ជាអ្នកចោទថាអ្នកនេះធ្វើខុស អ្នកនេះជាអ្នកក្បត់។

តាមរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បទល្មើសមានតែពីរប្រភេទទេគឺ បទល្មើសប្រឆាំង និងបំផ្លិចបំផ្លាញរដ្ឋ ដែលត្រូវមានទោសធ្ងន់ ហើយបទល្មើសក្រៅពីនេះត្រូវទទួលតែការអប់រំប៉ុណ្ណោះ[7]។

---

[5] យោងតាម ក្រឹត្យលេខ ១៤២/៧៣/បសខ ចុះថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៩៧៣។

[6] មាត្រា ៩ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យចែងថា ៖ " តុលាការ ជាតុលាការរបស់ប្រជាជន តំណាងយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌របស់ប្រជាជន ការពារសិទ្ធិ សេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោសដល់គ្រប់សកម្មភាពដែលប្រឆាំងនឹងរដ្ឋរបស់ប្រជាជន ឬដែលល្មើសនឹងច្បាប់រដ្ឋរបស់ប្រជាជន។ តុលាការគ្រប់ជាន់ថ្នាក់ត្រូវសភាតំណាងជ្រើសរើស និងតែងតាំង"។

[7] មាត្រា ១០ នៃរដ្ឋធម្មនុញ្ញនេះចែងថា ៖ "ប្រភេទបទល្មើសច្បាប់រដ្ឋប្រជាជនមានដូចតទៅ

- ចំពោះប្រភេទសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញដែលមានលក្ខណៈជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋប្រជាជន ត្រូវផ្តន្ទាទោសកំរិតខ្ពស់បំផុត
- ចំពោះប្រភេទល្មើសក្រៅពីប្រភេទខាងលើ ត្រូវអប់រំកសាងក្នុងក្របខណ្ឌអង្គការរដ្ឋ ឬក្នុងក្របខណ្ឌអង្គការប្រជាជន"។

សរុបសេចក្តីមក ប្រព័ន្ធចោទប្រកាន់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យស្ថិតនៅលើបុគ្គលម្នាក់ៗ ជាកម្មាភិបាល ( ជាមន្ត្រីរបស់របបនេះ) ជាអ្នកសម្រេច ដោយផ្អែកតែលើការសង្ស័យតែម្យ៉ាង ហើយអ្នកចោទនេះជាអ្នកកាត់សេចក្តីផងដែរ។

- **ពីឆ្នាំ ១៩៧៩ ដល់ ឆ្នាំ ១៩៩២**

នេះជារយៈពេលដែលប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម។ អង្គការអយ្យការត្រូវបានបង្កើត ៣ ឆ្នាំ ក្រោយពេលដែលកងទ័ពវៀតណាមចូលកាន់កាប់ប្រទេសកម្ពុជា។ ដូចបានបញ្ជាក់ពីខាងលើ ប្រទេសកម្ពុជាបានបាត់បង់ស្ថាប័នច្បាប់របស់ខ្លួននៅក្រោមរបបខ្មែរក្រហម។ ធនធានមនុស្សក៏លោយស្ទើរតែអស់ក្នុងរបបនោះ។ ក្នុងចំណោមរដ្ឋអាជ្ញាចំនួន ៣៨ នាក់ក្នុងសម័យសាធារណរដ្ឋខ្មែរ ប្រហែលជា ៣នាក់ប៉ុណ្ណោះដែលនៅសល់ជីវិត នៅក្រោយពីការរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយក្នុងចំណោមចៅក្រម ៩២ នាក់ មានចៅក្រម ប្រហែល ៨ នាក់ដែលនៅសល់ជីវិត។ [8]

ប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាមិនមាននិរន្តភាពដូចជានៅប្រទេសផ្សេងៗទៀតទេ។ លក្ខណៈនិងអត្តសញ្ញាណនៃប្រព័ន្ធច្បាប់ និងច្បាប់នានានៃប្រទេសនេះផ្លាស់ប្តូរទៅតាមរបបកាន់កាប់អំណាចជាពិសេសចាប់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យមក ពីព្រោះការផ្ទេរអំណាចពីរបបមួយទៅរបបមួយត្រូវបានធ្វើឡើងដោយសារសង្គ្រាមបដិវត្ត។

នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ថ្វីបើមានការកសាងឡើងវិញនូវប្រព័ន្ធច្បាប់មួយដែលបានរលត់រលាយហើយនោះ ប្រព័ន្ធថ្មីនេះទទួលឥទ្ធិពលពីកត្តា បី យ៉ាងគឺៈ

- ទស្សនៈនយោបាយនៃរបបថ្មី
- ស្ថានភាពសន្តិសុខនៃប្រទេស
- និងការទទួលឥទ្ធិពលវៀតណាមតាមរយៈ អ្នកជំនាញការនិងការអប់រំ[9]។

- **នៅឆ្នាំ ១៩៩៣ មកដល់បច្ចុប្បន្ន**

ចាប់ពីឆ្នាំ១៩៩៣ មកតុលាការនៃប្រទេសកម្ពុជាត្រូវបានរៀបចំនិងកែប្រែតាមគំរូថ្មី ឧទាហរណ៍ ការបង្កើតចៅក្រមស៊ើបអង្កេត ការលុបចោលនូវទីប្រឹក្សាប្រជាជនពីក្រុមប្រឹក្សាវិនិច្ឆ័យ ការបង្កើតសាលាឧទ្ធរណ៍

[8] សៀវភៅ ស្តីពីអង្គការអយ្យការ ( ប្រវត្តិ និងការសិក្សាប្រៀបធៀប) របស់លោក កុយ នាម និង លោក ឡុង បញ្ញាវុធ បោះពុម្ព ឆ្នាំ ២០០៦

[9] សម្រាប់ព័ត៌មានលំអិតសូមអានជំពូកទី ១១ អំពីច្បាប់, សិទ្ធិមនុស្ស និងរឿងក្តីក្រកូលយេន ក្នុងសៀវភៅ កម្ពុជាបន្ទាប់ពីរបបខ្មែរក្រហម របស់លោក ឆេវិន ហ្គុតស្មាន់

ការអនុម័តនីតិវិធីព្រហ្មទណ្ឌថ្មី ការអនុម័តច្បាប់ព្រហ្មទណ្ឌថ្មីដោយអាជ្ញាធរ អន្តរកាលនៃអង្គការសហប្រជាជាតិនៅកម្ពុជា ការបង្កើតឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញជាដើម។

ជាក់ស្តែងក្រមនីតិវិធីព្រហ្មទណ្ឌដែលត្រូវបានចូលជាធរមាននៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ មកច្បាប់និងបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលរួមមានក្រមព្រហ្មទណ្ឌអន្តរកាល និងក្រមនីតិវិធីព្រហ្មទណ្ឌអន្តរកាល ត្រូវបាននិរាករណ៍ដោយច្បាប់ថ្មីនេះ។

## ផ្នែកទី១៖ ការរៀបចំនៃអង្គការអយ្យការ

អង្គការអយ្យការមានមុខងារធ្វើបណ្តឹងអាជ្ញា និងសុំឱ្យអនុវត្តច្បាប់នៅ ចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងអនុវត្តមុខងារផ្សេងទៀតតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន[10]។ ការរៀបចំនៃអង្គការអយ្យការ ត្រូវបានរៀបចំឡើងដោយមាន **រចនាសម្ព័ន្ធអង្គការអយ្យការ** ដូចខាងក្រោម៖

### ១. រចនាសម្ព័ន្ធនៃអង្គការអយ្យការ

រចនាសម្ព័ន្ធនៃអង្គការអយ្យការ ត្រូវបានបែងចែកជា ពីរ (២) ប្រភេទគឺ អង្គការអយ្យការ និងអង្គការមហាអយ្យការ៖

#### ១.១. អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

សាលាដំបូងជាសាលាជម្រះក្តីថ្នាក់ទីមួយ ដែលត្រូវបង្កើតឱ្យមាននៅរាជធានីភ្នំពេញ និងនៅគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។ ការដាក់ឱ្យដំណើរការសាលាដំបូងនានា ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ[11]។ នៅគ្រប់សាលាដំបូងរាជធានី-ខេត្ត គឺតែងតែមានអយ្យការអមមួយដែលគេហៅថា អយ្យការអមសាលាដំបូង។ អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ជាស្ថាប័នមួយសម្រាប់ធ្វើការចោទប្រកាន់រាល់រឿងក្តីដែលបានកើតឡើងនៅគ្រប់រាជធានី-ខេត្ត ដែលជាដែនសមត្ថកិច្ចរបស់សាលាដំបូងរាជធានី-ខេត្ត។ អង្គការអយ្យការជាអង្គអវិភាគ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ អង្គការអយ្យការអមសាលាដំបូង មានតំណាងនិងដឹកនាំដោយព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង។[12]

[10] មាត្រា ៣០ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

[11] មាត្រា ១២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

[12] មាត្រា ៣៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ១.១.១. ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាជាប្រមុខដឹកនាំរបស់អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត។មិនត្រឹមតែប៉ុណ្ណោះ ព្រះរាជអាជ្ញា ជាអ្នកចោទប្រកាន់ក្នុងដំណើរការរឿងក្ដីព្រហ្មទណ្ឌ ហេតុដូច្នេះ បានជាព្រះរាជអាជ្ញា ជាតួអង្គយ៉ាងសំខាន់នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ។

### ១.១.២. ព្រះរាជអាជ្ញារង

ព្រះរាជអាជ្ញារងស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ដោយប្រើប្រាស់សិទ្ធិទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ[13]។

យោងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ បានកំណត់ថា អយ្យការអមសាលាដំបូងមានសមាសភាពដូចជា៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅអយ្យការអមសាលាដំបូង[14]។

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ។ ព្រះរាជអាជ្ញាមានអំណាចលើព្រះរាជអាជ្ញារងទាំងអស់ ដែលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ព្រះរាជអាជ្ញាចាត់តាំង និងបែងចែកការងារដល់ព្រះរាជអាជ្ញារងទាំងអស់។

ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន ព្រះរាជអាជ្ញាត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ដើម្បីជំនួសខ្លួនបាន។ ព្រះរាជអាជ្ញាមានសិទ្ធិធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ ឬក៏ចាត់ឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ[15]។

## ១.២. អង្គការមហាអយ្យការអមតុលាការជាន់ខ្ពស់

អង្គការមហាអយ្យការ គឺជាអង្គការដែលនៅអមសាលាជម្រះក្តីជាន់ខ្ពស់ ដែលមាន **មហាអយ្យការអមសាលាឧទ្ធរណ៍** និង **មហាអយ្យការអមតុលាការកំពូល**។

[13] មាត្រា ៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[14] មាត្រា ២៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

[15] មាត្រា ៣០ និង មាត្រា ៣១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

### ក). មហាអយ្យការអមសាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍ គឺជាសាលាជម្រះក្តីថ្នាក់ទី ពីរ។ សាលាឧទ្ធរណ៍រួមមានសាលាឧទ្ធរណ៍ភ្នំពេញ និង សាលាឧទ្ធរណ៍តាមតំបន់។ ការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់នីមួយៗ និងការកំណត់ពីសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍តំបន់នេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ[16]។

នៅសាលាឧទ្ធរណ៍ គឺមានស្ថាប័នអយ្យការមួយដែលគេហៅថា មហាអយ្យការអមសាលាឧទ្ធរណ៍។ មហាអយ្យការអមសាលាឧទ្ធរណ៍ តំណាងដោយ ៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង និង
- ព្រះរាជអាជ្ញា ។[17]

យោងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មហាអយ្យការអមសាលាឧទ្ធរណ៍មានសមាសភាពដូចជា ៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង
- ព្រមទាំងមាន មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍[18]។

មុខងាររបស់មហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវបានប្រគល់ឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ចំណែកអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចក្នុងការគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទៅក្នុងការងារផ្សេងៗនៃមហាអយ្យការនិងក្នុងអង្គជំនុំជម្រះ។ ក្នុងករណីមានធុរៈ ឬមានជំងឺ

[16] មាត្រា ៣៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

[17] មាត្រា ៣៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[18] មាត្រា ៤៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេ អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ដើម្បីជំនួសខ្លួនបាន។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញាអមសាលាដំបូង ធ្វើការចោទប្រកាន់ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន[19]។

**ខ). មហាអយ្យការអមតុលាការកំពូល**

នៅក្នុងតុលាការកំពូល មានស្ថាប័នអយ្យការមួយនៅអមដែលគេហៅថា **មហាអយ្យការអមតុលាការកំពូល**។ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ មហាអយ្យការអមតុលាការកំពូល គឺតំណាងដោយៈ

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង និង
- ព្រះរាជអាជ្ញាអមតុលាការកំពូល[20]។

នៅក្នុងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ក៏បានកំណត់ផងដែរថា នៅក្នុងមហាអយ្យការអមតុលាការកំពូលមានសមាសភាពដូចជាៈ

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី
- ព្រមទាំងមាន មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅមហាអយ្យការអមតុលាការកំពូល[21]។

មុខងាររបស់មហាអយ្យការអមតុលាការកំពូល ត្រូវបានប្រគល់ឱ្យអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ ចំណែក អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមអនុវត្តមុខងារនេះក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមានអំណាចក្នុងការគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និង ព្រះរាជអាជ្ញាអមតុលាការកំពូល។

[19] មាត្រា ៥០ និង មាត្រា ៥១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

[20] មាត្រា ៣១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[21] មាត្រា ៦៨ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទៅក្នុងការងារផ្សេងៗនៃមហាអយ្យការនិងក្នុងអង្គជំនុំជម្រះ។ ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេ អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ដើម្បីជំនួសខ្លួនបាន[22]។

## ផ្នែកទី២៖ សមត្ថកិច្ច តួនាទី ភារកិច្ច និងសិទ្ធិអំណាចនៃអង្គការអយ្យការ

### ១. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា

នៅពេលដែលមានបទល្មើសណាមួយកើតឡើង ថាតើបទល្មើសដែលបានកើតឡើងនោះ ព្រះរាជអាជ្ញាណាមានសមត្ថកិច្ចក្នុងការទទួលសំណុំរឿងដោះស្រាយចំពោះបទល្មើសនោះ?

នេះបើយោងតាម ក្រមនីតិវិធីព្រហ្មទណ្ឌ សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញាត្រូវបានកំណត់ដូចតទៅ ៖[23]

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថា បានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស។

### ២. តួនាទីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាមានតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រងយុត្តិធម៌ និងវិធានច្បាប់នានា ដែលទាក់ទងទៅនឹងការអនុវត្តតាមការទទួលខុសត្រូវដ៏សំខាន់របស់ខ្លួន។

ព្រះរាជអាជ្ញាត្រូវដើរតួយ៉ាងសកម្មក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ រួមទាំងស្ថាប័នអយ្យការ ដែលច្បាប់បានអនុញ្ញាត ឬស្របតាមការអនុវត្តន៍ក្នុងស្រុក ក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ពិនិត្យមើលនីត្យានុកូលភាពក្នុងការស៊ើបអង្កេតនានា និងការបំពេញតួនាទីផ្សេងៗទៀត ដោយតំណាងឱ្យផលប្រយោជន៍សាធារណៈ។

---

[22] មាត្រា ៦៩ និង មាត្រា ៧០ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

[23] មាត្រា ៣៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ព្រះរាជអាជ្ញា ត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ហ្មត់ចត់ និងឱ្យបានឆាប់រហ័ស ស្រប តាមច្បាប់កំណត់ ហើយត្រូវគោរព និងការពារសេចក្ដីថ្លៃថ្នូររបស់មនុស្ស និងលើកកម្ពស់សិទ្ធិមនុស្ស ហេតុដូច្នេះ ត្រូវរួមជាវិភាគទានក្នុងការធានាដល់កិច្ចដំណើរការនៃប្រព័ន្ធយុត្តិធម៌ឱ្យបានត្រឹមត្រូវ និងមានភាពរលូន[24]។

### ៣. ភារកិច្ចរបស់ព្រះរាជអាជ្ញា

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាគឺជាអ្នកធ្វើការចោទប្រកាន់រាល់បទល្មើសទាំងឡាយ ដែលជាបទល្មើសព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញា ត្រូវអនុវត្តមុខនាទីរបស់ខ្លួន ដោយមិនលំអៀង និងជៀសវាង រាល់ការរើសអើងភេទ វប្បធម៌ ជាតិសាសន៍សាសនា ឋានៈសង្គម ឬ ការរើសអើងផ្សេងៗទៀត។

ព្រះរាជអាជ្ញា ត្រូវការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និង ជនរង គ្រោះដោយមិនលំអៀង និងត្រូវប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធទាំងអស់ ទោះជាស្ថានភាពនោះមាន ប្រយោជន៍ ឬគ្មានប្រយោជន៍ដល់ជនសង្ស័យក៏ដោយ។

ព្រះរាជអាជ្ញា ត្រូវរក្សារឿងក្ដីជាសម្ងាត់ លើកលែងតែត្រូវបំពេញភារកិច្ច បើពុំដូច្នោះទេនោះ គឺជាតម្រូវ ការរបស់តុលាការដើម្បីបញ្ជាក់ពីភាពយុត្តិធម៌។ ព្រះរាជអាជ្ញា ត្រូវពិនិត្យមើលពីទិដ្ឋភាពទូទៅ និងក្ដីបារម្ភរបស់ ជនរងគ្រោះ នៅពេលដែលមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ និងបញ្ជាក់ប្រាប់ពីសិទ្ធិរបស់ជន រងគ្រោះដល់ជនរងគ្រោះ ដើម្បីឱ្យស្របតាមសេចក្ដីប្រកាសស្ដីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានរបស់ជនរង គ្រោះ ក្នុងរឿងព្រហ្មទណ្ឌ និងការរំលោភអំណាច។[25]

### ៤. សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាប្រើប្រាស់សិទ្ធិអំណាចទាំងអស់ដែលក្រមនីតិវិធីព្រហ្មទណ្ឌ និងលិខិតបទដ្ឋានគតិយុត្ត ផ្សេងៗទៀតដែល ទទួលស្គាល់ឱ្យប្រើប្រាស់ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

ព្រះរាជអាជ្ញា ដឹកនាំសម្របសម្រួលសកម្មភាពរបស់មន្ត្រីនិងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅ ក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ព្រះរាជអាជ្ញាប្រើប្រាស់សិទ្ធិអំណាចទាំងអស់ដែលក្រមនេះបានទទួលស្គាល់ ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។

---

[24] មើលនៅគោលការណ៍ណែនាំ ស្ដីពី តួនាទីរបស់ព្រះរាជអាជ្ញា ដែលអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ស្ដីអំពី ការបង្ការបទឧក្រិដ្ឋ និងគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា នៃប្រទេសគុយបា នៅថ្ងៃទី ២៧ ខែ សីហា ដល់ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០។

[25] មើលនៅគោលការណ៍ណែនាំ ស្ដីពី តួនាទីរបស់ព្រះរាជអាជ្ញា ដែលអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ស្ដីអំពី ការបង្ការបទឧក្រិដ្ឋ និងគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា នៃប្រទេសគុយបា នៅថ្ងៃទី ២៧ ខែ សីហា ដល់ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០។

ព្រះរាជអាជ្ញា អាចចុះទៅកាន់កន្លែងស៊ើបអង្កេតនិងធ្វើការណែនាំដែលមានប្រយោជន៍ដល់មន្ត្រីនិងភ្នាក់ងារនគរបាលយុត្តិធម៌។ក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនោះ។

ព្រះរាជអាជ្ញា អាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យវិធានការឃាត់ខ្លួន ជាពិសេស គឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។[26] ព្រះរាជអាជ្ញាមានអំណាចលើព្រះរាជអាជ្ញារងទាំងអស់ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ព្រះរាជអាជ្ញាចាត់តាំង និងបែងចែកការងារដល់ព្រះរាជអាជ្ញារងទាំងអស់។ ព្រះរាជអាជ្ញាមានសិទ្ធិធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ ឬក៏ចាត់ឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ។

សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារង ត្រូវតែបញ្ជូនទៅព្រះរាជអាជ្ញាពិនិត្យនៅមុនពេលសវនាការ។ ប្រសិនបើព្រះរាជអាជ្ញាមិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ហើយតំណាងអយ្យការដែលជាអ្នកធ្វើសេចក្តីសន្និដ្ឋាននោះនៅតែមិនព្រមធ្វើតាមព្រះរាជអាជ្ញាអាចចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀត ឬក៏ព្រះរាជអាជ្ញាចាត់តាំងខ្លួនឯងតែម្តង ឱ្យធ្វើជាតំណាងអយ្យការនៅក្នុងសវនាការនៃសាលាដំបូង[27]។

## ផ្នែកទី៣៖ គោលការណ៍នៃការរៀបចំអង្គការអយ្យការ

គោលការណ៍នៃការរៀបចំអង្គការអយ្យការ នៅក្នុងទំនាក់ទំនងការងារនៃការរៀបចំអង្គការអយ្យការចៅក្រមអយ្យការ ត្រូវគោរពតាមគោលការណ៍ ៣ (បី)គឺ៖ គោលការណ៍ ឋានានុក្រម ឬ គោលការណ៍ឯកភាព គោលការណ៍អវិភាគ ឬ គោលការណ៍នៃភាពមិនអាចចែកដាច់ពីគ្នា និង គោលការណ៍ឯករាជ្យរវាងអង្គការអយ្យការ និង តុលាការ។

### ១. គោលការណ៍ ឋានានុក្រម ឬ គោលការណ៍ឯកភាព

គោលការណ៍នេះគឺមានន័យថា ព្រះរាជអាជ្ញារងនៅអមសាលាដំបូងនីមួយៗ ធ្វើការក្រោមការទទួលខុសត្រូវ និងការណែនាំរបស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាមានសិទ្ធិណែនាំ និងបញ្ជាទៅដល់ព្រះរាជអាជ្ញារងទាំងអស់។

[26] មាត្រា ៣៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[27] មាត្រា ៣១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

ក្រៅពីនេះទៀត ក្នុងក្របខណ្ឌនៃដំណើរការរឿងក្តីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាទាំងអស់ត្រូវគោរពអធិបញ្ជានៃអំណាចឋានានុក្រមរបស់ខ្លួន បានន័យថា ព្រះរាជអាជ្ញារង ត្រូវគោរពបញ្ជារបស់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញាត្រូវគោរពអធិបញ្ជារបស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ឬរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចធ្វើអធិបញ្ជាទៅដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងចំពោះបណ្តឹង ឬបទល្មើសដែលខ្លួនបានដឹង (តែមិនអាចធ្វើអធិបញ្ជាឱ្យតម្កល់រឿងទុកឥតចាត់ការបានទេ) ហើយបង្ហាញ ឬបញ្ជានូវសេចក្តីសន្និដ្ឋានដែលខ្លួន យល់ឃើញថាជាការគួរ។ ដូចដែលបានបញ្ជាក់ខាងលើថា ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ទាំងឡាយត្រូវគោរពនូវគោលការណ៍ឋានានុក្រម ឬអធិបញ្ជារបស់ថ្នាក់លើ។ ប៉ុន្តែ នៅពេលសវនាការ ព្រះរាជអាជ្ញា មានសេរីភាពខាងយោបល់របស់ខ្លួនបានន័យថា បណ្តឹងដោយផ្ទាល់មាត់នៅពេលសវនាការ គាត់អាចធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់តាមការយល់ឃើញរបស់ខ្លួន ហើយបណ្តឹងដោយផ្ទាល់មាត់នេះ ដែលអាចផ្ទុយទៅនឹងអធិបញ្ជារបស់ថ្នាក់លើ មិនអាចធ្វើជាមូលដ្ឋានចោទប្រកាន់ខាងបទវិន័យរបស់គាត់ ដែលនេះជា គោលការណ៍សម្រាប់ព្រះរាជអាជ្ញា យើងហៅថា «ប៉ាកកាជាទាសី សម្តីដោយសេរី» បានន័យថា ក្នុងដីកាសន្និដ្ឋានចោទប្រកាន់របស់គាត់ គឺត្រូវតែគោរពអធិបញ្ជារបស់ថ្នាក់លើបើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បញ្ជាឱ្យគាត់ ចោទប្រកាន់ពីបទល្មើសណាមួយ គាត់ត្រូវតែចោទប្រកាន់ជាដាច់ខាត។ ប៉ុន្តែ នៅពេលសវនាការ គាត់អាចបង្ហាញនូវការយល់ឃើញរបស់ខ្លួនដោយសេរី។

### ២. គោលការណ៍អវិភាគ ឬ គោលការណ៍នៃភាពមិនអាចចែកដាច់ពីគ្នា

គោលការណ៍នេះ គឺចង់សំដៅថា ក្នុងការបំពេញមុខងាររបស់ខ្លួន ចៅក្រមអយ្យការ អាចជំនួសគ្នាបានជានិច្ច បានន័យថា ក្នុងរឿងក្តីមួយពីចាប់ផ្តើមដំបូង ព្រះរាជអាជ្ញាចូលធ្វើការសន្និដ្ឋាន បន្ទាប់មកគាត់អាចឱ្យព្រះរាជអាជ្ញារងផ្ទាល់ប្តូរគ្នាបាន។ ផ្តើមចេញពី គោលការណ៍នេះ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងត្រូវទទួលខុសត្រូវរួមគ្នា បានន័យថា បើព្រះរាជអាជ្ញារងធ្វើខុស គឺព្រះរាជអាជ្ញា ត្រូវតែទទួលខុសត្រូវចំពោះថ្នាក់លើរបស់គាត់។

### ៣. គោលការណ៍ឯករាជ្យរវាងអង្គការអយ្យការ និង តុលាការ

តុលាការគ្មានអំណាចត្រួតពិនិត្យទៅលើចៅក្រមអយ្យការទេ។ ចៅក្រមអយ្យការ មិនស្ថិតនៅចំណុះឱ្យតុលាការដែលខ្លួននៅអមឡើយ។ ផ្នែកខាងចៅក្រមអសនៈ ឬ ប្រធានតុលាការ មិនអាចធ្វើការស្តីបន្ទោសទៅដល់ការចោទប្រកាន់ ឬសកម្មភាពការងារ របស់តំណាងអយ្យការបានទេ។ តែនៅក្នុងករណីខ្លះ តំណាង

អយ្យការធ្វើខុសដែលមើលទៅជាករណីធ្ងន់ធ្ងរ ចៅក្រមអសនៈ ជាពិសេស ប្រធានតុលាការអាចរាយការណ៍ទៅ ថ្នាក់លើនៃតំណាងអយ្យការ ប៉ុន្តែមិនអាចធ្វើការស្តីបន្ទោសផ្ទាល់បានទេ។

# ជំពូកទី ២

# លក្ខខណ្ឌនៃ

# ការចោទប្រកាន់

# ជំពូកទី២

# លក្ខខណ្ឌនៃការចោទប្រកាន់

ក្រោយពីទទួលបណ្ដឹងទាមទារ ឬបណ្ដឹងបរិហារពីជនណាម្នាក់ ឬទទួលរបាយការណ៍ ពីមន្ត្រីនគរបាលយុត្តិធម៌ អយ្យការអាចមិនទាន់ធ្វើការចោទប្រកាន់ ប្រសិនបើយល់ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់នៅឡើយ។ អយ្យការអាចឱ្យមន្ត្រីនគរបាលយុត្តិធម៌ស្វែងរកភស្តុតាងបន្ថែម ឬបើកការស៊ើបអង្កេតបឋមបាន[28]។ ដោយសម្អាងថា ព្រះរាជអាជ្ញា ជាម្ចាស់នៃបណ្ដឹងអាជ្ញាគាត់អាចទទួលពាក្យបណ្ដឹងព្រហ្មទណ្ឌណាមួយបាន។ ពាក្យបណ្ដឹងអាចធ្វើឡើងដោយជនរងគ្រោះសាច់ញាតិរបស់ជនរងគ្រោះ ឬមន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីផ្សេងទៀត ដែលមានសមត្ថកិច្ច ចាត់ការក្នុងរឿងព្រហ្មទណ្ឌ ដូចជា មន្ត្រីគយ មន្ត្រីពន្ធដា មន្ត្រីជលផល ឬក៏តតិយជនដែលបានដឹងឮ ពីបទល្មើស ឧក្រិដ្ឋ ឬ បទមជ្ឈិមណាមួយ។

## ផ្នែកទី១៖ ការពិនិត្យនៅលើកាលានុវត្តភាពនៃការចោទប្រកាន់

ក្រមនីតិវិធីព្រហ្មទណ្ឌ បានជ្រើសរើសយកគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ពុំមែនគោលការណ៍នីត្យានុកូលភាព នៃការចោទប្រកាន់ដូចក្នុងនីតិវិធីព្រហ្មទណ្ឌចាស់ឡើយ។ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌ បច្ចុប្បន្នរបស់កម្ពុជា យកមកប្រើប្រាស់សម្រាប់ឱ្យអង្គការអយ្យការធ្វើការពិចារណាមុននឹងធ្វើចំណាត់ការនីតិវិធី។ នៅក្នុងគោលការណ៍នេះ បានធ្វើឱ្យព្រះរាជអាជ្ញាក្លាយទៅជានិយ័តករសង្គមមួយយ៉ាងពិតប្រាកដ ដែលមានសិទ្ធិសម្រេចដោយធ្វើការថ្លឹងថ្លែងមុននឹងសម្រេចថា "ចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ"។ ជាក់ស្ដែង ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានកំណត់ថា ៖ **ព្រះរាជអាជ្ញា អាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ**[29]។ បទបញ្ញត្តិនេះ ជាបញ្ញត្តិគោល ដែលនាំឱ្យមានការបកស្រាយថា ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាន់យកគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។

វាគឺជាគោលការណ៍មួយក្នុងនីតិវិធីព្រហ្មទណ្ឌដែលផ្ដល់សិទ្ធិអំណាចដល់ព្រះរាជអាជ្ញា ធ្វើការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្ដឹង និងពាក្យបណ្ដឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលបញ្ជូនមក ដើម្បីសម្រេចថាតើគួរតែតម្កល់រឿងទុកឥតចាត់ការ ឬគួរធ្វើការចោទប្រកាន់ទៅលើជនណាម្នាក់ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ដែលគេអាចហៅបានថាជា ជម្រើសនៃការចោទប្រកាន់។ តាមរយៈគោលការណ៍នេះ ព្រះរាជអាជ្ញាអាចប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចមិនធ្វើ

[28] មាត្រា ៤០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[29] មាត្រា ៤០ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌណាមួយ ទោះបីជាអំពើនោះមានចែងក្នុងក្រមព្រហ្មទណ្ឌ ឬច្បាប់ផ្សេងៗទៀតក៏ដោយ។ ជាគោលការណ៍ព្រះរាជអាជ្ញាអាចពិចារណាអំពីតុល្យភាពនៃការផ្តន្ទាទោស និងទំហំនៃព្យសនកម្ម (ការខូចខាត) របស់ជនរងគ្រោះ និងសង្គមជាតិទាំងមូលត្រូវទទួលរង។

**១. សេរីភាពក្នុងការសម្រេចរបស់ព្រះរាជអាជ្ញា**

ជាគោលការណ៍ ព្រះរាជអាជ្ញាមានសេរីភាពពេញលេញក្នុងការសម្រេចពីការចោទប្រកាន់ ឬ មិនចោទប្រកាន់។ ប៉ុន្តែ ដោយហេតុថា ព្រះរាជអាជ្ញាស្ថិតក្នុងអង្គដែលមានឋានានុក្រម ដូច្នេះ ព្រះរាជអាជ្ញាត្រូវធ្វើតាមបង្គាប់របស់ថ្នាក់លើ តាមឋានានុក្រមរបស់ខ្លួនដែលបង្គាប់បញ្ជាឱ្យធ្វើការចោទប្រកាន់ លើបទល្មើសអ្វីមួយ បើទោះបីជាព្រះរាជអាជ្ញាខ្លួនឯងយល់ឃើញថា ពុំត្រូវចោទប្រកាន់ក៏ដោយ។ គួរធ្វើការកត់សម្គាល់ផងដែរថា មានតែបញ្ជាឱ្យចោទប្រកាន់តែប៉ុណ្ណោះដែលព្រះរាជអាជ្ញាត្រូវតែអនុវត្តតាមតែបើមានបញ្ជាមិនឱ្យមានការមិនចោទប្រកាន់ តែព្រះរាជអាជ្ញាបានចោទប្រកាន់ហើយ គឺព្រះរាជអាជ្ញាពុំអាចដកការចោទប្រកាន់បានឡើយ។

**២. សេចក្តីសម្រេចរបស់អយ្យការទាក់ទងនឹងការចោទប្រកាន់**

ក្រោយពីបានពិនិត្យឯកសារក៏ដូចជាសំណុំរឿងចប់សព្វគ្រប់ហើយ អង្គការអយ្យការត្រូវធ្វើការសម្រេចថា តើត្រូវចោទប្រកាន់ ឬមិនចោទប្រកាន់។

## ផ្នែកទី២៖ ការតម្កល់រឿងទុកឥតចាត់ការរបស់អង្គការអយ្យការ

### ១. សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ

#### ១.១. អត្ថន័យនៃការតម្កល់រឿងទុកឥតចាត់ការ

ដំណើររឿងក្តីព្រហ្មទណ្ឌនៅក្នុងសាលាដម្រះក្តីជាន់ទាបត្រូវបានបែងចែកជា ៤ (បួន)ដំណាក់កាលគឺ៖ **ដំណាក់កាលស៊ើបអង្កេត ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរ និង ដំណាក់កាលជំនុំជម្រះ**។ ដំណាក់កាលចោទប្រកាន់ គឺជាដំណាក់កាលមួយដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ស្ថាប័នអង្គការអយ្យការដែលជាម្ចាស់នៃបណ្តឹងអាជ្ញា ដែលអាចសម្រេចចោទប្រកាន់ និងបញ្ជូនសំណុំរឿងទៅយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ដើម្បីធ្វើចំណាត់ការបន្ត។ ក្រៅពីការចោទប្រកាន់ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ក៏បានផ្តល់អំណាចដល់អង្គការអយ្យការគឺ **ការតម្កល់រឿងទុកឥតចាត់ការ** (ការសម្រេចមិនចោទប្រកាន់)។ ការតម្កល់រឿងទុកឥតចាត់ការនេះ គឺជានីតិវិធីមួយដែលកើតចេញពីគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។ ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។[30] តាមខ្លឹមសារនេះ មានន័យថា ព្រះរាជអាជ្ញាអាចធ្វើការសម្រេចចោទប្រកាន់ផង និងតម្កល់រឿងទុកឥតចាត់ការ

[30] មាត្រា ៤០ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ផង ចំពោះបទល្មើសព្រហ្មទណ្ឌ។ ដូចនេះមានន័យថា ព្រះរាជអាជ្ញា អាចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះអំពើ ២ (ពីរ)គឺ៖

- អំពើដែលមិនមែនជាបទល្មើស
- អំពើដែលជាបទល្មើស។

ដោយការផ្តល់អំណាចសម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើសដល់ព្រះរាជអាជ្ញានេះ គឺហៅថា គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។ តាមរយៈគោលការណ៍នេះ គឺបានផ្តល់នូវអំណាចឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែងថា គួរចោទប្រកាន់ ឬមិនចោទប្រកាន់ចំពោះអំពើដែលជាបទល្មើសព្រហ្មទណ្ឌ។

តាមរយៈគោលការណ៍នេះទៀតសោត ក៏បានលេចចេញជាសំណួរមួយថា៖ តើហេតុអ្វីបានជាច្បាប់ផ្តល់អំណាចដល់ព្រះរាជអាជ្ញាក្នុងការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើសព្រហ្មទណ្ឌទៅវិញ? ហេតុអ្វីមិនធ្វើការចោទប្រកាន់ ព្រោះវាជាបទល្មើស? ដូច្នេះ យើងខ្ញុំនឹងបកស្រាយសំណួរនេះ នៅក្នុងចំណុច (២). **មូលហេតុដែលនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការ។**

### ១.២. អាជ្ញាធរទទួលបន្ទុកក្នុងការតម្កល់រឿងទុកឥតចាត់ការ

អាជ្ញាធរទទួលបន្ទុកក្នុងការតម្កល់រឿងទុកឥតចាត់ការ សំដៅដល់អ្នកមានសមត្ថកិច្ចអាចធ្វើការតម្កល់រឿងទុកឥតចាត់ការ។ ដោយអ្នកមានសមត្ថកិច្ចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការមាន៖

- ព្រះរាជអាជ្ញា [31]
- ព្រះរាជអាជ្ញារង[32]។

## ២. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

ផ្អែកលើមូលដ្ឋាននៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មិនបានអះអាងអំពីមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការនោះទេ គ្រាន់តែបានកំណត់ថា ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ[33]។ នេះសបញ្ជាក់ថា ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ហាក់សង្កត់ធ្ងន់លើនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការជាជាងប្រាប់ពីមូលហេតុរបស់វា។

[31] មាត្រា ៤០ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[32] មាត្រា ៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ និង មាត្រា ៧៥ កថាខណ្ឌទី១ ចំណុចទី២ (គោលការណ៍អវិភាគ) នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[33] មាត្រា ៤០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ព្រះរាជអាជ្ញាអាចធ្វើការតម្កល់រឿងទុកឥតចាត់ការចំពោះ**អំពើដែលមិនមែនជាបទល្មើសផង** និង **អំពើដែលជាបទល្មើសផង**។ ដូចនេះ យើងធ្វើការបែងចែកមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការជា ២ (ពីរ) ករណី៖

- ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលមិនមែនជាបទល្មើស
- ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើស។

### ២.១. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលមិនមែនជាបទល្មើស

បទល្មើស សំដៅដល់អំពើខ្លះរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កចលាចលដល់សង្គម[34]។ ហើយបើយោងតាម គោលការណ៍នីត្យានុកូលភាពនៃបទល្មើស អំពើមួយត្រូវបានចាត់ទុកថាជាបទល្មើស លុះត្រាតែមានបញ្ញត្តិក្នុងច្បាប់ជាធរមាន[35]។ ដូចនេះ អំពើដែលមិនមែនជាបទល្មើស សំដៅដល់អំពើដែលច្បាប់មិនបានបញ្ញត្តិថាជាបទល្មើស។

តាមសញ្ញាណនៃការបកស្រាយខាងលើ យើងអាចទាញបាននូវមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលមិនមែនជាបទល្មើសជា ២ (ពីរ) ករណី៖

#### ករណីទី១. កង្វះធាតុផ្សំនៃបទល្មើស

អំពើមួយត្រូវបានចាត់ទុកថាជាបទល្មើស លុះត្រាតែមានធាតុផ្សំ ៣ (បី) គឺ៖

- ធាតុផ្សំនីត្យានុកូល (ធាតុច្បាប់)
- ធាតុផ្សំសត្យានុម័ត (ធាតុផ្សំសម្ភារៈ)
- ធាតុផ្សំអត្តនោម័ត (ធាតុផ្សំចិត្តសាស្ត្រ)

ដូចនេះ ប្រសិនបើមានកង្វះនូវធាតុផ្សំណាមួយនោះ តំណាងអយ្យការនឹងសម្រេចតម្កល់រឿងទុកឥតចាត់ការ។

#### ករណីទី២. អវត្តមាននៃបទល្មើស

រាល់អំពើដែលបង្កព្យសនកម្មទាំងអស់ មិនមែនសុទ្ធតែជាបទល្មើសព្រហ្មទណ្ឌនោះទេ។ អវត្តមាននៃបទល្មើស សំដៅដល់សំណុំរឿងទាំងឡាយណា ពុំមានបទល្មើសព្រហ្មទណ្ឌ ហើយដែលមិនមែនជាប្រភេទរឿងក្តីព្រហ្មទណ្ឌ។ ឧទាហរណ៍ សំណុំរឿងក្តីរដ្ឋប្បវេណី។ ដូចនេះ ប្រសិនបើរឿងក្តីមិនមែនជារឿងក្តីព្រហ្មទណ្ឌ តំណាងអយ្យការនឹងសម្រេចតម្កល់រឿងទុកឥតចាត់ការ។

---

[34] មាត្រា ២ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[35] មាត្រា ៣ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

### ២.២. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើស

ដូចដែលបានបកស្រាយនៅក្នុងចំណុចខាងលើ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ បានអនុញ្ញាតដល់តំណាងអយ្យការក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីសម្រេចថា គួរចោទប្រកាន់ ឬមិនចោទប្រកាន់ចំពោះអំពើដែលជាបទល្មើសព្រហ្មទណ្ឌ។ គោលគំនិតនៃការបង្កើតនូវគោលការណ៍នេះ គឺដោយយល់ឃើញថា ចំពោះអំពើមួយចំនួនថ្វីត្បិតតែច្បាប់បានកំណត់ថាជាបទល្មើសក៏ពិតមែន ប៉ុន្តែកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ហេតុ និងបច្ច័យដែលទាក់ទងនឹងបទល្មើសខ្លះ មិនបានបង្កព្យសនកម្មធ្ងន់ធ្ងរ និងភាពរឹកររដល់សង្គមនោះទេ ហេតុនេះប្រសិនបើធ្វើការចោទប្រកាន់ហាក់មិនបានផ្តល់ផលប្រយោជន៍អ្វី ហើយដូចជាបន្ថែមបន្ទុកទៅលើសង្គមទៅវិញ។ *ឧទាហរណ៍៖ ស្ត្រីមេម៉ាយក្រីក្រម្នាក់ មានកូនតូចៗក្នុងបន្ទុក ៤ នាក់ ដោយសារតែឃ្លានពេក ក៏បានសម្រេចចិត្តលួចនំប៉័ងមួយដើមនៅក្នុងហាងមួយកន្លែង។*

តាមអង្គហេតុខាងលើនេះ ស្ត្រីម្នាក់នេះបានប្រព្រឹត្តបទល្មើសលួច ប៉ុន្តែបើយើងពិនិត្យ ទៅលើហេតុ និងបច្ច័យដែលទាក់ទងនឹងការប្រព្រឹត្តបទល្មើសនេះវិញ គឺដោយសារតែឃ្លានពេក( ដើម្បីជីវិតរស់នៅបានចិញ្ចឹមកូន) ហើយព្យសនកម្មក៏មានលក្ខណៈតិចតួចមែនទែន។

ប្រសិនបើសម្រេចចោទប្រកាន់ វានឹងផ្តល់ផលប៉ះពាល់ដល់សង្គមជាច្រើនដូចជា៖ កូនៗត្រូវក្លាយជាកុមារកំព្រា ពុំមានអ្នកទំនុកបម្រុង បង្កើតការកកស្ទះសំណុំរឿងនៅតាមតុលាការ ប៉ះពាល់ដល់សេដ្ឋកិច្ចជាតិដោយសារការចំណាយលើទណ្ឌិតនៅក្នុងពន្ធនាគារ។ ដូចនេះ ការតម្កល់រឿងទុកឥតចាត់ការ គឺជារឿងដែលសមហេតុផលបំផុត។ ក្រៅពីការបកស្រាយនៅក្នុងអង្គហេតុខាងលើ នៅមានមូលហេតុផ្សេងទៀតជាច្រើនដែលនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការចំពោះ អំពើដែលជាបទល្មើសព្រហ្មទណ្ឌ។

តាមការសិក្សាលើបទដ្ឋានគតិយុត្ត យើងអាចកំណត់បាននូវមូលហេតុដែលនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើសជាពីរផ្នែកគឺ៖

**ក. <u>មូលហេតុគតិយុត្ត</u>**

មូលហេតុគតិយុត្ត សំដៅដល់មូលហេតុច្បាប់ទាំងឡាយណាដែលបានបញ្ញត្តិរាំងតំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់ចំពោះអំពើដែលជាបទល្មើសនោះបាន។

- **អភ័យឯកសិទ្ធិ**

បុគ្គលដែលមានអភ័យឯកសិទ្ធិមួយចំនួនច្បាប់បញ្ញត្តិឱ្យរួចផុតពីការចោទប្រកាន់ សិទ្ធិពិសេសដែលច្បាប់ផ្តល់ឱ្យ[36]។ ទោះបីជា អត្ថិភាពនៃបទល្មើសត្រូវបានរកឃើញក៏ពិតមែន ប៉ុន្តែលក្ខខណ្ឌនៃការចោទប្រកាន់

[36] មាត្រា ៣៥៥ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

នៅតែមិនអាចធ្វើទៅបាន ដោយហេតុផលថា បុគ្គលដែលបានប្រព្រឹត្តបទល្មើសជាបុគ្គលដែលត្រូវបានការពារដោយអភ័យឯកសិទ្ធិពិសេសជាអាទិ៍ **អភ័យឯកសិទ្ធិ ព្រះមហាក្សត្រមហាក្សត្រីយ៍ អភ័យឯកសិទ្ធិរដ្ឋសភា អភ័យឯកសិទ្ធិព្រឹទ្ធសភា** និង**អភ័យឯកសិទ្ធិការទូត**។ បុគ្គលដូចបានរៀបរាប់ខាងលើនេះ មិនអាចត្រូវបានគេចោទប្រកាន់ ក្នុងពេលដែលខ្លួនអនុវត្តតួនាទីរបស់ខ្លួនបានឡើយ។

- **អនិយ័តភាពនៃកិច្ចនីតិវិធី**

សំដៅដល់ភាពមិនត្រឹមត្រូវតាមច្បាប់នៃការអនុវត្តកិច្ចនីតិវិធីនៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌[37]។

- **ការផុតរលត់នៃបណ្ដឹងអាជ្ញា**[38]

– មរណភាពនៃជនល្មើស

ប្រសិនជនល្មើសទទួលមរណភាពមុនពេលបណ្ដឹងអាជ្ញា ឬស្លាប់មុនពេលមានសេចក្ដីសម្រេចផ្ដន្ទាទោសជនល្មើស បណ្ដឹងអាជ្ញាត្រូវរលត់។ ជនល្មើសគឺជាប្រធាននៃបទល្មើសដែលនាំឱ្យមានការបង្កជាព្យសនកម្មនិងកម្រិតគ្រោះថ្នាក់ដល់សង្គមដែលតម្រូវឱ្យតំណាងអយ្យការធ្វើការចោទប្រកាន់ ហើយសុំឱ្យតុលាការផ្ដន្ទាទោសចំពោះអំពើល្មើសនោះ។ ប៉ុន្តែក្នុងករណីដែលជនល្មើសពុំមានវត្តមាននៅលើលោកនេះទេ (បានស្លាប់) តំណាងអយ្យការពុំចាំបាច់ធ្វើការចោទប្រកាន់ទេ ព្រោះការចោទប្រកាន់នេះដើម្បីធ្វើការអប់រំជនល្មើសឱ្យឈប់ប្រព្រឹត្តអំពើមិនល្អហើយអាចរស់នៅក្នុងសង្គមសារជាថ្មី មិនមែនជាការដាក់ទណ្ឌកម្មដើម្បីសងសឹកលើអំពើល្មើសដែលគេបានធ្វើឡើយ។

– ការលើកលែងទោសជាទូទៅ

ដោយផ្អែកតាមច្បាប់ស្តីពីការលើកលែងទោសជាទូទៅនិងមានកំណត់ក្នុងរដ្ឋធម្មនុញ្ញផងដែរនោះបានតម្រូវអោយមានមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល (មាត្រា ៩០ ថ្មីនៃរដ្ឋធម្មនុញ្ញ)។ មានន័យថាទោះបីអំពើខ្លះជាបទល្មើសក៏ដោយ តំណាងអយ្យការពុំចាំបាច់ធ្វើការចោទប្រកាន់ ឬ បញ្ឈប់ការចោទប្រកាន់ ឬបញ្ឈប់ការអនុវត្តទោសបើរដ្ឋសភាបានអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ។

– ការផុតអាជ្ញាយុកាល

[37] មាត្រា ៩១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[38] មាត្រា ៧ និង មាត្រា ៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ជារយៈពេលមួយកំណត់ដោយច្បាប់ ដែលផុតរយៈពេលនេះ ព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់បានទេ ប្រសិនបើផុតថិរវេលាដែលច្បាប់បានកំណត់ហើយតំណាងអយ្យការពុំអាចធ្វើការចោទប្រកាន់បានទេ។ អាជ្ញាយុកាលនៃបទល្មើស ចាប់ផ្តើមគិតពីថ្ងៃដែលបានប្រព្រឹត្តបទល្មើសតទៅៈ

- ១៥ ( ដប់ប្រាំ ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ ( ប្រាំ ) ឆ្នាំ ចំពោះបទមជ្ឈិម
- ១ ( មួយ ) ឆ្នាំ ចំពោះបទលហុ [39]

ប៉ុន្តែអាជ្ញាយុកាលមិនផុតរលត់ឡើយចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម[40]។

– និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

គឺជាការលុបចោលនូវបទល្មើសណាមួយដែលច្បាប់បានកំណត់ ឬត្រូវបាននិរាករណ៍នៅពេលដែលច្បាប់ថ្មីចូលជាធរមាន។ ការនិរាករណ៍ធ្វើអោយអំពើល្មើសពុំត្រូវបានធ្វើការចោទប្រកាន់ ឬការអនុវត្តទោសត្រូវបានបញ្ចប់។

– អាជ្ញាអស់ជំនុំ

គោលការណ៍អាជ្ញាអស់ជំនុំ ឬគោលការណ៍ដែលពុំអាចជម្រះក្តីពីរដងលើរឿងក្តីតែមួយ ទោះបីមានការកំណត់ឈ្មោះបទល្មើសថ្មីក៏ដោយ បើជនល្មើសត្រូវបានតុលាការផ្តន្ទាទោស ឬការលើកលែងទោសជាស្ថាពរនោះពុំអាចធ្វើការចោទប្រកាន់បានទេ ដើម្បីមានការធានាសិទ្ធិពលរដ្ឋនិងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋទៅលើតុលាការ។

– ការសម្របសម្រួលជាមួយរដ្ឋ

ជាគោលការណ៍បណ្តឹងអាជ្ញាពុំអាចអនុញ្ញាតឱ្យមាន ការបញ្ឈប់តាមតែទំនើងចិត្តបានទេ លើកលែងតែមានការកំណត់ពីច្បាប់ជាពិសេស។ ជាឧទាហរណ៍ ចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្ត ឬផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិម ស្រាល ឬបទលហុ ការផ្សះផ្សាឬសម្រុះសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីទាំងសងខាង[41]។

– ការដកពាក្យប្តឹង

[39] មាត្រា ១០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[40] មាត្រា ៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[41] មាត្រា ២៦ ស្តីពីច្បាប់ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

ជនរងគ្រោះអាចធ្វើការដកពាក្យប្តឹង ចំពោះបទល្មើសមួយចំនួន ដែលជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ។ លក្ខខណ្ឌនៃការចោទប្រកាន់នោះ មានជាអាទិ៍ អំពើហិង្សាក្នុងគ្រួសារដែលសហព័ទ្ធជាជនរងគ្រោះអាចដកពាក្យប្តឹង ហើយតំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់បានឡើយ[42]។

– ការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល

ករណីនេះគេសង្កេតឃើញ ភាគច្រើនចំពោះការអនុវត្តលើបទល្មើសចរាចរណ៍ ដោយភាគីជនរងគ្រោះទទួលបានសំណង សមរម្យដោយការបង់ប្រាក់សម្របសម្រួល ហើយខ្លួនដាក់សំណើដើម្បីកុំឱ្យមានការចោទប្រកាន់ណាមួយ ។

- **ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ**

– វិបល្លាសស្មារតី

កត្តាដែលនាំឱ្យជនល្មើសពុំអាចយល់ដឹងពីលទ្ធផលនៃអំពើដែល ខ្លួនបានប្រព្រឹត្តថាជាបទល្មើស។ ប៉ុន្តែបញ្ហាស្មារតីដែលនាំឱ្យមានការអោនថយការយល់ដឹងពីទង្វើដែលប្រព្រឹត្តឡើងដោយការសេពគ្រឿងស្រវឹង ការសេពគ្រឿងញៀនជាអាទិ៍ ពុំមែនជាលេសដែល អាចរួចផុតពីការចោទប្រកាន់នោះឡើយ។

– ការអនុញ្ញាតដោយច្បាប់ឬអាជ្ញាធរ

អំពើខ្លះទោះបីជាការប្រព្រឹត្តស្តែងចេញ ជាបទល្មើសយ៉ាងណាក្តីតែបើស្ថិតក្នុងការអនុញ្ញាតដោយបទបញ្ញត្តិនានាឬតាមការបញ្ជារបស់អាជ្ញាធរអំពើនោះត្រូវរួចផុតពីការចោទប្រកាន់។

– ការការពារស្របច្បាប់

ជាកិច្ចការពារជាធម្មានរូបដើម្បីរួចផុតពីការរំលោភបំពាន។ តែចំណុចនេះមានការកម្រិតនូវលក្ខខណ្ឌជាអាទិ៍៖ បទល្មើសត្រូវចាត់ទុកជាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និងគ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន[43]។

– ជាការសន្មត់ដូចការការពារស្របច្បាប់ក្នុងករណី៖

[42] មាត្រា ៣៦ ស្តីពីច្បាប់ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

[43] មាត្រា ៣៣ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

បទល្មើលត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ។ បទល្មើលបានប្រព្រឹត្ត ដើម្បីការពារខ្លួន ប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា[44]។

– ស្ថានភាពចាំបាច់

ភាពជាការចាំបាច់ដែលត្រូវតែប្រព្រឹត្តបទល្មើស ដែលមានលក្ខខណ្ឌពីរដូចតទៅៈ បទល្មើសត្រូវបាន ចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និងគ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់[45]។

– អានុភាពនៃកម្លាំង ឬការបង្ខំ

គឺត្រូវតែជាព្រឹត្តិការណ៍ក្រៅឆន្ទៈ របស់មនុស្សហើយត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន។ ប៉ុន្តែក្នុងករណីដែលបុគ្គលប្រព្រឹត្តបទល្មើសមានគោលបំណងឱ្យកើតមានឡើង នោះវាស្ថិតក្នុងឆន្ទៈរបស់ខ្លួន។ ដូចនេះ ប្រសិនបើបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តបទល្មើសដោយសារតែស្ថានភាពកម្លាំងឬ ការបង្ខំ ហើយដែលខ្លួនពុំអាចទប់ទល់បាននោះគេមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ។

– អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ

ចំពោះជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ ឬហៅបានថានីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ[46]។ ទោះជាយ៉ាងនេះក្តី ពុំមានន័យថាអនីតិជនត្រូវរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ គឺជាអញ្ញត្រកម្មច្បាប់បានកំណត់ឱ្យមានជាវិធានការអនុវត្តចំពោះអនីតិជនដែល មានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅដែលបានប្រព្រឹត្តបទល្មើស ដែលស្ថិតក្រោមវិធានការតាមដានវិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ [47]។

### ខ. ការចោទប្រកាន់មិនផ្តល់ប្រយោជន៍

ការចោទប្រកាន់មិនផ្តល់ប្រយោជន៍ សំដៅដល់ការថ្លឹងថ្លែងរបស់តំណាងអយ្យការលើស្ថានភាពនានាដែលពាក់ព័ន្ធបទល្មើស ចារី ជនរងគ្រោះ ជាអាទិ៍ហើយរកឃើញថា ប្រសិនបើចោទប្រកាន់ ហាក់មិនបានផ្តល់ផលអ្វីសោះដល់សង្គមនិងផ្ទុយពីគោលបំណងនៃបណ្តឹងអាជ្ញា។

[44] មាត្រា ៣៤ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[45] មាត្រា ៣៥ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[46] មាត្រា ៣៨ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[47] មាត្រា ៣៩ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

មូលហេតុដែលនាំឱ្យការចោទប្រកាន់មិនផ្តល់ប្រយោជន៍ អាចបណ្តាលមកពីកត្តាផ្សេងៗដូចជាៈ កត្តាចំណាត់ការ កត្តាចារី កត្តាជនរងគ្រោះ កត្តាព្យសនកម្ម ជាអាទិ៍។

- ✓ ខ.១) កត្តាចំណាត់ការៈ ក្នុងស្ថានភាពខ្លះការចោទប្រកាន់ហាក់មិនបានផលដោយសារ ការស៊ើបអង្កេតមិនបានផល អូសបន្លាយពេលវេលាយូរជាអាទិ៍។
- ✓ ខ.២) កត្តាចារីៈ ចារីប្រព្រឹត្តបទល្មើសក្នុងស្ថានភាពមួយចាំបាច់ ចារីមានអាកប្បកិរិយាទទួលស្គាល់កំហុស បញ្ហាបន្ទុកគ្រួសារ។
- ✓ ខ.៣) កត្តាជនរងគ្រោះៈ ការបោះបង់ពាក្យបណ្តឹង ការមិនអើពើនឹងអំពើល្មើស ការខកខាននីតិវិធី។
- ✓ ខ.៤) កត្តាព្យសនកម្មៈ ព្យសនកម្មមានលក្ខណៈតិចតួច ព្យសនកម្មដែលកើតចេញពីអំពើល្មើសត្រូវបានប៉ះប៉ូវ។

ក្រៅពីកត្តាខាងលើ នៅមានមូលហេតុជាក់ស្តែងជាច្រើនទៀតដែលធ្វើឱ្យការចោទប្រកាន់មិនផ្តល់ប្រយោជន៍ ដែលនាំឱ្យព្រះរាជអាជ្ញាថ្លឹងថ្លែងលើការសម្រេចតម្កល់រឿងទុកឥតចាត់ការ។

គួរកត់សម្គាល់ផងដែរថាៈ ថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើសតាមរយៈការថ្លឹងថ្លែងរបស់ខ្លួន ប៉ុន្តែការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះត្រូវតែមានសំអាងច្បាប់ និងសំអាងហេតុ[48]។ មានន័យថា ត្រូវតែមានអំណះអំណាងគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការចេញសេចក្តីសម្រេចរបស់ខ្លួន។

## ៣. នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

### ៣.១. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

នៅពេលដែលព្រះរាជអាជ្ញាទទួលបានពាក្យបណ្តឹង ឬពាក្យបរិហារ គាត់នឹងធ្វើចំណាត់ការលើពាក្យបណ្តឹងនោះដោយ ធ្វើការថ្លឹងថ្លែងទៅលើមូលដ្ឋាននៃអង្គហេតុដែលបានបំពេញនូវធាតុផ្សំគួរដល់ការចោទប្រកាន់ ឬមិនចោទប្រកាន់។ ប្រសិនបើ ព្រះរាជអាជ្ញាសម្រេចមិនចោទប្រកាន់ទៅលើពាក្យបណ្តឹងដែលខ្លួនបានទទួលនោះ គាត់នឹងធ្វើដីកាសម្រេចមួយដែលហៅថា **ដីកាតម្កល់រឿងទុកឥតចាត់ការ**។ ស្របតាមការសម្រេចនេះ ព្រះរាជអាជ្ញា ត្រូវចុះនិទ្ទេសលើបណ្តឹង ឬកំណត់ហេតុព្រមទាំងលើបញ្ជីចុះបណ្តឹង។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងទៅដើមបណ្តឹងរដ្ឋប្បវេណីអំពីសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេល ២ (ពីរ)ខែ យ៉ាងយូរចាប់តាំងពីថ្ងៃទទួលពាក្យប្តឹង។

---

[48] មាត្រា ៤១ កថាខណ្ឌ ២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការជូនដំណឹងអំពីការតម្កល់រឿងទុកឥតចាត់ការ គឺជាលក្ខខណ្ឌចាំបាច់មួយដែលព្រះរាជអាជ្ញាត្រូវបំពេញ ដើម្បីឱ្យអ្នកប្ដឹងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញានេះ ធ្វើការដាក់ពាក្យបណ្ដឹងតវ៉ាទៅ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញា។

ការតម្កល់រឿងទុកឥតចាត់ការ ជានីតិវិធីមួយរបស់អង្គការអយ្យការក្នុងការមិនចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ។ ការសម្រេចមិនចោទប្រកាន់អាចជាការថ្លឹងថ្លែង ប្រកបដោយភាពត្រឹមត្រូវតែក៏អាចជាភាពខុសឆ្គង លើការសម្រេចមិនចោទប្រកាន់ខាងបទព្រហ្មទណ្ឌរបស់ព្រះរាជអាជ្ញាដែរ ដូច្នេះដើម្បីធានាថា ទោះជាមានការតម្កល់រឿងទុកឥតចាត់ការយ៉ាងណាក៏ដោយ ក៏ត្រូវយកមកដោះស្រាយដោយនីតិវិធីផ្សេងៗលើចំណាត់ការបែបនេះ។ ការជៀសវាងហានិភ័យកម្រិតខ្ពស់សម្រាប់សង្គម ក្នុងការការពារជូនប្រយោជន៍ជាចាំបាច់របស់ជនរងគ្រោះ និងសង្គមក៏មិនមានន័យថាការចោទប្រកាន់មិនអាចធ្វើបាននោះទេ។ ការកំណត់នីតិវិធីសម្រាប់ឧបសគ្គនេះទោះជានាំឱ្យស្ថាប័នអយ្យការ បាត់បង់នូវឯករាជ្យភាពរបស់ខ្លួនមួយផ្នែកក្នុងការអនុវត្តន៍ច្បាប់ក៏ដោយ ឬក៏វាមិនមានការប៉ះពាល់ដល់សង្គម ឬហុចផលវិបត្តិដល់ស្មារតីយុត្តិធម៌ ព្រោះជាទូទៅការចោទប្រកាន់មិនមែនជាការដាក់ទណ្ឌកម្មនោះទេ គ្រាន់តែជាការប្ដឹងទៅតុលាការ និងដើម្បីឱ្យយុត្តាធិការជំនុំជម្រះកំណត់អំពីពិរុទ្ធភាពកើតមានចំពោះជននោះតែប៉ុណ្ណោះ។

### ៣.២. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ចំពោះអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការត្រូវបានបញ្ញត្តិក្នុងមាត្រា ៤១ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យគ្មានអាជ្ញាអស់ជំនុំទេ។ តាមគោលការណ៍អាជ្ញាអស់ជំនុំជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែលទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។[49] ដូចនេះ ការតម្កល់រឿងទុកឥតចាត់ការពុំបង្កើតអាជ្ញាអស់ជំនុំទេ នោះមានន័យថាតំណាងអយ្យការអាចធ្វើការចោទប្រកាន់ឡើងវិញនៅពេលក្រោយបានទោះបីបានធ្វើការតម្កល់រឿងទុកឥតចាត់ការរួចហើយក៏ដោយ។

## ៤. យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ

យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ សំដៅដល់នីតិវិធីទាំងឡាយដែលធ្វើឡើងដើម្បីនាំឱ្យមានការចោទប្រកាន់ឡើងវិញ បន្ទាប់ពីមានការតម្កល់រឿងទុកឥតចាត់ការ។

[49] មាត្រា ១២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

តាមរយៈបញ្ញត្តិនានា នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការមានចំនួន ៤ (បួន) គឺៈ

**៤.១. ការសើរើកែប្រែសេចក្តីសម្រេចរបស់តំណាងអយ្យការ**

តាមបញ្ញត្តិនៃ មាត្រា៤១ ការតម្កល់រឿងទុកឥតចាត់ការពុំបង្កើតអានុភាពអាជ្ញាអស់ជំនុំនោះទេ ហើយតំណាងអយ្យការអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញបាន ក្នុងខណៈដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ[50]។ ក្នុងករណីខាងលើ នៅពេលដែលមានលេចចេញនូវអង្គហេតុ ឬភស្តុតាងថ្មីណាមួយដែលនាំឱ្យតំណាងអយ្យការអាចកំណត់បានសញ្ញាណថ្មី និងមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការចោទប្រកាន់ នោះតំណាងអយ្យការអាចសើរើកែប្រែពីការតម្កល់រឿងទុកឥតចាត់ការមកធ្វើការចោទប្រកាន់ឡើងវិញបាន ប៉ុន្តែស្ថិតក្នុងលក្ខខណ្ឌដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់ប៉ុណ្ណោះ។

**៤.២. ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**

ប្រសិនបើអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ អាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន។ ការតវ៉ានេះត្រូវធ្វើនៅក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីការតម្កល់រឿងទុកឥតចាត់ការ។ ការតវ៉ាធ្វើឡើងតាមបណ្តឹងសាមញ្ញ ដាក់នៅអង្គការអយ្យការដែលចេញសេចក្តីសម្រេច។ បន្ទាប់មកសំណុំរឿងត្រូវបញ្ជូនភ្លាមទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

ប្រសិនបើការតវ៉ាមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចេញអធិបញ្ជាជាលាយលក្ខណ៍អក្សរដាក់បញ្ចូលក្នុងសំណុំរឿង ហើយបញ្ជូនមកឱ្យព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់វិញ។ ប៉ុន្តែប្រសិនបើការតវ៉ាមិនមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តម្កល់សេចក្តីសម្រេចរបស់តំណាងអយ្យការអមសាលាដំបូងទុកជាបានការរួចជូនដំណឹងដល់អ្នកប្តឹងតវ៉ា[51]។

**៤.៣. ការធ្វើអធិបញ្ញាតាមឋានានុក្រមនៃអង្គការអយ្យការ**

គោលការណ៍ឯកភាពបានចែងអំពីការធ្វើអធិបញ្ញាឱ្យធ្វើការចោទប្រកាន់ឡើងវិញតាមឋានានុក្រមដែលមានដូចជា[52]៖

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

[50] មាត្រា ៤១ កថាខណ្ឌទី៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[51] មាត្រា ៤១ កថាខណ្ឌទី ៤ , ៥ និង ៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[52] មាត្រា ២៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ និង មាត្រា ៧៥ កថាខណ្ឌទី ១ នៃច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

– ព្រះរាជអាជ្ញាអមសាលាដំបូង

កត់សម្គាល់ផងដែរថា៖ ការធ្វើអធិបញ្ញា គឺដើម្បីឱ្យធ្វើការចោទប្រកាន់ មិនអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបាននោះទេ។

### ៤.៤. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ។ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរអំពីបណ្តឹងអាជ្ញា។ នៅពេលបានទទួលបណ្តឹង ចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់ដោយដីកា រួចបញ្ជូនបណ្តឹងទៅតំណាងអយ្យការ។ ក្រោយពីបានឃើញពាក្យប្តឹង តំណាងអយ្យការត្រូវប្តឹងទៅចៅក្រមស៊ើបសួរតាម ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរបានផងដែរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬអំពើនោះមិនមែនជាបទល្មើស។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចតាមការសុំរបស់ព្រះរាជអាជ្ញាទេចៅក្រមស៊ើបសួរអាចសម្រេចដោយឯករាជ្យគឺ៖

- សម្រេចមិនស៊ើបសួរ៖ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។
- សម្រេចស៊ើបសួរ៖ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុហើយត្រូវជូនដំណឹងជាបន្ទាន់ដល់តំណាងអយ្យការ [53]។

## ៥. ផលវិបាកនៃនីតិវិធីតម្កល់រឿងទុកឥតចាត់ការចំពោះសង្គមជាតិ

ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ពិតជាមានសារៈសំខាន់ណាស់នៅក្នុងដំណើរការនៃនីតិវិធីព្រហ្មទណ្ឌ។ ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ដោយឈរលើមូលដ្ឋាននៃផលប្រយោជន៍របស់សង្គម ដើម្បីធានាថាការខូចខាតដែលបង្កឡើងដោយសារនីតិវិធីមិនកើតមាន។ ប៉ុន្តែទន្ទឹមនឹងគុណសម្បត្តិនេះ ការតម្កល់រឿងទុកឥតចាត់ការក៏បានផ្តល់នូវគុណវិបត្តិផងដែរ ដោយផ្អែកលើការកំណត់នូវមូលហេតុ និងនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការនេះ។

### ៥.១. គុណសម្បត្តិនៃការតម្កល់រឿងទុកឥតចាត់ការចំពោះសង្គម

ដោយឈរលើមូលដ្ឋាននៃប្រយោជន៍សង្គមជាតិ ការតម្កល់រឿងទុកឥតចាត់ការបានផ្តល់នូវលទ្ធផលវិជ្ជមានជាអាទិ៍៖

[53] មាត្រា ១៣៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

- ដោយសារស្ថានភាពបទល្មើសតូចតាចមួយចំនួន ដែលហុចព្យសនកម្មមានរូបភាពតូចតាចត្រូវបានជម្រុះចោលដោយការមិនចោទប្រកាន់ ហើយបានជួយសម្រាលបន្ទុកចំពោះការកកស្ទះពាក្យប្តឹងទៅតុលាការ ដោយទុកលទ្ធភាពឱ្យតុលាការយកចិត្តទុកដាក់លើបទល្មើសដែលស្តែងចេញនូវចរិតសាហាវឃោរឃៅ និងគ្រោះថ្នាក់ដល់សង្គមជាតិ ដែលនាំឱ្យការកាត់សេចក្តីប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនិងធានាបាននូវយុត្តិធម៌។
- ផ្តល់លទ្ធភាពដល់ការកសាងសង្គមជាតិ ព្រោះចំពោះបទល្មើសទាំងអស់ មិនសុទ្ធតែបានបំពានដល់ផលប្រយោជន៍របស់បុគ្គល និងសង្គមជាតិធ្ងន់ធ្ងរនោះទេ។ មនុស្ស ជាកម្លាំងចលករសម្រាប់ការអភិវឌ្ឍន៍សង្គមជាតិ ហេតុនេះហើយ បើយើងមិនចោទប្រកាន់លើអំពើនោះ វាមានន័យថាមនុស្សនៅតែអាចចូលរួមក្នុងសង្គមជាមួយគ្នា ដើម្បីការអភិវឌ្ឍជាងការដែលទុកជននោះ ក្នុងពន្ធនាគារដែលគ្មានប្រយោជន៍ ថែមទាំងបំផ្លិចបំផ្លាញថវិការជាតិទៀតផង។
- ប្រើប្រាស់ធនធានថវិការជាតិអោយមានប្រសិទ្ធភាពខ្ពស់បំផុត
- សំដៅប្រើប្រាស់ទណ្ឌកម្មខាងព្រហ្មទណ្ឌអោយមានប្រសិទ្ធភាព ស្របទៅតាមគោលបំណងនៃនីតិព្រហ្មទណ្ឌ

### ៥.២. គុណវិបត្តិនៃការតម្កល់រឿងទុកឥតចាត់ការចំពោះសង្គម

បើពិចារណាឱ្យបានកាន់តែស៊ីជម្រៅ ស្របពេលនឹងមានគុណសម្បត្តិ យើងនឹងឃើញថាការតម្កល់រឿងទុកឥតចាត់ការក៏ផ្តល់នូវគុណវិបត្តិដូចខាងក្រោម៖

ជារឿយៗការតម្កល់រឿងទុកឥតចាត់ការ ជាហេតុនាំឱ្យសង្គមសម្បូរទៅដោយបទល្មើសតូចតាចកាន់តែច្រើន ដោយសារតែជនល្មើសយល់ថា ខ្លួននឹងមិនត្រូវបានចោទប្រកាន់ចំពោះទង្វើ របស់ខ្លួនទេ នោះបុគ្គលម្នាក់ៗនឹងមិនខ្លាចការផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌឡើយ។ ការកំណត់នូវទណ្ឌកម្មតាមរយៈស្មារតីនៃមាត្រានីមួយៗ គឺដើម្បីបង្ការ ឬបំភ័យមនុស្ស ថាបើកាលណាជននោះ ហ៊ានប្រព្រឹត្តនូវអំពើល្មើស ជននោះនឹងទទួលទណ្ឌកម្មដោយការចោទប្រកាន់របស់ព្រះរាជអាជ្ញាទៅតុលាការ។ មិនត្រឹមតែប៉ុណ្ណោះ វាអាចជាចំណុចចន្លោះប្រហោងនៃច្បាប់ ដែលទុកឱកាសឱ្យមន្ត្រីអនុវត្ត ទាញយកផលប្រយោជន៍ណាមួយដែលគាត់ទទួលបានពីការតម្កល់រឿងទុកឥតចាត់ការទៅវិញ។

ជារួម ការតម្កល់រឿងទុកឥតចាត់ការ វាជះឥទ្ធិពលដល់ការរីកចម្រើនរបស់សង្គមតែវាក៏ជាចំណុចអន់ថយ ក្នុងការការពារសណ្តាប់ធ្នាប់សាធារណៈផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ទន្ទឹមគ្នា ជាមួយនិងនីតិវិធីតម្កល់រឿងទុកឥតចាត់ការ ក្នុងគោលបំណងធានាការកាត់បន្ថយកម្រិតអវិជ្ជមាន ឱ្យ

កាន់តែខ្ពស់មួយកម្រិតទៀត តាមរយៈការបញ្ញត្តិនូវវិធានការដោះស្រាយនូវគុណវិបត្តិនោះដោយ បើកសិទ្ធិឱ្យមានការប្តឹងឧទ្ធរណ៍ ចំពោះដីកាតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាពីសំណាក់ ដើមបណ្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រសិនបើភាគីដើមបណ្តឹងនៅតែកើតទុក្ខមិនសុខចិត្ត នឹងដីការបស់ព្រះរាជអាជ្ញា ក្នុងការតម្កល់រឿងទុកឥតចាត់ការ។

# ជំពូកទី ៣

# ការចោទប្រកាន់

# របស់តំណាងអយ្យការ

# ជំពូកទី៣

# ការចោទប្រកាន់របស់តំណាងអយ្យការ

កាលណាអង្គហេតុដែលជាបទល្មើសត្រូវបានពិនិត្យដោយព្រះរាជអាជ្ញានូវអត្ថិភាពនៃបទល្មើសរួចមក ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចត្រូវធ្វើចំណាត់ការលើរឿងក្តីនោះភ្លាម។ ចំណាត់ការលើរឿងក្តីដែលជាបទល្មើសនេះ ត្រូវបាននីតិនិពន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌបញ្ញត្តិជាបច្ចេកស័ព្ទគតិយុត្តថា **"ជម្រើសនៃការចោទប្រកាន់"** ។ ជម្រើសនៃការចោទប្រកាន់ អាចធ្វើឡើងតាមវិធីដូចជាៈ

- **ការបញ្ជូនរឿងក្តីទៅចៅក្រមស៊ើបសួរ**
    - **ការបើកការស៊ើបសួរ**
- **ការបញ្ជូនរឿងក្តីទៅចៅក្រមជំនុំជម្រះតែម្តង**
    - **ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ**
    - **តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម**

ជម្រើសនៃការចោទប្រកាន់ បានបើកផ្លូវឱ្យព្រះរាជអាជ្ញាមានមធ្យោបាយច្រើនក្នុងការធ្វើបណ្តឹងអាជ្ញា ដោយអាស្រ័យ លើស្ថានភាពនៃសំណុំរឿង និងប្រភេទនៃបទល្មើស។

## ផ្នែកទី១ៈ សញ្ញាណទូទៅនៃការចោទប្រកាន់

### ១. អត្ថន័យនៃការចោទប្រកាន់

នៅពេលមានអំពើរំលោភបំពានណាមួយកើតឡើង ជារឿយៗយើងសង្កេតឃើញមានការដាក់ពាក្យបណ្តឹងពីសំណាក់ជនរងគ្រោះ ឬគ្រួសារជនរងគ្រោះទៅប៉ុស្តិ៍នគរបាល ឬតុលាការ។

ប្រជាជនភាគច្រើន តែងតែគិតថា ការដាក់ពាក្យបណ្តឹងនេះ គឺជាការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ព្រោះក្នុងពាក្យបណ្តឹងបានសរសេរពីអង្គហេតុ អំពើល្មើស និងការចោទប្រកាន់ទៅលើបុគ្គលដែលជាជនល្មើស។

តែជាតុពិត ការចោទប្រកាន់តាមពាក្យបណ្តឹងនេះ គឺគ្រាន់តែជាការប្រកាសប្រាប់ស្ថាប័នមានសមត្ថកិច្ចអំពីរឿងរ៉ាវដែលបានកើតឡើង និងដើម្បីឱ្យស្ថាប័នមានសមត្ថកិច្ចធ្វើចំណាត់ការតាមផ្លូវច្បាប់ប៉ុណ្ណោះ។ ពាក្យបណ្តឹងប្រភេទនេះហៅថា បណ្តឹងសាមញ្ញ។ បណ្តឹងសាមញ្ញ គ្មានអានុភាពនាំឱ្យធ្វើការចោទប្រកាន់ជាបទព្រហ្មទណ្ឌ [54]។

[54] មាត្រា ៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ត្រង់ចំណុចនេះ ក៏មានសំណួរមួយចោទសួរថា តើអ្វីទៅទើបជាការចោទប្រកាន់?

ក្នុងន័យច្បាប់ ការចោទប្រកាន់សំដៅដល់ការកំណត់អំពីអត្ថិភាពនៃបទល្មើសដោយស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋដែលកំណត់ដោយច្បាប់។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានបញ្ញត្តិថា "អយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ"។ ដូច្នេះ មានតែស្ថាប័នអយ្យការប៉ុណ្ណោះ ទើបមានសមត្ថកិច្ចកំណត់ថាអំពើណាមួយជាបទល្មើស ហើយធ្វើការចោទប្រកាន់ និងសុំឱ្យយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះធ្វើចំណាត់ការបន្ត[55]។

គួរកត់សម្គាល់ផងដែរថា ស្ថាប័នអយ្យការអនុវត្តបណ្តឹងអាជ្ញាក្នុងនាមផលប្រយោជន៍ទូទៅ ទោះបីគ្មានពាក្យបណ្តឹងពីជនរងគ្រោះ ឬប្រភពណាមួយក៏ដោយ ស្ថាប័នអយ្យការអាចធ្វើការចោទប្រកាន់គ្រប់អំពើដែលជាបទល្មើស លើកលែងករណីពិសេសដែលមានបញ្ញត្តិក្នុងច្បាប់។

## ២. អាជ្ញាធរទទួលបន្ទុកក្នុងការចោទប្រកាន់

អាជ្ញាធរទទួលបន្ទុកក្នុងការចោទប្រកាន់ សំដៅដល់អ្នកមានសមត្ថកិច្ចអាចធ្វើការចោទប្រកាន់។ អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ដូច្នេះអ្នកដែលមានសមត្ថកិច្ចធ្វើការសម្រេចចោទប្រកាន់មាន៖

- ព្រះរាជអាជ្ញា [56]
- ព្រះរាជអាជ្ញារង[57]។

(សម្គាល់៖ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូង)

មុនធ្វើការចោទប្រកាន់ទៅលើជនណាម្នាក់នោះដែលទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ ប្រាកដណាស់លុះត្រាតែបានទទួលបណ្តឹងទាមទារពីជនរងគ្រោះ អ្នកតំណាងរបស់ជនរងគ្រោះ ឬទទួលបានរបាយការណ៍ពីមន្រ្តីនគរបាលយុត្តិធម៌ ក៏ប៉ុន្តែព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់តាមពាក្យបណ្តឹងនោះភ្លាមនោះទេ ។ ព្រះរាជអាជ្ញាត្រូវធ្វើការបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែមទៀត[58]។

នៅពេលដែលមានភស្តុតាងជួនល្មមអាចជឿបានថា ជនសង្ស័យអាចនឹងប្រព្រឹត្តអំពើដែលគេប្តឹងមកនោះពិតមែន ព្រះរាជអាជ្ញានឹងចាប់ផ្តើមធ្វើការចោទប្រកាន់ ។

---

[55] មាត្រា ៤ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[56] មាត្រា ៤០ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[57] មាត្រា ៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[58] មាត្រា ៤០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្នុងករណីដែលមន្ត្រីរាជការណាម្នាក់ ត្រូវបានតុលាការធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នេះទៅប្រធានសាមីអង្គភាព ក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ [59]។ ការចាប់ផ្តើមចោទប្រកាន់ ចំពោះអនីតិជន ត្រូវជូនដំណឹងពីជនជាប់សង្ស័យទៅ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់អនីតិជននោះ ។

**៣. ប្រភេទនៃការចោទប្រកាន់**

តាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌអាចធ្វើតាមនីតិវិធី ៣ (បី) យ៉ាងគឺៈ

- ការបើកធ្វើការស៊ើបសួរ
- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ
- តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម[60]

## ផ្នែកទី២៖ ការបញ្ជូនរឿងក្តីទៅចៅក្រមស៊ើបសួរ

នៅពេលដែលព្រះរាជអាជ្ញា យល់ឃើញថា សំណុំរឿងដែលខ្លួនទទួលបាន មានភាពចាំបាច់ក្នុងការស្រាវជ្រាវបន្ថែម ដើម្បីប្រមូលភស្តុតាងឱ្យគ្រប់គ្រាន់ធួមល្មមនឹងអាចជំនុំជម្រះបាន។ ហេតុនេះ ព្រះរាជអាជ្ញាត្រូវធ្វើការបើកផ្លូវឱ្យចៅក្រមស៊ើបសួរមានសមត្ថកិច្ចស៊ើបសួរបន្ថែមជាមុនសិន។ ដើម្បីឱ្យចៅក្រមស៊ើបសួរមានសមត្ថកិច្ចបើកការស៊ើបសួរបាន លុះត្រាតែព្រះរាជអាជ្ញាធ្វើការបញ្ជូនរឿងក្តីតាមរយៈ**ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ**ជាមុនសិន។

**១. ការបើកការស៊ើបសួរ**

ការបើកការស៊ើបសួរ គឺជាការប្តឹងទៅចៅក្រមស៊ើបសួររបស់ព្រះរាជអាជ្ញា ឱ្យធ្វើការស៊ើបសួរតាមរយៈ**ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**។ ដោយព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាដីកាដែលព្រះរាជអាជ្ញាអាចប្តឹង ទៅចៅក្រមស៊ើបសួរ ឱ្យធ្វើការស៊ើបសួរលើអង្គហេតុ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវមាននិទ្ទេសដូចកំណត់ហេតុក្នុងមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមានជាអាទិ៍ៈ

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស ឧទាហរណ៍ ករណីរំលោភ ឃាតកម្ម

[59] មាត្រា ៥១ ថ្មីនៃច្បាប់ស្តីពីសហលក្ខខន្តិកៈ មន្ត្រីរាជការស៊ីវិល

[60] មាត្រា ៤៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងការបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ( ក្នុងករណីមិនអាចកំណត់បាន អាចបើកការស៊ើបសួរប្រឆាំង នឹងអញ្ញាតជន ពោលគឺ ជនមិនស្គាល់ ) ។
- ចុះកាលបរិច្ឆេទ និងហត្ថលេខា ។

ព្រះរាជអាជ្ញា មានកាតព្វកិច្ចធ្វើដីកានេះស្នើឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរក្នុងករណីដូចខាងក្រោម៖

- បទល្មើសឧក្រិដ្ឋជាក់ស្តែង ឬមិនជាក់ស្តែង
- បទល្មើសមជ្ឈិម ដែលព្រះរាជអាជ្ញាយល់ឃើញថា ត្រូវបើកការស៊ើបសួរ ។

អនុលោមតាមន័យនេះចៅក្រមស៊ើបសួរត្រូវបានប្រគល់អំណាចដោយព្រះរាជអាជ្ញា ឱ្យធ្វើការស្រាវជ្រាវទៅលើអង្គហេតុ ដែលចង្អុលបង្ហាញដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ហើយការស្រាវជ្រាវទៅលើអង្គហេតុរបស់ចៅក្រមស៊ើបសួរគឺខុសពីការស្រាវជ្រាវដែលធ្វើឡើងដោយព្រះរាជអាជ្ញា ព្រោះព្រះរាជអាជ្ញា នៅពេលដែលគាត់ធ្វើការស្រាវជ្រាវស្វែងរកព័ត៌មាន និងភស្តុតាងទាំងឡាយណាដើម្បីកំណត់ឱ្យឃើញអំពីអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌដើម្បីការពារការចោទប្រកាន់របស់គាត់។ ប៉ុន្តែនៅពេលសំណុំរឿងត្រូវបានបញ្ជូនទៅចៅក្រមស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ ចៅក្រមស៊ើបសួរបំពេញកិច្ចធ្វើការស្រាវជ្រាវ ដើម្បីស្វែងរកឱ្យឃើញការពិតអំពីអត្ថិភាព ឬនត្ថិភាព នៃបទល្មើសដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ក្នុងន័យនេះមានន័យថាចៅក្រមស៊ើបសួរ នឹងធ្វើការស្រាវជ្រាវនូវគ្រប់ព័ត៌មានទាំងអស់ដែលមានទាំងភស្តុតាងដាក់បន្ទុក ហើយនិងភស្តុតាងដោះបន្ទុក[61]។

### ២. នីតិវិធីនៃការបើកការស៊ើបសួរ

នីតិវិធីនៃការបើកការស៊ើបសួរអាចត្រូវបានធ្វើឡើងទៅតាមករណី ២ (ពីរ) យ៉ាងគឺ៖

- ការបើកការស៊ើបសួរតាមរយៈ ពាក្យប្តឹងសាមញ្ញ ឬ សំណុំរឿងមន្ត្រីនគរបាលយុត្តិធម៌
- ការបើកការស៊ើបសួរតាមរយៈ ពាក្យប្តឹង ដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

### ក). ការបើកការស៊ើបសួរតាមរយៈពាក្យបណ្តឹងសាមញ្ញ ឬសំណុំរឿងមន្ត្រីនគរបាលយុត្តិធម៌

ពាក្យបណ្តឹងសាមញ្ញ សំដៅទៅលើពាក្យប្តឹងទាំងឡាយណា ដែលធ្វើឡើងក្នុងគោលដៅបកអាក្រាតពីបទល្មើសព្រហ្មទណ្ឌណាមួយបានកើតឡើង។ ចំពោះពាក្យបណ្តឹងសាមញ្ញនេះ នៅក្នុងក្របខណ្ឌនៃនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ អាចស្តែងឡើងតាមរូបភាព២ (ពីរ) យ៉ាង៖

[61] មាត្រា ១២៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**បណ្តឹងទាមទារ ៖** មានន័យថា បណ្តឹងដែលធ្វើឡើងដោយជនរងគ្រោះណាម្នាក់ ឬ ច្រើននាក់ ក្នុងគោលបំណងដើម្បីដោះស្រាយ និងទាមទារសំណងជម្ងឺចិត្តពីបទល្មើសព្រហ្មទណ្ឌណាមួយទៅអាជ្ញាធរមានសមត្ថកិច្ច។

**បណ្តឹងបរិហារ ៖** មានន័យថា បណ្តឹងទាំងឡាយណាដែលធ្វើឡើងដោយជនណាម្នាក់ ឬ ច្រើននាក់ ក្រៅពីជនរងគ្រោះក្នុងគោលបំណងបង្ហាញអំពីបទល្មើសព្រហ្មទណ្ឌណាមួយដែលបានកើតមានឡើងទៅអាជ្ញាធរមានសមត្ថកិច្ច ដែលមិនមានការទាមទារសំណងជម្ងឺចិត្ត ដូចបណ្តឹងទាមទារឡើយ។

គួរកត់សម្គាល់ផងដែរថា ចំពោះពាក្យប្តឹងសាមញ្ញវាពុំមានអានុភាពនាំឱ្យមានការចោទប្រកាន់ជាបទព្រហ្មទណ្ឌទេ មានន័យថា នៅពេលដែលព្រះរាជអាជ្ញាទទួលពាក្យប្តឹងសាមញ្ញបែបនេះ នោះព្រះរាជអាជ្ញានឹងធ្វើការថ្លឹងថ្លែងទៅលើបទល្មើស នៅក្នុងពាក្យប្តឹងថាគួរចោទប្រកាន់ឬ មិនចោទប្រកាន់។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាបទល្មើសនោះមានចរិតលក្ខណៈដាច់ខាតចាំបាច់ឱ្យមានការចោទប្រកាន់លើលក្ខខណ្ឌនៃនីតិវិធី ហើយលក្ខខណ្ឌនៃនីតិវិធីការបើកការស៊ើបអង្កេត ត្រូវបានបំពេញនោះព្រះរាជអាជ្ញា នឹងបើកការស៊ើបសួរដោយប្តឹងទៅចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

**ខ). ការបើកការស៊ើបសួរតាមរយៈពាក្យប្តឹងដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

នៅពេលជនរងគ្រោះដែលទទួលរងព្យសនកម្ម ពីបទល្មើសព្រហ្មទណ្ឌណាមួយ បានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីទាមទារសំណងផ្សេងៗ តែព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការនោះ ជនរងគ្រោះនឹងបាត់បង់ឱកាសក្នុងការទាមទារសំណង។ ដោយមើលឃើញពីចន្លោះប្រហោង នៃនីតិវិធីព្រហ្មទណ្ឌបែបនេះ ទើបក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានបញ្ចូលនូវយន្តការថ្មីមួយ សម្រាប់ជនរងគ្រោះដែលមានបំណងទាមទារសំណងផ្សេងៗ ដែលបង្កឡើងដោយបទល្មើសព្រហ្មទណ្ឌណាមួយ ក្នុងករណីដែលបទល្មើសនោះត្រូវបានព្រះរាជអាជ្ញាធ្វើការសម្រេចចិត្តតម្កល់រឿងទុកឥតចាត់ការ។

យន្តការថ្មីនេះ ជាយន្តការសម្រាប់ជនរងគ្រោះទាមទារសំណងជម្ងឺចិត្តផ្សេងៗនោះ គឺការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។ ពាក្យបណ្តឹងដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញាដែលគេហៅថា **ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ** [62]។

[62] មាត្រា ៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ២.១. លក្ខខណ្ឌនៃការបើកការស៊ើបសួរក្នុងបទល្មើសព្រហ្មទណ្ឌ

ទោះបីជាការបើកការស៊ើបសួរ អាចធ្វើឡើងតាមវិធីដូចដែលបានបង្ហាញខាងលើក៏ដោយ ក៏ការបើកការស៊ើបសួរតាមវិធីទាំងនេះត្រូវបំពេញលក្ខខណ្ឌមួយចំនួនដែលក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចង្អុលបង្ហាញ។ តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ លក្ខខណ្ឌនៃការបើកការស៊ើបសួរត្រូវបានបែងចែកជាប្រភេទបទល្មើសដែលក្នុងនោះគេឃើញថា ការបើកការស៊ើបសួរអាចធ្វើឡើងក្នុងករណីបទឧក្រិដ្ឋ និងបទមជ្ឈិម។

- **លក្ខខណ្ឌនៃការបើកការស៊ើបសួរចំពោះបទឧក្រិដ្ឋ**

ការបើកការស៊ើបសួរ គឺជានីតិវិធីមួយដែលមានលក្ខណៈវែងអន្លាយ និងស្មុគស្មាញ ព្រោះនៅក្នុងកាលប្បវត្តិនៃដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរនឹងប្រើប្រាស់វិធានការជាច្រើនដែលបានចង្អុលបង្ហាញដោយក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ ហេតុនេះចំពោះបទឧក្រិដ្ឋ បើព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់នោះព្រះរាជអាជ្ញា ត្រូវតែជ្រើសរើសយកនីតិវិធីនៃការចោទប្រកាន់ដោយការបើកការស៊ើបសួរ[63]។

ការបើកការស៊ើបសួរត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ[64]។ ព្រោះបទឧក្រិដ្ឋជាបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរ ហើយអ្នកដែលបានចោទប្រកាន់ចំពោះបទល្មើសនេះ នឹងអាចប្រឈមមុខនឹងការដាក់ពន្ធនាគារច្រើនឆ្នាំ និងដើម្បីជៀសវាងនឹងការជំនុំជម្រះដែលធ្វើឡើងដោយមានការភ័ន្តច្រឡំ ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនជាប់ចោទ។ ហេតុនេះលក្ខខណ្ឌនៃការបើកការស៊ើបសួរចំពោះបទឧក្រិដ្ឋ គឺជាលក្ខខណ្ឌចាំបាច់ និងដាច់ខាតខុសពីករណីបទមជ្ឈិមដែលព្រះរាជអាជ្ញាអាចធ្វើការថ្លឹងថ្លែងធ្វើការចោទប្រកាន់ថាគួរបើកការស៊ើបសួរ ឬចាត់ការតាមនីតិវិធីចោទប្រកាន់ផ្សេងៗ។

- **លក្ខខណ្ឌនៃការបើកការស៊ើបសួរចំពោះបទមជ្ឈិម**

ចំពោះបទមជ្ឈិមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានផ្តល់ជាឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែងសម្រេចធ្វើការចោទប្រកាន់ បើកការស៊ើបសួរ ឬប្រើការចោទប្រកាន់តាមនីតិវិធីផ្សេង[65]។

ជារួមមកការបើកការស៊ើបសួរ អាចធ្វើឡើងចំពោះបទល្មើស ២ (ពីរ)គឺ បទឧក្រិដ្ឋ និង បទមជ្ឈិម។ ហើយដើម្បីឱ្យការបើកការស៊ើបសួរមាននីត្យានុកូលនោះព្រះរាជអាជ្ញាត្រូវបំពេញឱ្យបានច្បាស់លាស់នូវទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

[63] មាត្រា ៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[64] មាត្រា ១២២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[65] មាត្រា ៤៥ និង មាត្រា ១២២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ២.២. ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ពេលដែលព្រះរាជអាជ្ញាសម្រេចចោទប្រកាន់តាមរយៈការស៊ើបសួរនោះ ព្រះរាជអាជ្ញាត្រូវរៀបចំលិខិតនីតិវិធី គឺដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅចៅក្រមស៊ើបសួរឱ្យបំពេញកិច្ចស៊ើបសួរ។ ព្រះរាជអាជ្ញាត្រូវបំពេញឱ្យបានច្បាស់លាស់ នូវទម្រង់ការនៃដីកានេះ ដែលបានលើកឡើងខាងលើម្តងរួចមកហើយ ក៏ប៉ុន្តែដើម្បីឱ្យកាន់តែច្បាស់នូវចំណុចនេះ យើងខ្ញុំសូមលើកយកមកបង្ហាញម្តងទៀត ដែលក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ បានចង្អុលបង្ហាញទម្រង់ការនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមានដូចតទៅ៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស ឧទាហរណ៍ ករណីរំលោភ ឃាតកម្ម
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងការបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ( ក្នុងករណីមិនអាចកំណត់បាន អាចបើកការស៊ើបសួរប្រឆាំង នឹងអញ្ញាតជន ពោលគឺ ជនមិនស្គាល់ ) ។
- ចុះកាលបរិច្ឆេទ និងហត្ថលេខា [66]។

ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីលក្ខណៈដាច់ខាត នៃទម្រង់ការនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលព្រះរាជអាជ្ញាត្រូវតែគោរពតាមទម្រង់នេះជាដាច់ខាត មានន័យថាប្រសិនបើមានចំណុចណាមួយនៃទម្រង់ការនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះមិនបានបំពេញនោះដីកានេះត្រូវទុកជាមោឃៈ [67]។ (មោឃភាព នៃលិខិតនីតិវិធីនេះ មានតែសភាស៊ើបសួរប៉ុណ្ណោះ ដែលមានសមត្ថកិច្ច ដើម្បីពិនិត្យ ក្នុងករណីប្រសិនបើ ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី យល់ឃើញថា លិខិតណាមួយនៃនីតិវិធីមានមោឃភាព ចៅក្រមស៊ើបសួរ ប្តឹងទៅសភាស៊ើបសួរ តាមដីកាដោយមានសំអាងហេតុ និងជូនព័ត៌មានដល់ ព្រះរាជអាជ្ញា ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី)[68]។

### ២.៣. ការចូលរួមរបស់អង្គការអយ្យការក្នុងការស៊ើបសួរ

ទោះបីជាការបើកការស៊ើបសួរ ព្រះរាជអាជ្ញាត្រូវប្រគល់សំណុំរឿងទាំងអស់ទៅចៅក្រមស៊ើបសួរក៏ដោយ ក៏មិនមែនមានន័យថា ព្រះរាជអាជ្ញាអស់សិទ្ធិ ទៅលើសំណុំរឿងនៃរឿងក្តីនោះទេ។ ប៉ុន្តែការចូលរួមរបស់ព្រះរាជអាជ្ញាមិនមានលក្ខណៈទូលំទូលាយ ដូចចៅក្រមស៊ើបសួរទេ ព្រោះថាព្រះរាជអាជ្ញាពុំមានសិទ្ធិស្រាវជ្រាវ

---

[66] មាត្រា ៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[67] មាត្រា ៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[68] មាត្រា ២៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដូចចៅក្រមស៊ើបសួរទេ គឺព្រះរាជអាជ្ញាគ្រាន់តែជាអ្នកចូលរួមក្នុងសកម្មភាពស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាចូលរួមសកម្មភាពមួយចំនួនដូចជា៖

- **ការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា**
- **ការសួរចម្លើយ និងការស្តាប់ចម្លើយ**
- **ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ**
- **ដំណើរការនៃការឃុំខ្លួន**
- **ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**

### ២.៤. ដីកាសន្និដ្ឋានស្ថាពរបញ្ចប់ការស៊ើបសួររបស់អង្គការអយ្យការ

នៅពេលដែលកិច្ចស៊ើបសួរចប់សព្វគ្រប់ ចៅក្រមស៊ើបសួរនឹងបិទការស៊ើបសួររបស់ខ្លួនតាមរយៈដីកាដំណោះស្រាយ[៦៩]។ ប៉ុន្តែមុននឹងចេញដីកាដំណោះស្រាយនេះ ចៅក្រមស៊ើបសួរត្រូវតែជូនដំណឹងអំពីការបញ្ចប់ការស៊ើបសួររបស់ខ្លួនទៅ ៖

- ជនត្រូវចោទ
- ដើមបណ្តឹងរដ្ឋប្បវេណី
- មេធាវី និង
- ព្រះរាជអាជ្ញា ដែលជាម្ចាស់បណ្តឹងអាជ្ញា។

ការជូនដំណឹងទៅព្រះរាជអាជ្ញា គឺជាកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរដែលត្រូវបំពេញ។ ចៅក្រមស៊ើបសួរមិនត្រូវធ្វើការបិទការស៊ើបសួរស្ងាត់ៗនោះបានទេ គឺត្រូវតែជូនដំណឹងដល់ភាគីនៃរឿងក្តីឱ្យបានដឹង ក្នុងគោលបំណងដើម្បីឱ្យភាគីស្នើសុំទៅចៅក្រមស៊ើបសួរ ឱ្យបំពេញកិច្ចណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ហើយក៏អាចឱ្យភាគីធ្វើការរៀបចំនូវមធ្យោបាយការពារខ្លួនផ្សេងទៀតទាន់ពេលវេលា។ ទម្រង់ការនៃការជូនដំណឹង ចៅក្រមស៊ើបសួរត្រូវធ្វើតាមរយៈលិខិតរដ្ឋបាលមួយប្រភេទមានឈ្មោះថា **លិខិតជូនព័ត៌មាន** ឬ **លិខិតជូនដំណឹង**។

ក្រោយពីជូនដំណឹងបានរយៈពេល២ ថ្ងៃរួចមក ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យតាមរយៈដីកា បញ្ជូនរឿងឱ្យពិនិត្យ។ ចៅក្រមស៊ើបសួរធ្វើការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដោយសារមានហេតុផល ២ យ៉ាងគឺ៖

[៦៩] មាត្រា ២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- ដើម្បីឱ្យព្រះរាជអាជ្ញាពិនិត្យមើលសំណុំរឿង ថាតើគួរតែមានការយល់ស្របដូចចៅក្រមស៊ើបសួរដែរ ឬមួយក៏ចង់ឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចណាមួយទៀត បើយល់ឃើញថាមានប្រយោជន៍។
- ដើម្បីឱ្យព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានស្ថាពរលើសំណុំរឿង។

ប្រសិនព្រះរាជអាជ្ញាយល់ឃើញថា ចៅក្រមស៊ើបសួរត្រូវបំពេញកិច្ចណាមួយដែលចាំបាច់នោះព្រះរាជអាជ្ញាត្រូវធ្វើការស្នើសុំចៅក្រមស៊ើបសួរឱ្យបំពេញកិច្ច [70]។

បើព្រះរាជអាជ្ញាយល់ឃើញថាការស៊ើបសួរអាចបញ្ចប់បានហើយ ព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ ប្រសិនបើជនត្រូវចោទនៅក្នុងឃុំ និង ១ (មួយ)ខែ ប្រសិនបើជនត្រូវចោទនៅក្រៅឃុំ[71]។ ដីកានេះត្រូវធ្វើឡើងដោយលាយល័ក្ខណ៍អក្សរ និងបញ្ជាក់ពីការសំអាងហេតុ និងមូលហេតុឱ្យបានច្បាស់លាស់។ ដីកានេះត្រូវចេញដោយព្រះរាជអាជ្ញា ហើយនៅក្នុងផ្នែកនៃសេចក្តីសម្រេចនៃដីកានេះ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។ ដីកានេះត្រូវចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង។

ក្រោយពីធ្វើដីកាសន្និដ្ឋានស្ថាពរហើយ ព្រះរាជអាជ្ញាត្រូវបញ្ជូនដីកានេះដាក់ចូលក្នុងសំណុំរឿងហើយផ្ញើជូនទៅចៅក្រមស៊ើបសួរវិញ។ បន្ទាប់ពីទទួលបានសំណុំរឿងពីព្រះរាជអាជ្ញា ដោយភ្ជាប់មកជាមួយដីកាសន្និដ្ឋានស្ថាពរហើយនោះ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចណាមួយបានទៀតនោះឡើយ ហើយត្រូវតែបិទការស៊ើបសួរដោយចេញដីកាដំណោះស្រាយតែម្តង។

ដីកាដំណោះស្រាយនេះ គឺជាដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ក្នុងការសម្រេចបិទកិច្ចស៊ើបសួររបស់ខ្លួន។ ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរនេះស្តែងឡើងតាមរូបភាព ២ គឺ៖

**ដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់។**

ការចេញដីកាដំណោះស្រាយនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចដោយលក្ខណៈឯករាជ្យ និងដោយឆន្ទានុសិទ្ធិរបស់ខ្លួន ទោះបីជាមានការចង្អុលបង្ហាញពីព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានស្ថាពរក៏ដោយ ព្រោះថាចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាឡើយ។ មានន័យថា ប្រសិនបើនៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាធ្វើការលើកលែងការចោទប្រកាន់ក៏ដោយ ក៏នៅក្នុងដីកាដំណោះស្រាយចៅក្រមស៊ើបសួរនៅតែមានសិទ្ធិក្នុងការចោទប្រកាន់ជននោះដដែល គឺដោយដីកាបញ្ជូនទៅជំនុំជម្រះ ប្រសិនបើអង្គហេតុដែលចៅក្រមស៊ើបសួរធ្វើការស៊ើបសួរនោះ គាត់យល់ថាអង្គហេតុនោះ

[70] មាត្រា ១៣២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[71] មាត្រា ២៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

បង្កើតបានជាបទល្មើសព្រហ្មទណ្ឌ។ ម្យ៉ាងទៀត បើសិនជាព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានស្ថាពរក៏ដោយ ក៏ចៅក្រមស៊ើបសួរនៅតែមានសិទ្ធិសម្រេចលើកលែងការចោទប្រកាន់ គឺដោយដីកាដំណោះស្រាយរបស់ខ្លួន ដែលដីកានោះគេហៅថា ដីកាលើកលែងការចោទប្រកាន់ បើកាលណាចៅក្រមស៊ើបសួរយល់ឃើញថាអង្គហេតុដែលគាត់ធ្វើការស៊ើបសួរនោះ គាត់យល់ឃើញថាអំពើដែលបានប្រព្រឹត្តមិនមែនជាបទល្មើស ឬជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ឬនៅតែគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។ ហេតុនេះហើយនៅក្នុងកិច្ចស៊ើបសួរ បើចៅក្រមស៊ើបសួរស្រាវជ្រាវទៅឃើញថាសំណុំរឿងនៅតែគ្មានមូលដ្ឋានសមស្របដើម្បីធ្វើការចោទប្រកាន់ទៅលើជនត្រូវចោទ នោះចៅក្រមស៊ើបសួរនឹងធ្វើការលើកលែងការចោទប្រកាន់តាមរយៈដីកាដំណោះស្រាយរបស់ខ្លួន។

បន្ទាប់ពីចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយរួចរាល់ហើយ គាត់ត្រូវធ្វើការជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតទៅដល់ព្រះរាជអាជ្ញា[72] គឺដើម្បីទុកឱកាសដល់ព្រះរាជអាជ្ញាប្រើសិទ្ធិរបស់ខ្លួនក្នុងការធ្វើពាក្យប្តឹងឧទ្ធរណ៍ ប្រសិនបើគាត់យល់ឃើញថា មានចំណុចមិនប្រក្រតីក្នុងចំណុចណាមួយនៅក្នុងដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរនោះ។

## ផ្នែកទី៣៖ ការបញ្ជូនរឿងក្តីទៅចៅក្រមជំនុំជម្រះ

កាលណាព្រះរាជអាជ្ញាពិនិត្យឃើញថា លក្ខខណ្ឌនៃការបញ្ជូនរឿងក្តីទៅចៅក្រមស៊ើបសួរ តាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួរមិនត្រូវបានបំពេញទេ ព្រះរាជអាជ្ញាអាចជ្រើសរើសមធ្យោបាយចំនួន ០២ (ពីរ) ផ្សេងទៀត ដើម្បីបញ្ជូនរឿងក្តីទៅតុលាការជំនុំជម្រះតែម្តង គឺ (១.) **ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់** និង (២.) **តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។**

### ១. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដើម្បីចាប់ផ្តើមនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់បាន ដំបូងព្រះរាជអាជ្ញាត្រូវចេញដីកា មួយដែលមានឈ្មោះថា **ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឱ្យជនជាប់ចោទឱ្យចូលទៅបង្ហាញខ្លួននៅមុខ តុលាការជាន់ដំបូង[73]។ លក្ខខណ្ឌដើម្បីដំណើរការនីតិវិធីនៃការបញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញាត្រូវគោរពលក្ខខណ្ឌជាច្រើន ដែលត្រូវបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ ប៉ុន្តែមុនឈានទៅដល់ការបកស្រាយអំពីលក្ខខណ្ឌដែលត្រូវបំពេញនៃនីតិ

[72] មាត្រា ២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[73] មាត្រា ៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

វិធីបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ យើងគួរធ្វើការសិក្សាទៅលើនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ នៅក្នុងក្របខណ្ឌនៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៩៣ ជាមុនសិន។

នៅក្នុងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ រដ្ឋអាជ្ញាក៏អាចប្រើប្រាស់នីតិវិធីនៃការបញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់ ក្នុងការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌរបស់គាត់បានផងដែរ។ មាត្រា ៦១ នៃច្បាប់នេះបានកំណត់ថា **កាលណាក្នុងករណីបទល្មើសមជ្ឈិមរដ្ឋអាជ្ញាអាច ឬចោទប្រកាន់ជនល្មើស ហើយបញ្ជូនផ្ទាល់ទៅតុលាការព្រហ្មទណ្ឌដើម្បីជំនុំជម្រះ។** បទមជ្ឈិមដែលបានលើកឡើងដោយច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣ នេះ នៅក្នុងការប្រើនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺមិនសំដៅជាទូទៅដល់បទល្មើសមជ្ឈិមទេ មានន័យថា រដ្ឋអាជ្ញាអាចធ្វើការចោទប្រកាន់តាម នីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ទៅលើបទល្មើសមជ្ឈិមទាំងឡាយណាដែលត្រូវការផ្តន្ទាទោស អតិបរមាមិនលើសពីមួយឆ្នាំ[74]។ ដោយឡែក ចំពោះបទល្មើសលហុវិញ រដ្ឋអាជ្ញាក៏អាចចោទប្រកាន់តាមនីតិវិធីនេះបានដែរ ហើយចំពោះបទលហុនេះរដ្ឋអាជ្ញាអាចចាប់ផ្តើមចោទប្រកាន់ ដោយប្រើប្រាស់នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់តែប៉ុណ្ណោះ។ ដោយឡែក នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏បានដាក់បញ្ចូលនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដែរ ប៉ុន្តែនៅក្នុងក្រមនីតិវិធីថ្មីនេះ នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវបានដាក់បញ្ចូលនូវលក្ខខណ្ឌថ្មីៗជាច្រើនដែលនាំឱ្យនីតិវិធីនេះ មានលក្ខណៈខុសប្លែកទៅនឹងនីតិវិធីចាស់ដែលបានកំណត់នៅក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣។

### ១.១. លក្ខខណ្ឌនៃការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

នៅពេលដែលព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដោយប្រើនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញានឹងចេញដីកាសម្រេចមួយ គឺ**ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**។ លក្ខខណ្ឌដើម្បីឱ្យព្រះរាជអាជ្ញាអាចចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ តាមនីតិវិធីនេះ ព្រះរាជអាជ្ញាត្រូវរកឱ្យឃើញនូវលក្ខខណ្ឌ ២ យ៉ាងចាំបាច់គឺ៖

**ក. លក្ខខណ្ឌនៃបទល្មើស និង**

**ខ. លក្ខខណ្ឌនៃសាវតាជាតិរបស់ជនល្មើស។**

- **លក្ខខណ្ឌនៃបទល្មើស**

ចំពោះប្រភេទនៃបទល្មើសព្រហ្មទណ្ឌ ត្រូវបានបែងចែកជាបីធំៗគឺ **បទលហុ បទមជ្ឈិម និង បទឧក្រិដ្ឋ**។ ដោយឡែកនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចង្អុលបង្ហាញពីប្រភេទនៃបទល្មើសពីរគឺ

[74] មាត្រា ៦៧ នៃច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣

បទលហុ និងបទមជ្ឈិម ដែលអាចឱ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់របស់ខ្លួនដោយ ប្រើប្រាស់នីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់បាន។

– **បទលហុ**

បទលហុសំដៅទៅលើស្ថានភាពនៃបទល្មើសទាំងឡាយណាដែលត្រូវរងជាទោសដាក់ពន្ធនាគាររយៈពេល អតិបរមាក្រោម ឬស្មើ ០៦ (ប្រាំមួយ) ថ្ងៃ។ ម្យ៉ាងវិញទៀត បទល្មើសដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ ក៏ត្រូវបានចាត់ទុកថាជាបទលហុផងដែរ[75]។ នៅពេលដែលអង្គហេតុមួយបង្កើតបានជាបទលហុព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់តាមនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់[76]។ ចំពោះបទលហុនេះព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ បានតែក្នុងនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់តែប៉ុណ្ណោះ ព្រោះថា បទលហុជាបទល្មើសតូចតាច ប្រសិនបើត្រូវរងការចោទប្រកាន់ដោយប្រើប្រាស់នីតិវិធីផ្សេង ដូចជាការបង្ហាញខ្លួនភ្លាម ឬបើកការស៊ើបសួរ វានឹងនាំឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិសេរីភាពរបស់ជនជាប់ចោទ ដោយហេតុថានីតិវិធីនៃការបង្ហាញខ្លួនភ្លាម ឬនីតិវិធីនៃការបើកការស៊ើបសួរអនុញ្ញាតឱ្យមានការឃុំជនជាប់ចោទរហូតដល់បង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ។

– **បទមជ្ឈិម**

ចំពោះបទមជ្ឈិមវិញ គឺសំដៅទៅលើស្ថានភាពនៃបទល្មើស ទាំងឡាយណាដែលត្រូវរងទោសដាក់ពន្ធនាគាររយៈពេលជាអតិបរមាលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ០៥(ប្រាំ) ឆ្នាំ[77] ។ ដោយយោងទៅលើក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បទមជ្ឈិម ជាកម្មវត្ថុនៃការចោទប្រកាន់តាម នីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់[78]។ ត្រង់លក្ខខណ្ឌនេះ មានភាពទូលំទូលាយជាង លក្ខខណ្ឌដែលបានកំណត់នៅក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌចាស់ ឆ្នាំ១៩៩៣ ដោយហេតុថាមានមាត្រា ៦៧ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣ បានចែងថារដ្ឋអាជ្ញាអាចធ្វើការចោទប្រកាន់តាមនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ទៅ លើបទមជ្ឈិមទាំងឡាយណាដែលត្រូវរងការផ្តន្ទាទោសអតិបរមាមិនលើសពីមួយឆ្នាំ។ ដោយក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មិនបានកំណត់ឱ្យបានច្បាស់យ៉ាងនេះទេ មានន័យថា ឱ្យតែមានបទល្មើសមួយកើតឡើងដែលជាបទមជ្ឈិម ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់តាមនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់បាន មិនថាបទមជ្ឈិមនោះជាក់ស្តែង ឬមិនជាក់ស្តែងក៏ដោយ។ ម្យ៉ាងវិញទៀត ការកំណត់លក្ខខណ្ឌឱ្យខុសពីនីតិវិធីចាស់បែបនេះ គឺស្ថិតនៅក្នុងគោលដៅដើម្បីទុក

[75] មាត្រា ៤៨ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[76] មាត្រា ៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[77] មាត្រា ៤៧ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[78] មាត្រា ៤៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឱកាសឱ្យព្រះរាជអាជ្ញា ប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការពិចារណាថ្លឹងថ្លែងថា តើបទល្មើសដែលខ្លួនទទួលបាន មានភាពធួនល្មមនឹងអាចជំនុំជម្រះបានដែរឬទេ ។ ហើយដើម្បីបញ្ជាក់អំពីភាពធួនល្មមនឹងអាចជំនុំជម្រះបាន ក្នុងករណីខ្លះ ព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យស្រាវជ្រាវបន្ថែមបាន[79] ។

- **លក្ខខណ្ឌសាវតាជាតិរបស់ជនល្មើស**

ក្រៅពីការកំណត់ឱ្យបានអំពីប្រភេទនៃបទល្មើសហើយព្រះរាជអាជ្ញា នៅពេលដែលទទួលបណ្តឹង ចាំបាច់ត្រូវរកឱ្យឃើញអំពីសាវតាជាតិរបស់ជនល្មើស ដែលនេះជាលក្ខខណ្ឌចាំបាច់នៅក្នុងនីតិវិធីនៃការបញ្ជូន ទៅជំនុំជម្រះផ្ទាល់។ នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ទាមទារការកំណត់ឱ្យបាននូវអត្តសញ្ញាណ របស់ ជនល្មើសដោយខានមិនបាន ព្រោះថាបើជនល្មើសស្ថិតនៅក្នុងស្ថានភាពអញ្ញាតជនទេនោះ ព្រះរាជអាជ្ញាមិន អាចធ្វើការចោទប្រកាន់តាមវិធីនេះបានទេ។

## ១.២. នីតិវិធីនៃការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

នីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជានីតិវិធីមួយដែលមិនឆ្លងកាត់ដំណាក់កាលស៊ើបសួរទេ ហេតុនេះ ព្រះរាជអាជ្ញា នៅពេលដែលទទួលបណ្តឹងហើយ ត្រូវធ្វើការចោទប្រកាន់ភ្លាម ហើយបញ្ជូនសំណុំរឿងនេះ តាម រយៈដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ទៅយុត្តាធិការជំនុំជម្រះផ្ទាល់។ ក្នុងន័យនេះ មិនមានន័យថាជនជាប់ចោទ ត្រូវបានជំនុំជម្រះភ្លាមៗ នៅពេលដែលដីកាបញ្ជូនទៅតុលាការជំនុំជម្រះផ្ទាល់ ទៅដល់ដៃចៅក្រមជំនុំជម្រះ នោះទេ គឺព្រះរាជអាជ្ញាត្រូវកោះហៅ និងប្រាប់អំពីព័ត៌មានដល់ជនជាប់ចោទតាមរយៈដីកាកោះហៅបញ្ជូនទៅ ជំនុំជម្រះផ្ទាល់។ ម្យ៉ាងវិញទៀត ការចោទប្រកាន់តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះទៀត សោត ព្រះរាជអាជ្ញាត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនដែលក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចង្អុល បង្ហាញដើម្បីធានាបានថា ដីកាកោះហៅរបស់គាត់មានសុពលភាព។

**ក). ទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

ព្រះរាជអាជ្ញាត្រូវធ្វើដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឱ្យមានទម្រង់ការច្បាស់លាស់ ដើម្បីឱ្យ ចៅក្រមជំនុំជម្រះយល់ឃើញថារឿងក្តីដែលព្រះរាជអាជ្ញាបានចោទប្រកាន់ពិតជាមាន ភាពធួនល្មមនឹងអាច ចោទប្រកាន់បាន។ ម្យ៉ាងវិញទៀតទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះ នេះក៏ជាព័ត៌មានយ៉ាងសំខាន់ សម្រាប់ជនជាប់ចោទយល់អំពីមូលហេតុនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ព្រមទាំងសិទ្ធិ និងកាតព្វកិច្ច របស់ជនជាប់ចោទក្នុងការបង្ហាញខ្លួនតាមកាលកំណត់ដូចដែលបានចែងនៅក្នុងដីកានេះ។ ហេតុនេះ ទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមានដូចតទៅ ៖

---

[79] មាត្រា ៤០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- អត្តសញ្ញាណនៃជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ
- ឈ្មោះបទល្មើស និង
- អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។

ក្រៅពីទម្រង់ការខាងលើ នៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ ព្រះរាជអាជ្ញាក៏ត្រូវ ចង្អុលប្រាប់ដល់ជនជាប់ចោទពីតុលាការ ព្រមទាំងទីកន្លែងចោទប្រកាន់ កាលបរិច្ឆេទនិងម៉ោងពេលនៃសវនាការផងដែរ។ ហេតុដូច្នេះនៅក្នុងនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញាពុំចាំបាច់ចេញដីកាកោះហៅជនជាប់ចោទចូលសវនាការ ដូចដែលមានចែងនៅក្នុងមាត្រា ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទៀតទេ ព្រោះថាទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ បានបញ្ជាក់ប្រាប់ដល់ជនជាប់ចោទរួចអស់ទៅហើយ។

**ខ). សុពលភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

ដើម្បីធានាជនជាប់ចោទ មានរយៈពេលសមរម្យដើម្បីឱ្យជនជាប់ចោទរៀបចំខ្លួនត្រៀមឡើងសវនាការ ដូចដែលមានចែងនៅក្នុងមាត្រា ៤៦៦ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បាន កំណត់អំពីរយៈពេលខុសៗគ្នា ដែលអាស្រ័យទៅលើស្ថានភាពទីតាំង ដែលជនជាប់ចោទមានវត្តមាន។ រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួននោះគឺ៖

- **១៥ (ដប់ប្រាំ) ថ្ងៃ** ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង
- **២០ (ម្ភៃ) ថ្ងៃ** ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- **២ (ពីរ) ខែ** ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- **៣ (បី) ខែ** ប្រសិនបើជនជាប់ចោទរស់នៅក្នុងកន្លែងដទៃទៀត[80]។

កាលបើលក្ខខណ្ឌទាក់ទងនឹងរយៈពេលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួនក្លាមមិនត្រូវបានបំពេញ ឬធ្វើឡើងដោយបំពាននោះ ហើយបើតុលាការយល់ឃើញថាដីកានោះមានអានុភាពធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជនជាប់ចោទ តុលាការអាចនឹងប្រកាសអំពីមោឃភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បាន[81]។ ម្យ៉ាងទៀត តុលាការត្រូវបង្គាប់ឱ្យ

[80] មាត្រា ៤៥៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[81] មាត្រា ៤៩២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មានការចេញនូវដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ជាថ្មីម្តងទៀត លើកលែងតែក្នុងករណីផុតរលត់បណ្តឹងអាជ្ញា[82] ។

ជារួមមក នីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីនៃការចោទប្រកាន់មួយដែលធានាការពារដល់សិទ្ធិបុគ្គលដល់ជនជាប់ចោទ ព្រោះថាជានិច្ចកាលជនជាប់ចោទត្រូវនៅក្រៅឃុំជានិច្ច ព្រោះថាជនជាប់ចោទមុននឹងបង្ហាញខ្លួននៅមុខតុលាការ គាត់ត្រូវបានជូនដំណឹងអំពីពេលវេលា កាលបរិច្ឆេទនៃសវនាការ តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។ ម្យ៉ាងវិញទៀតនៅក្នុងនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ ជនជាប់ចោទចូលទៅបង្ហាញខ្លួនដោយខ្លួនឯងនៅពេលសវនាការ គឺគ្មានការបង្ខំ ឬត្រូវបានឃុំគ្រងដោយកងការពាររបស់ស្ថាប័នតុលាការ ដូចនីតិវិធីនៃការចោទប្រកាន់ផ្សេងទៀត ដូចជានីតិវិធីនៃការបង្ហាញខ្លួនភ្លាម ឬនីតិវិធីនៃការបើកការស៊ើបសួរនោះទេ។

សរុបមកនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីមួយដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ទៅលើជនដែលប្រព្រឹត្តបទល្មើស ហើយបញ្ជូនជននោះទៅកាន់ចៅក្រមជំនុំជម្រះតែម្តង ដោយមិន ចាំបាច់មានការឆ្លងកាត់ចៅក្រមស៊ើបសួរនោះឡើយ។ ហើយនីតិវិធីនេះដែរធ្វើដូចទៅនឹងដំណើរការដែលបានរៀបរាប់ខាងលើ។

## ២. នីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

ក្រៅពីនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ នីតិវិធីនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា មួយទៀតដែលមានលក្ខណៈលឿនជាង និងដើម្បីជួយជម្រុញដល់ដំណើររឿងក្តីព្រហ្មទណ្ឌឱ្យបានឆាប់រហ័ស ជៀសវាងការកកស្ទះសំណុំរឿងនៅក្នុងស្ថាប័នតុលាការ ក៏ដូចជាដើម្បីសម្រួលដល់វិស័យយុត្តិធម៌ក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានដាក់បញ្ចូលការចោទប្រកាន់របស់ព្រះរាជអាជ្ញានូវនីតិវិធីឆាប់រហ័សមួយគឺ **នីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម**។ ចំពោះនីតិវិធីនៃការបង្ហាញខ្លួនភ្លាម គឺជាវិធានការនៃការចោទប្រកាន់មួយដែលអនុញ្ញាតឱ្យ ព្រះរាជអាជ្ញាបង្គាប់ឱ្យជនជាប់ចោទ ចូលបង្ហាញខ្លួននៅមុខសាលាដំបូងដោយផ្ទាល់។

### ២.១. លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម

ដើម្បីធ្វើការចោទប្រកាន់ទៅតាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាមនេះ ព្រះរាជអាជ្ញាត្រូវប្រមែប្រមូលឱ្យបាននូវវត្ថុតាង និងព័ត៌មានទាំងអស់ដែលជាលក្ខខណ្ឌចម្បងក្នុងការចោទប្រកាន់តាមនីតិវិធីនេះ។

[82] មាត្រា ៤៩១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដោយយោងតាមមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ កំណត់លក្ខខណ្ឌដែល ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាមមានដូចខាងក្រោម៖

**ក).** បទល្មើសដាច់ខាតត្រូវតែជាបទមជ្ឈិមជាក់ស្តែង បទល្មើសនេះបានបញ្ជាក់ បង្ហាញយ៉ាងច្បាស់នៅក្នុងមាត្រា ៨៦ និងមាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ ដូច្នេះក្រៅពីបទមជ្ឈិមជាក់ស្តែងព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់តាម នីតិវិធីនេះបានឡើយ ឬអាចនិយាយម្យ៉ាងទៀតបានថានីតិវិធីមួយនេះមិនអាចអនុវត្ត បានឡើយចំពោះករណីបទឧក្រិដ្ឋ មជ្ឈិមមិនជាក់ស្តែង និងបទលហុ។

**ខ).** បទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ)ឆ្នាំ និងជាអតិបរមា ៥ (ប្រាំ)ឆ្នាំ មានន័យថាចន្លោះនៃទោសពី ០១ ឆ្នាំ ទៅ ០៥ ឆ្នាំ នេះគឺសំដៅដល់អតិបរមានៃទោសដែលច្បាប់បានកំណត់។

**គ).** ជនជាប់ចោទជានីតិជន មានន័យថាជនជាប់ចោទត្រូវតែជាបុគ្គលដែលមានអាយុ ចាប់ពី ១៨ ឆ្នាំឡើងទៅ។ ដូច្នេះ នីតិជន ជាជនដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅទើបព្រះរាជអាជ្ញាអាចចោទប្រកាន់តាមនីតិវិធីនេះបាន។

**ឃ).** រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ផ្ចួនល្មមអាចជំនុំជម្រះបាន មានន័យថា នៅក្នុងសំណុំរឿងត្រូវមានភស្តុតាងគ្រប់គ្រាន់ ដោយពុំមានការសង្ស័យ ដែលមានភាពផ្ចួនល្មមនឹង អាចបើកសវនាការជំនុំជម្រះបាន។

ជារួមមក លក្ខខណ្ឌទាំងបួនខាងលើនេះ គឺជាលក្ខខណ្ឌដែលមិនអាចខ្វះនូវចំណុចណាមួយបានឡើយ។ ក្រៅពីលក្ខខណ្ឌទាំងបួននេះ ប្រសិនបើយើងធ្វើការសិក្សាទៅលើនីតិវិធីនៃការបង្ហាញខ្លួនភ្លាម នីតិវិធីនេះគឺ ពឹងផ្អែកទាំងស្រុងទៅលើវត្តមានរបស់ជនល្មើស បើគ្មានជនល្មើសទេព្រះរាជអាជ្ញាក៏មិនអាចបង្គាប់ឱ្យជនជាប់ចោទចូលមកបង្ហាញខ្លួនបានដែរ។ ហេតុដូចនេះ លក្ខខណ្ឌមួយទៀត ដែលយើងគួរបន្ថែមជាមួយលក្ខខណ្ឌទាំងបួននេះ គឺ វត្តមាននៃជនជាប់ចោទ។ ដូច្នេះ បន្ទាប់ពីព្រះរាជអាជ្ញាបានប្រមូលនូវលក្ខខណ្ឌគ្រប់គ្រាន់ ដូចដែលមានចែងនៅក្នុង មាត្រា ៤៧ ហើយព្រះរាជអាជ្ញានឹងធ្វើចំណាត់ការនីតិវិធីនៃការបង្ហាញខ្លួនភ្លាមតាមរយៈកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម ទៅចំពោះមុខចៅក្រមជំនុំជម្រះ ឬយុត្តាធិការជំនុំជម្រះ។

### ២.២. នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

បន្ទាប់ពី ព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាមរួចមក ព្រះរាជអាជ្ញាត្រូវធ្វើចំណាត់ការនីតិវិធីរបស់ខ្លួន ដែលត្រូវបានចង្អុលបង្ហាញដោយ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ដោយយោងតាមមាត្រា ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ យើងអាចធ្វើការបែងចែងនីតិវិធីនៃការបង្ហាញខ្លួនភ្លាមជា ២ (ពីរ)គឺ៖

- **ទី១.** ដំណាក់កាលចំពោះមុខព្រះរាជអាជ្ញា និង

- **ទី២.** ដំណាក់កាលចំពោះមុខតុលាការជាន់ដំបូង

**ទី១. ដំណាក់កាលចំពោះមុខព្រះរាជអាជ្ញា**

ជំហានដំបូងនៃនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ជនជាប់ចោទត្រូវតែជាជនដែលត្រូវបានឃាត់ខ្លួននៅក្នុងដំណាក់កាលនៃមន្ត្រីនគរបាលយុត្តិធម៌ជាមុនសិន រួចទើបជននោះត្រូវបញ្ជូនមកចំពោះមុខព្រះរាជអាជ្ញានៅពេលដែលរយៈនៃការឃាត់ខ្លួនត្រូវបានបញ្ចប់[83]។ នៅពេលដែលជនជាប់ចោទត្រូវបានបញ្ជូនមកបង្ហាញចំពោះមុខព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាត្រូវពិនិត្យមើលពីអត្តសញ្ញាណបុគ្គលដែលបង្ហាញខ្លួននោះ ដើម្បីធានាឱ្យប្រាកដថាជននោះ គឺពិតជាជនប្រព្រឹត្តបទល្មើសមែន និងជៀសវាងការចាប់ខ្លួនបុគ្គលច្រឡំដែលមិនមែនជាអ្នកប្រព្រឹត្ត។ បន្ទាប់ពីពិនិត្យអំពីអត្តសញ្ញាណជនជាប់ចោទរួចហើយ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់ជននោះអំពីអង្គហេតុនៃការចោទប្រកាន់ និងឈ្មោះបទល្មើស។ ក្នុងករណីដែលជនជាប់ចោទចង់និយាយទាក់ទងទៅនឹងការចោទប្រកាន់ ព្រះរាជអាជ្ញាក៏ត្រូវទទួលចម្លើយរបស់បុគ្គលនោះផងដែរ។ ព្រះរាជអាជ្ញាត្រូវធ្វើកំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមដាក់ចូលក្នុងសំណុំរឿងរបស់ខ្លួនរួចបញ្ជូនទៅតុលាការជាន់ដំបូងដើម្បីចាត់តាំងថៅក្រមជំនុំជម្រះ **(ដោយប្រធានតុលាការ)** ក្នុងការបើកសវនាការ។ ព្រះរាជអាជ្ញាក៏ត្រូវប្រាប់ជនជាប់ចោទថាគេមានសិទ្ធិពឹងពាក់មេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬតាមការចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។ នៅក្នុងករណីដែលជនជាប់ចោទមានមេធាវីការពារខ្លួននោះ ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់មេធាវីនោះដើម្បីឱ្យមេធាវី របស់ជនជាប់ចោទអាចពិនិត្យលើសំណុំរឿងទាក់ទងទៅ នឹងជនជាប់ចោទបាន។

នៅពេលដែលកំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ត្រូវបានធ្វើការចប់សព្វគ្រប់រួចហើយ ជនជាប់ចោទនឹងត្រូវបានបង្ខាំងទុកដោយកងកម្លាំងការពារ និងបញ្ជូនជននោះព្រមទាំងសំណុំរឿង ទៅចំពោះមុខតុលាការ ដែលត្រូវបើកសវនាការនៅថ្ងៃនោះតែម្ដង។

**ទី២. ដំណាក់កាលចំពោះមុខតុលាការជាន់ដំបូង**

នៅពេលដែលជនជាប់ចោទត្រូវបានបង្ហាញខ្លួននៅមុខតុលាការហើយ ជាដំបូងតុលាការ ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់អំពីអត្តសញ្ញាណរបស់ជនជាប់ចោទ និងធ្វើរបាយការណ៍សង្ខេបអំពីអង្គហេតុនៃការចោទប្រកាន់ ហើយត្រូវប្រាប់ជនជាប់ចោទថា គេអាចមានរយៈពេលដើម្បីរៀបចំការការពារខ្លួនបាន។ ប្រសិនបើជនជាប់ចោទមិនទាមទាររយៈពេលដើម្បីរៀបចំការការពារខ្លួននោះទេ តុលាការនឹងបើកសវនាការជំនុំជម្រះ និងប្រកាសសាលក្រមនៅថ្ងៃនោះតែម្ដង។

[83] មាត្រា ១០៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ផ្ទុយទៅវិញប្រសិនបើជនជាប់ចោទសុំរយៈពេលដើម្បីរៀបចំការការពារខ្លួន ឬតុលាការយល់ឃើញថារឿងក្តីនោះ មិនទាន់អាចជំនុំជម្រះភ្លាមៗបានទេ សំណុំរឿងនឹងត្រូវលើកទៅពេលសវនាការក្រោយ។ ក្នុងករណីនេះតុលាការត្រូវបើកសវនាការតូចមួយដែលហៅថា **សវនាការជំនុំជម្រះមុនអង្គសេចក្តី** ដើម្បីសម្រេចរឿងឃុំខ្លួន ឬមិនឃុំខ្លួនជនជាប់ចោទ ហេតុនេះតុលាការនឹង ចេញសាលក្រមសម្រេចរឿងឃុំខ្លួនជនជាប់ចោទ ដែលគេហៅថា **សាលក្រមមុនអង្គសេចក្តី**។ សាលក្រមនេះតុលាការ ត្រូវយោងទៅតាមស្មារតីនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួន បណ្តោះអាសន្ន) ក្រៅពីសាលក្រមនេះ តុលាការក៏ត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួនដែរ ក្នុងករណីសម្រេចឱ្យឃុំខ្លួន ព្រោះថាដីកាបង្គាប់ឱ្យឃុំខ្លួនគឺជាបញ្ជាដល់ពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួលនិងឱ្យឃុំខ្លួន[84]។ ប្រសិនបើគ្មានដីកាបង្គាប់ឱ្យឃុំខ្លួនទេ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនមិនអាចមានសិទ្ធិធ្វើការឃុំខ្លួនជននោះបានឡើយ ទោះបីជាមានសាលក្រមហើយក៏ដោយ។ គួរកត់សម្គាល់ផងដែរថា រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះមានលក្ខណៈខុសគ្នាទៅនឹងការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដំណាក់កាលនៃការស៊ើបសួរ ពីព្រោះថាការសម្រេចឃុំខ្លួន នៅក្នុងនីតិវិធីនេះកម្រិតរយៈពេលតែ ២ (ពីរ)សប្តាហ៍តែប៉ុណ្ណោះ។ ក្នុងរយៈពេលពីរសប្តាហ៍គិតចាប់ពីពេលថ្ងៃចេញសាលក្រមមុនអង្គសេចក្តី តុលាការត្រូវបើកសវនាការលើអង្គសេចក្តី ដើម្បីជំនុំជម្រះទៅលើជនជាប់ចោទ ដោយចេញសាលក្រមលើអង្គសេចក្តី ដែលប្រកាសអំពីពិរុទ្ធភាពទៅជនជាប់ចោទ ឬជនជាប់ចោទ ត្រូវបានរួចពីបទចោទ ប្រសិនបើតុលាការយល់ឃើញថាអំពើនោះមិនមែនជាបទល្មើស ឬក៏ជនជាប់ចោទគ្មានកំហុសទេ [85]។ ប្រសិនបើក្នុងរយៈពេលនៃការឃុំខ្លួនពីរសប្តាហ៍នេះ តុលាការមិនបានបើកសវនាការលើអង្គសេចក្តីទេនោះ ជនជាប់ចោទនឹងត្រូវដោះលែងឱ្យនៅក្រៅឃុំឱ្យមានសេរីភាពវិញដោយឯកឯង[86] ។

[84] មាត្រា ២២០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[85] មាត្រា ៣៥០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[86] មាត្រា ៤៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវរួចមក យើងអាចយល់ច្បាស់អំពី តួនាទីរបស់អង្គការអយ្យការក្នុងចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌ ដែលព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដើរតួយ៉ាងសំខាន់នៅក្នុងដំណាក់កាលនៃការចោទប្រកាន់នេះ។ ដូចដែលយើងបានដឹងរួមមកហើយអង្គការអយ្យការ គឺជាស្ថាប័នដ៏សំខាន់មួយនៅក្នុងដំណើរការនៃនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានពង្រាយវត្តមានឱ្យមាននៅគ្រប់ រាជធានី-ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ហើយតួនាទីចម្បងរបស់អង្គការអយ្យការ គឺជាការធ្វើបណ្តឹងអាជ្ញា ឬបណ្តឹងព្រហ្មទណ្ឌ និងថ្លឹងថ្លែងអំពីការធ្វើបណ្តឹងនេះ ក្នុងនាមជាអ្នកតំណាងឱ្យផលប្រយោជន៍សាធារណៈ។ ពោលគឺអង្គការអយ្យការ ត្រូវតែប្រកាន់យកនូវភាពត្រឹមត្រូវ និងយុត្តិធម៌ប្រកបដោយមនសិការវិជ្ជាជីវៈ ក្នុងដំណើរការនៃនីតិវិធីព្រហ្មទណ្ឌ។ អង្គការអយ្យការជាអ្នកធ្វើបណ្តឹងអាជ្ញា ដែលជាអ្នកចោទប្រកាន់រាល់បទល្មើសព្រហ្មទណ្ឌ ដែលប្រកាន់យកគោលការណ៍កាលានុវត្តភាពនៃចោទប្រកាន់ ពុំមែនគោលការណ៍នីត្យានុកូលភាព នៃការចោទប្រកាន់ដូចក្នុងនីតិវិធីព្រហ្មទណ្ឌចាស់ឡើយ។ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌបច្ចុប្បន្នរបស់កម្ពុជា យកមកប្រើប្រាស់សម្រាប់ឱ្យអង្គការអយ្យការធ្វើការពិចារណាមុននឹងធ្វើចំណាត់ការនីតិវិធីដែលនេះស្តែងចេញឱ្យយើងឃើញថា ព្រះរាជអាជ្ញា មានឆន្ទានុសិទ្ធិក្នុងការធ្វើការចោទប្រកាន់ ឬមិនធ្វើការចោទប្រកាន់ (ការតម្កល់រឿងទុកឥតចាត់ការ) រាល់អំពើដែលជាបទល្មើសព្រហ្មទណ្ឌ។ វាគឺជាគោលការណ៍មួយក្នុងនីតិវិធីព្រហ្មទណ្ឌដែលផ្តល់សិទ្ធិអំណាចដល់ព្រះរាជអាជ្ញា ធ្វើការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹងនិងពាក្យបណ្តឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលបញ្ជូនមក ដើម្បីសម្រេចថាតើគួរតែតម្កល់រឿងទុកឥតចាត់ការ ឬគួរធ្វើការចោទប្រកាន់ទៅលើជនណាម្នាក់ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ដែលគេអាចហៅបានថាជា **ជម្រើសនៃការចោទប្រកាន់**។ ជម្រើសនៃការចោទប្រកាន់ អាចធ្វើឡើងតាមវិធីដូចជា៖ ការបញ្ជូនរឿងក្តីទៅចៅក្រមស៊ើបសួរ គឺការបើកការស៊ើបសួរ ឬការបញ្ជូនរឿងក្តីទៅតុលាការជំនុំជម្រះតែម្តង ដែលមាន ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងតាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម។ ជម្រើសនៃការចោទប្រកាន់ បានបើកផ្លូវឱ្យព្រះរាជអាជ្ញាមានមធ្យោបាយច្រើនក្នុងការធ្វើបណ្តឹងអាជ្ញាដោយអាស្រ័យលើស្ថានភាពនៃសំណុំរឿង និងប្រភេទនៃបទល្មើស។

ជារួមមក អង្គការអយ្យការ ជាតួអង្គដែលមិនអាចខ្វះបាននៅក្នុងដំណើរការនៃនីតិវិធីព្រហ្មទណ្ឌ ដែលមានតួនាទីធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងការសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។

# អនុសាសន៍

# អនុសាសន៍

អង្គការអយ្យការ គឺជាស្ថាប័នមួយសម្រាប់ដំណើរការនៃបណ្តឹងអាជ្ញា ឬបណ្តឹងព្រហ្មទណ្ឌជាស្ថាប័ន ដែលត្រូវបានដាក់ពង្រាយឱ្យមានអមតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែល ដើរតួយ៉ាងសំខាន់ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដើម្បីអោយមានតម្លាភាព និងប្រកបដោយភាពយុត្តិធម៌។ តាម រយៈការសិក្សាស្រាវជ្រាវ ប្រធានបទស្តីពី **ចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌរបស់អង្គការអយ្យការអមសាលាដំបូង** យើងសង្កេតឃើញថា អង្គការអយ្យការពិតជាតួអង្គដ៏សំខាន់ដែលមិនអាចខ្វះបានឡើយនៅក្នុងរឿងក្តី ព្រហ្មទណ្ឌ ដែលតំណាងដោយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលបានបំពេញការងារប្រកបដោយភាព យុត្តិធម៌។

ប៉ុន្តែទោះបីជាយ៉ាងណាក៏នៅមានចំណុចមួយចំនួនដែលត្រូវធ្វើដើម្បីអោយមានភាពល្អប្រសើរជាង នេះទៅទៀត ដូច្នេះហើយនៅត្រង់ចំណុចនេះ ក្នុងនាមខ្ញុំជាបញ្ញវន្តផ្នែកច្បាប់ ខ្ញុំសូមគោរពដើម្បីបញ្ចេញនូវមតិ យោបល់ និងការសំណូមពរដល់មន្ត្រីដែលមានតួនាទីនិងភារកិច្ចក្នុងស្ថាប័នអយ្យការតម្រូវឱ្យមានដូចតទៅៈ

- មានចំណេះដឹងខ្ពង់ខ្ពស់ខាងផ្នែកនីតិសាស្ត្រទាក់ទងនឹងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ
- ក៏ដូចជាចំណេះដឹងទូទៅក្នុងសង្គមជាតិទាំងមូលផងដែរ និង
- ត្រូវប្រកាន់ភ្ជាប់ឱ្យបាននូវក្រមសីលធម៌វិជ្ជាជីវៈ
- ត្រូវស្វែងរកភស្តុតាងឱ្យបានល្អិតល្អន់
- ត្រូវគោរពតាមនីតិវិធីដែលមានចែងក្នុងច្បាប់ឱ្យបានខ្ជាប់ខ្ជួន
- ការចោទប្រកាន់ត្រូវតែមានសុក្រឹត្យភាព និងភាពស្មើភាពគ្នារវាងបុគ្គល
- ពោលគឺមិនត្រូវខ្លាចអំណាចរបស់បុគ្គលណាមួយដែលមានអំណាចឡើយ គឺត្រូវចោទប្រកាន់តាមអ្វី ដែលខ្លួនយល់ឃើញថាត្រឹមត្រូវតាមច្បាប់។

ព្រោះដើម្បីធានាដល់ការអនុវត្តនីតិវិធីព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធភាព ភាពត្រឹមត្រូវនិងយុត្តិធម៌ ជូនប្រជា ជនកម្ពុជា ។

# ឯកសារយោង

# ឯកសារយោង

## ១.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ១៩៩៣ បោះពុម្ពឡើងវិញដោយ អគ្គលេខាធិការនៃរដ្ឋសភា ឆ្នាំ២០១៥
- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ មិថុនា ២០០៩
- ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧
- ក្រមនីតិវិធីព្រហ្មទណ្ឌចាស់ ឆ្នាំ១៩៩៣
- ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥
- យោងតាម ក្រឹត្យលេខ ១៤២/៧៣/បសខ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៣
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, នស/រកម/០៧១៤/០១៥, ប្រកាសឱ្យប្រើនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤
- ច្បាប់ស្តីពីសហលក្ខខន្តិកៈមន្ត្រីរាជការស៊ីវិល
- គោលការណ៍ណែនាំ ស្តីពី តួនាទីរបស់ព្រះរាជអាជ្ញា ដែលអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ស្តីអំពីការបង្ការបទឧក្រិដ្ឋ និងគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា នៃប្រទេសគុយបា នៅថ្ងៃទី ២៧ ខែ សីហា ដល់ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ១៩៩០

## ២.សៀវភៅ

- សៀវភៅមេរៀនស្តីអំពី នីតិវិធីព្រហ្មទណ្ឌ របស់លោកសាស្ត្រាចារ្យ **មីន សំអុល**
- សៀវភៅមេរៀនស្តីអំពី នីតិព្រហ្មទណ្ឌពិសេស របស់សាស្ត្រាចារ្យ **មីន សំអុល**
- សៀវភៅស្តីពី អង្គការអយ្យការ (ប្រវត្តិ និងការសិក្សាប្រៀបធៀប) របស់លោក **កុយ នាម** និង លោក **ឡុង បញ្ញាវុធ** បោះពុម្ព ឆ្នាំ២០០៦
- អំពីច្បាប់,សិទ្ធិមនុស្ស និងរឿងក្តីត្រកូលយេន ក្នុងសៀវភៅ កម្ពុជាបន្ទាប់ពីរបបខ្មែរក្រហម របស់លោក អេវិន ហ្គតស្មាន់

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី ១៖** ដីកាបង្គាប់ឱ្យស៊ើបអង្កេតបឋម

**ឧបសម្ព័ន្ធទី ២៖** កំណត់ហេតុទទួលវត្ថុតាង

**ឧបសម្ព័ន្ធទី ៣៖** កំណត់ហេតុស្តាប់ចម្លើយ

**ឧបសម្ព័ន្ធទី ៤៖** ដីកាកោះ

**ឧបសម្ព័ន្ធទី ៥៖** ដីកាផ្ទេរសមត្ថកិច្ច

**ឧបសម្ព័ន្ធទី ៦៖** លិខិតអញ្ជើញ

**ឧបសម្ព័ន្ធទី ៧៖** លិខិតជូនដំណឹង

**ឧបសម្ព័ន្ធទី ៨៖** ដីកាតម្កល់រឿងទុកឥតចាត់ការ

**ឧបសម្ព័ន្ធទី ៩៖** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

**ឧបសម្ព័ន្ធទី ១០៖** ដីកាសន្និដ្ឋានសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ

**ឧបសម្ព័ន្ធទី ១១៖** ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

**ឧបសម្ព័ន្ធទី ១២៖** ដីកាសម្រេចឱ្យយកជនជាប់ចោទមកជំនុំជម្រះ

**ឧបសម្ព័ន្ធទី ១៣៖** កំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

**ឧបសម្ព័ន្ធទី ១៤៖** ដីកាសន្និដ្ឋានស្ថាពរ

**ឧបសម្ព័ន្ធទី១**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៛

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

*លេខ៖*

# ដីកាបង្គាប់ឲ្យស៊ើបអង្កេតបឋម

+++++

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញរបាយការណ៍លេខៈ .../១១ តពទ.បជ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ របស់សាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ ។

-បានឃើញសុំណុំរឿងព្រហ្មទណ្ឌលេខៈ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ ។

-បានឃើញមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាលឱ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧។

**សម្រេច**

**១**-បង្គាប់ឱ្យសាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ បើកការស៊ើបអង្កេតបឋម លើករណីឈ្មោះ ... ហើយឱ្យឈ្មោះ ... បង់ប្រាក់ពិន័យអន្តរកាលទៅតាមនីតិវិធី។

**២**-ពេលស៊ើបអង្កេតចប់បញ្ជូនសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យវិញ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ ... ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី២**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការ**
អមសាលាដំបូង
ខេត្តបន្ទាយមានជ័យ

## កំណត់ហេតុឧទ្ទលវត្ថុតាង

ឆ្នាំពីរពាន់ដប់បី ខែ ... ថ្ងៃទី ពីរ វេលាម៉ោង ដប់ និង សូន្យ នាទី ។
យើង ...ក្រឡាបញ្ជីនៃអយ្យការ អមសាលាដំបូងខេត្តបន្ទាយមានជ័យ ។
លោក ... ជាមន្ត្រីនគរបាលយុត្តិធម៌នៃស្នងការនគរបាលខេត្តបន្ទាយមានជ័យ
ជាអ្នកប្រគល់រួមជាមួយនិងឈ្មោះ ....ឈ្មោះ ....ឈ្មោះ ...ពីបទៈជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសាធាតុញៀន

បានពិនិត្យកំនភាគវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ឃើញដូចខាងក្រោមៈ

១-កញ្ចប់ពណ៌សបិទជិតមានស្នាមមេដៃឈ្មោះ ....ឈ្មោះ ...និងហត្ថលេខាលោក ...លោក ...និងលោក ... ។

២-ទូរស័ព្ទចំនួន ០៦ គ្រឿង មួយគ្រឿងម៉ាក់ SAMSUNG ពណ៌ខ្មៅស៊ីមពីរ(ចិន) .មួយគ្រឿងម៉ាក់NOKIA E99I ពណខ្មៅស៊ីមពីរ(ចិន) .មួយគ្រឿងម៉ាក់ NOKIA X1 ពណ៌ខ្មៅ(ចិន) .មួយគ្រឿងទៀតម៉ាក់ NOKIA ចុចពិលពណ៌ផ្កាឈូកលាយពណ៌ស (ចាស់) .មួយគ្រឿងម៉ាក់ NOKIA ចុចពិលពណ៌ខ្មៅបិទស្កុតពណ៌ទឹកប្រាក់ និងមួយគ្រឿងទៀតម៉ាក់ HUAWEI ពណ៌ខ្មៅលាយពណ៌ស។

៣-កាបូបលុយចំនួនមួយពណ៌ខៀវ(គ្មានលុយ).ដែកកេះចំនួនពីរ.កាបូបស្ពាយតូចចំនួនមួយពណ៌ប្រផេះ.សំបកប្រអប់ស្រោមអនាម័យOKចំនួនមួយ.ថង់តូចពណ៌សមួយចំនួន.បំពុងទុយយចំនួនពីរ.កំរបដបទឹកចោះដាក់ទុយយមួយ។

៤-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចំនួនពីរ.មួយមានលេខៈ...របស់ឈ្មោះ...និងមួយទៀតមានលេខៈ... របស់ឈ្មោះ ...។

៥-លុយខ្មែរចំនួន ៥០០០០ រៀល និងលុយដុល្លារចំនួន ១០ ដុល្លារ។

៦-ម៉ូតូមួយគ្រឿងម៉ាក់ VIVA ពណ៌ខ្មៅសេរីឆ្នាំ ២០១០ គ្មានកញ្ចក់ .គ្មានកន្រ្តក ពាក់ផ្លាក់លេខៈ ...លេខម៉ាស៊ីន ...។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោង ដប់និងសែសិប នាទី នាថ្ងៃ ខែឆ្នាំដដែល ។

អ្នកប្រគល់ ក្រឡាបញ្ជី ជនជាប់សង្ស័យ

បានឃើញ
បន្ទាយមានជ័យ.ថ្ងៃទី ... ខែ ...ឆ្នាំ ២០១៣
**ព្រះរាជអាជ្ញារង**

**ឧបសម្ព័ន្ធទី៣**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តពោធិ៍សាត់**

*សំណុំរឿង៣ហ្វទណ្ឌ*

*លេខ............*

*ចុះថ្ងៃទី ... ខែ... ឆ្នាំ២០១៦*

# កំណាត់ហេតុស្តាប់ចម្លើយ

ឆ្នាំ ពីរពាន់ដប់ប្រាំមួយ ខែធ្នូ ថ្ងៃទីពីរ វេលាម៉ោង ដប់ និងសូន្យ នាទី។

យើង ...ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់ អមដោយលោកជាក្រឡាបញ្ជី ។

យើងបានស្តាប់ចម្លើយឈ្មោះ...ជាជនសង្ស័យដោយមានលោក...ជាមេធាវីការពារ។

បានមកបង្ហាញខ្លួន នៅចំពោះមុខយើង ដែលមានអត្តសញ្ញាដូចខាងក្រោម:

នាមត្រកូល ៖ ... នាមខ្លួន ៖ ...

ភេទ: ប្រុស

កើតថ្ងៃទី ៖ អាយុ ... ឆ្នាំ

ទីកន្លែងកំណើត ៖ភូមិ...ខេត្តពោធិ៍សាត់

អាសយដ្ឋាន ៖ភូមិ...ខេត្តពោធិ៍សាត់

មុខរបរ ៖ ...

សាសនា: ព្រះពុទ្ធ

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ... "រ" ម្តាយឈ្មោះ ៖ ... "រ"

អនីតិជន ☐ ឬ នីតិជន ☐

ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន

ជននេះ ៖ ☐ ចេះនិយាយ ☐ ចេះអាន ☐ ចេះសរសេរអក្សរខ្មែរ

ជននេះ ៖ ☐ មិនចេះនិយាយ ☐ មិនចេះអាន ☐ មិនចេះសរសេរអក្សរខ្មែរ

**សួរ-ឆ្លើយ៖** នៅថ្ងៃទី... ខែ... ឆ្នាំ២០១៦ វេលាម៉ោងប្រហែលជា២១ជាង មិត្តភក្តិរបស់ខ្ញុំមានគ្នាបីនាក់ ១.ឈ្មោះ ...២.... ៣.ឈ្មោះ ... ជិះម៉ូតូ០២គ្រឿងមកបបួលខ្ញុំនៅផ្ទះ

នៅភូមិ...ខេត្តពោធិ៍សាត់ ថាទៅដុតត្រីហួប ពេលនោះខ្ញុំនិងមិត្តភក្តិរៀបចេញដំណើរ ស្រាប់តែសមត្ថកិច្ចមកដល់ ហើយបានហៅពួកខ្ញុំទាំងបួននាក់ មកអធិការដ្ឋាននគរបាលក្រុងពោធិ៍សាត់ សមត្ថកិច្ចបានឆែកឆេរក្នុងម៉ូតូ របស់ខ្ញុំ ឃើញមានក្រដាសអាលុយមីញ៉ូម ហើយទុយយូមួយដើម និងពិនិត្យទឹកនោមខ្ញុំ ឃើញមានសារធាតុញៀន ។

**សួរ.ឆ្លើយ៖** ខ្ញុំធ្លាប់ប្រើប្រាស់ថ្នាំញៀន ហើយប្រើប្រាស់លើកចុងក្រោយមុនថ្ងៃចាប់ខ្លួនពីរឬបីថ្ងៃ ប្រើម្នាក់ឯងក្នុងផ្ទះរបស់ខ្ញុំ។ថ្នាំញៀនដែលខ្ញុំប្រើប្រាស់នេះ ទិញពីឈ្មោះ ... ណាត់យកមកឲ្យនៅផ្លូវ...ខេត្តពោធិ៍សាត់ ទិញតំលៃ៣ម៉ឺនរៀល។

**សួរ.ឆ្លើយ៖** ពួកម៉ាកបីនាក់ទៀត សមត្ថកិច្ចបានឆែកឆេរអត់ឃើញមានអីពាក់ ពន្ធ័បានឲ្យទៅផ្ទះវិញ ។

**សួរ.ឆ្លើយ៖** ខ្ញុំមិនដែលរកស៊ីជួញដូរ និងចែកចាយថ្នាំញៀនទេ។

**សួរ.ឆ្លើយ៖** នៅក្នុងថ្ងៃខែមិនចាំ ក្នុងឆ្នាំ... ពេលយប់មិនចាំម៉ោង ខ្ញុំបានជិះម៉ូតូម៉ាកស៊ីរូស អត់មានផ្លាកលេខ ចេញពីផ្ទះដើម្បីទៅទិញមីនិងបារីជក់ ពេលជិះមកដល់ស្ពានដែក (ផ្លូវរថភ្លើង) តាមផ្លូវមាត់ស្ទឹង ស្រាប់តែមានរថយន្តតូចមួយគ្រឿង បានជិះមកគៀរម៉ូតូរបស់ខ្ញុំបណ្តាលឲ្យដួល ហើយឃើញគេចុះពីលើឡានរួចស្រែកឲ្យខ្ញុំឈប់ ឃើញដូឆ្នេះខ្ញុំក៏រត់ចោលម៉ូតូ មកដេកផ្ទះ ។

**សួរ.ឆ្លើយ៖** ពេលបាត់ម៉ូតូខ្ញុំមិនបានប្តឹងសមត្ថកិច្ចទេ ក្រោយមកលឺដំណឹងថាម៉ូតូរបស់ខ្ញុំ នៅប៉េអឹមហើយពាក់ពន្ធ័និងថ្នាំញៀន លឺដូចឆ្នេះខ្ញុំមិនហ៊ានទៅសុំម៉ូតូវិញទេ ព្រោះខ្លាចគេចោទ ថាជួញដូរថ្នាំញៀន ។

**សួរ.ឆ្លើយ៖** ពេលខ្ញុំរត់ចោលម៉ូតូ ខ្ញុំមិនមានថ្នាំញៀនទេហើយថ្នាំញៀនដែលសមត្ថកិច្ចដកហូតបាន ខ្ញុំមិនដឹងថាជារបស់អ្នកណាឡើយ ។

*បញ្ចប់កំណត់ហេតុវេលាម៉ោង ដប់ និង សែសិបប្រាំនាទី នាថ្ងៃ ខែ ឆ្នាំ ដដែល។*

យើងបានប្រាប់ជននេះឱ្យអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុង កំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ផ្តិតម្រាមដៃលើកំណត់ហេតុនេះ ។

បានអានចប់សព្វគ្រប់ ហើយជននេះមិនមានបដិសេធចំណុចណាទេ និង ចុះហត្ថលេខា ឬ ផ្តិតម្រាម ដៃជាមួយយើង ។

**អ្នកឆ្លើយ** **ក្រឡាបញ្ជី** **ព្រះរាជអាជ្ញារង**

**ឧបសម្ព័ន្ធទី៤**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូង ខេត្តពោធិ៍សាត់**
សំណុំរឿងព្រហ្មទណ្ឌលេខ ...
ចុះថ្ងៃទី ... ខែ ... ឆ្នាំ...

**ដីកាកោះ**

យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

បង្គាប់មកឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំ ជាសាក្សី ។

ទីលំនៅបច្ចុប្បន្ននៅភូមិ...ខេត្តពោធិ៍សាត់ ។

ឱ្យចូលទៅកាន់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

នៅវេលាម៉ោង២០០ រសៀល ថ្ងៃទី ... ខែ... ឆ្នាំ... ។

ដើម្បី **សួរយកចម្លើយ**

ពីដំណើររឿង **បង្ក្រាបបទល្មើសព្រៃឈើ កាលពីថ្ងៃទី ... ខែ... ឆ្នាំ ... នៅចំណុច...ភូមិ...ខេត្តពោធិ៍សាត់។**

សាមីខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងរឿង ខាងលើ មកជាមួយផងប្រសិនបើមាន។

ធ្វើនៅពោធិ៍សាត់, ថ្ងៃទី ... ខែ ... ឆ្នាំ ...

**ព្រះរាជអាជ្ញារង**

*យើង...........................................................................បានប្រគល់ដីកាកោះនេះដល់*

*ឈ្មោះ......................................ទីលំនៅបច្ចុប្បន្ននៅភូមិ...................... ឃុំ/សង្កាត់*
*.............................................. ស្រុក/ខណ្ឌ...................ខេត្ត/ក្រុង............................នៅថ្ងៃទី*
*.........ខែ...................ឆ្នាំ.........................................ហើយយើងបានប្រាប់ថា ឱ្យយកចុង*
*ដីកានេះទៅ ប្រគល់ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះ មុខសាលា*
*ដំបូងខេត្តពោធិ៍សាត់។*

**អ្នកទទួល** **អ្នកប្រគល់**

**ហត្ថលេខា ឬ ស្នាមមេដៃ**

**ឧបសម្ព័ន្ធទី៥**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**៣៧**

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

*លេខ៖*

# ដីកាផ្ទេរសមត្ថកិច្ច

+++++

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ ។

-បានឃើញមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧។

**សម្រេច**

**១**-បង្គាប់ឱ្យសាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ បើកការស៊ើបអង្កេតបឋម លើករណីឈ្មោះ ... ហើយឱ្យឈ្មោះ ... បង់ប្រាក់ពិន័យអន្តរកាលទៅតាមនីតិវិធី។

**២**-ពេលស៊ើបអង្កេតចប់បញ្ជូនសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យវិញ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ មករា ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តពោធិ៍សាត់**
លេខ......................អយ/១៧

**លិខិតអញ្ជើញ**

**យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត**

អញ្ជើញ លោក ... ភេទប្រុស ជានាយកមន្ទី... ។

ឱ្យចូលទៅកាន់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

នៅវេលាម៉ោង ២.០០ រសៀល ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៧ ។

ដើម្បី បំភ្លឺ ពីដំណើររឿង **បង្ក្រាបបទល្មើសព្រៃឈើ កាលពីថ្ងៃទី... ខែ... ឆ្នាំ ២០១៦ នៅចំណុច... ភូមិ... ឃុំ... ស្រុក... ខេត្តពោធិ៍សាត់ ។**

សាមីខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងរឿង ខាងលើ មកជាមួយផងប្រសិនបើមាន។

ធ្វើនៅពោធិ៍សាត់, ថ្ងៃទី ... ខែ ....ឆ្នាំ ២០១៧

**ព្រះរាជអាជ្ញារង**

យើង...............................................................បានប្រគល់ដីកាអញ្ជើញនេះដល់

ឈ្មោះ..................................ទីលំនៅបច្ចុប្បន្ននៅភូមិ................... ឃុំ/សង្កាត់

.......................................... ស្រុក/ខណ្ឌ................ខេត្ត/ក្រុង..........................នៅថ្ងៃទី

.........ខែ..................ឆ្នាំ.....................................ហើយយើងបានប្រាប់ថា ឱ្យយកចុងដីកា

នេះទៅ ប្រគល់ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះ មុខសាលាដំបូងខេត្ត

ពោធិ៍សាត់។

**អ្នកទទួល** **អ្នកប្រគល់**

**ហត្ថលេខា ឬ ស្នាមមេដៃ**

**ឧបសម្ព័ន្ធទី៧**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការ អម
សាលាដំបូងខេត្ត ពោធិ៍សាត់

លេខ..................

# លិខិតជូនដំណឹង

យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

សូមជូនដំណឹងលោក ... អាយុ ... ឆ្នាំ មានទីលំនៅ ភូមិ.... ឃុំ... ស្រុក... ខេត្តបាត់ដំបង អោយបានជ្រាបថា:

ពាក្យបណ្តឹងរបស់លោក ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៣ ដែលបាន ប្តឹងលោក ... អាយុ...ឆ្នាំមានទីលំនៅភូមិ... ឃុំ... ស្រុក... ខេត្តកំពង់ឆ្នាំង ថា: **បានបង្កគ្រោះថ្នាក់ចរាចរណ៍** ប្រព្រឹត្តនៅភូមិ... ឃុំ... ស្រុក... ខេត្តពោធិ៍សាត់ ដែលមានសំណុំរឿងព្រហ្មទណ្ឌ លេខ:... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៣ នោះត្រូវបានតំណាងអយ្យការតម្កល់រឿងទុកឥតចាត់ការ តាមដីការតម្កល់រឿងទុកឥតចាត់ការ លេខ:... អយ/១៦ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ ហើយ សូមលោកជ្រាប។

លោកមានសិទ្ធិប្តឹងតវ៉ារយ:ពេលពីរខែគិតចាប់ពីថ្ងៃលោកបានទទួលដំណឹងនេះ។

ពោធិ៍សាត់, ថ្ងៃទី... ខែ... ឆ្នាំ ២០១៦

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី៨**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ.........................

# ដីកាតម្កល់រឿងទុកឥតចាត់ការ

យើង ...........តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ:...................ចុះថ្ងៃទី........ខែ.........ឆ្នាំ២០១.... .របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា។

**១- អវត្តមានបទល្មើស**

☐ ១.១. អវត្តមានបទល្មើស

**២- ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់**

☐ ២.១. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

**៣- មូលហេតុគតិយុត្ត**

☐ ៣.១. ការដកពាក្យបណ្តឹង

☐ ៣.២. ការលើកលែងទោសជាទូទៅ

☐ ៣.៣. មរណភាពជនល្មើស

☐ ៣.៤. ផុតអាជ្ញាយុកាល

☐ ៣.៥. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

☐ ៣.៦. អាជ្ញាអស់ជំនុំ

☐ ៣.៧. ការសម្របសម្រួលជាមួយរដ្ឋ

☐ ៣.៨. ការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្របសម្រួល

☐ ៣.៩. អភ័យឯកសិទ្ធ

☐ ៣.១០. អនិយ័តភាពនៃនីតិវិធី

☐ ៣.១១. ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

**៤- ការចោទប្រកាន់មិនផ្តល់ប្រយោជន៍**

☐ ៤.១. ការស្វែងរកមិនបានផល

☐ ៤.២. ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[2]

☐ ៤.៣ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

☐ ៤-៤ ការខកខានរបស់ដើមបណ្តឹង

☐ ៤.៥. អាកប្បកិរិយារបស់ជនរងគ្រោះ

☐ ៤.៦. ជនរងគ្រោះមិនចាប់អារម្មណ៍ នឹងបទល្មើស

☐ ៤.៧. និយ័តកម្មដោយឯកឯង[3]

☐ ៤.៨. ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស

**៥- នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា**

☐ ៥.១. ការជួសជុលការខូចខាតដោយ/ដល់អនីតិជន

☐ ៥.២. សន្ទានកម្ម[4]

☐ ៥.៣. អធិបញ្ញាផ្តល់ការព្យាបាល

☐ ៥.៤. ជនរងគ្រោះ/ដើមបណ្តឹងបោះបង់បណ្តឹង
តាមការស្នើសុំរបស់ព្រះរាជអាជ្ញា

☐ ៥.៥. និយ័តកម្មតាមសំណើររបស់ព្រះរាជអាជ្ញា

☐ ៥.៦. ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន[5]

☐ ៥.៧. ការកំណត់ទិសដៅចំពោះរចនាសម្ព័ននៃសុខភាព នៃសង្គម ឬវិជ្ជាជីវៈ

☐ ៥.៨. ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

**៦- នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗ**

---

[1] ) ដូចជាមូលហេតុ វិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

[2] ) ដើមបណ្តឹងឈប់ប្តឹង

[3] ) សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និង ស្តារស្ថានភាពឡើងវិញ

[4] ) ករណីចែងដោយច្បាប់

[5] ) ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើស តាមកំណត់ច្បាប់ និងធ្វើការព្រមានឲ្យឈប់ប្រព្រឹត្ត

[6] ) ករណីចែងដោយច្បាប់

☐ ៦.១. ការចោទប្រកាន់ ឬទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

**៧-ជនល្មើសមិនត្រូវបានស្គាល់**

☐ ៧.១. ជនល្មើសមិនត្រូវបានស្គាល់

**៨-ជំនួយការអប់រំ**

☐ ៨.១. ការផ្ដល់ជំនួយការអប់រំជំនួសការចោទប្រកាន់

**ការអង្កេតផ្សេងៗ ៖**កាលពីថ្ងៃទី.......................................................................

.......................................................................................................................................

.......................................................................................................................

**បានឃើញ:**

-កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងឈ្មោះ

-កំណត់ហេតុស្ដាប់ចម្លើយជនសង្ស័យឈ្មោះ ។

-ពាក្យស្នើសុំដកបណ្ដឹងរបស់ឈ្មោះ ចុះថ្ងៃទី ...........ខែ ........... ឆ្នាំ ...........។

**យល់ឃើញថា:**

-តាមចម្លើយរបស់ដើមបណ្ដឹងឈ្មោះ

**ហេតុដូច្នេះ សម្រេច**

-តម្កល់រឿងព្រហ្មទណ្ឌលេខ ........... ថ្ងៃទី ..... ខែ ........... ឆ្នាំ ........... ទុកឥតចាត់ការតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី... ខែ....... ឆ្នាំ........

**ព្រះរាជអាជ្ញារង**

**ឧបសម្ព័ន្ធទី៩**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្ត
*ពោធិ៍សាត់*
*លេខ៖..........*

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង ........... តំណាងអយ្យការអម សាលាដំបូងខេត្ត ពោធិ៍សាត់
បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ .... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១...
បានឃើញរបាយការណ៍របស់អធិការដ្ឋាននគរបាលស្រុកក្រគរ លេខ: ...
ចុះថ្ងៃទី... ខែ... ឆ្នាំ២០១... ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា មានតម្រុយសន្នតបានថា:**

១-នាមត្រកូល ៖ ... នាមខ្លួន ...........ហៅតា ភេទ...

អាយុ ៖ ....ឆ្នាំ

ទីកន្លែងកំណើត៖ ...........................................................................

អាសយដ្ឋាន ៖ ...........................................................................

មុខរបរ ៖ ...

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ..............

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖........... "ស" ម្តាយឈ្មោះ ៖ ........... "ស"

អនីតិជន ☐ ឬ នីតិជន ☐

២-នាមត្រកូល ៖........... នាមខ្លួន ........... ភេទ...........

អាយុ ៖ ...........ឆ្នាំ

ទីកន្លែងកំណើត៖ ...........................................................................

អាសយដ្ឋាន៖ ...........................................................................

មុខរបរ ៖ ...........

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ...........

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ........... "ស" ម្តាយឈ្មោះ ៖ ........... "ស"

អនីតិជន ☐ ឬ នីតិជន ☐

៣-នាមត្រកូល ៖ ........... នាមខ្លួន ........... ភេទ...........

អាយុ ៖ ...........ឆ្នាំ

ទីកន្លែងកំណើត៖ ...........................................................................

អាសយដ្ឋាន ៖ ...........................................................................

មុខរបរ ៖ ...........

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ...........

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ........... "ស" ម្តាយឈ្មោះ ៖ ........... "ស"

អនីតិជន ☐ ឬ នីតិជន ☐

## បានប្រព្រឹត្តអំពើដូចតទៅ ៖

កាលពីថ្ងៃទី........... ខែ...........ឆ្នាំ........... វេលាម៉ោង...........និង...........នាទី មានបទល្មើស........... ........... ...........នៅតំបន់........... ........... ស្ថិតនៅភូមិ...........ឃុំ...........ស្រុក........... ខេត្តពោធិ៍សាត់ បង្កឡើងដោយជនសង្ស័យចំនួន០៧នាក់ ១.ឈ្មោះ...........ភេទ........... អាយុ ...........ឆ្នាំ ជា...........២.ឈ្មោះ ........... ភេទ........... ហៅ........... ភេទ........... អាយុ ...........ឆ្នាំ ៣.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ ៤.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ ៥.ឈ្មោះ ........... ភេទ........... អាយុ...........ឆ្នាំ ៦.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ ៧.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ។ ពេលទទួលបានបណ្តឹងពីប្រជាពលរដ្ឋ លោកអធិការបានបញ្ជាឲ្យលោកអធិការរងទទួលផែនការយុត្តិធម៌ ដឹកនាំផ្នែកជំនាញ ដោយសហការជាមួយប៉ុស្តិ៍........... ចុះទៅកន្លែងកើតហេតុដើម្បីធ្វើការស្រាវជ្រាវ បន្ទាប់ពីទៅដល់កន្លែងកើតហេតុលោកអធិការរងទទួលផែនការយុត្តិធម៌ ដឹកនាំផ្នែកជំនាញ និងប៉ុស្តិ៍........... ធ្វើការស្រាវជ្រាវកំណត់មុខសញ្ញា ។លុះដល់ថ្ងៃទី........... ខែ........... ឆ្នាំ........... កំលាំងអធិការដ្ឋាននគរបាលស្រុក........... ធ្វើការឃាត់ខ្លួន ១.ឈ្មោះ........... ភេទ........... អាយុ ...........

ឆ្នាំ ជាប្រធានអង្គការ............ ២.ឈ្មោះ ............ភេទ............ ហៅ............ភេទ............ អាយុ ............ឆ្នាំ ៣.ឈ្មោះ ............ ភេទ............ អាយុ............ឆ្នាំ ៤.ឈ្មោះ ............ ភេទ ............ អាយុ ............ឆ្នាំ ៥.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ ៦.ឈ្មោះ ............ ភេទ............ អាយុ ............ឆ្នាំ ៧.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ ០៦នាក់ជាសមាជិក............។

អំពើខាងលើជាបទល្មើស៖ កំហែងយក តាមមាត្រា ៣៦៣,៣៦៤ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅ............ ស្ថិតនៅភូមិ............ឃុំ............ស្រុក............ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី............ខែ............ ឆ្នាំ............។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**សម្រេច ៖**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង:

1.ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើ ៖

ក. ឈ្មោះ ............ហៅ............ អាយុ ............ឆ្នាំ

ខ.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ

គ.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ

ឃ.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ

ង.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ

ច.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ

ឆ.ឈ្មោះ ............ភេទ............ អាយុ ............ឆ្នាំ

ពីបទ៖ កំហែងយក តាមមាត្រា ៣៦៣,៣៦៤ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅ ........................ ស្ថិតនៅភូមិ........... ............ ............ ............ ............ .............កាលពីថ្ងៃទី ............ ខែ............ ឆ្នាំ............។

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ធ្វើនៅពោធិ៍សាត់,ថ្ងៃទី........ ខែ ........ ឆ្នាំ ............

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី១០**

អយ្យការ អម

សាលាដំបូងខេត្តបន្ទាយមានជ័យ

សំណុំរឿងព្រហ្មទណ្ឌ

លេខ:

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ដីកាសន្និដ្ឋានសុំដល់ចៅក្រមស៊ើបសួរកុំឲ្យស៊ើបសួរ

យើង ...តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ:...ចុះថ្ងៃទី...ខែ ...ឆ្នាំ ២០១២របស់ អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ មាត្រា១៣៧ មាត្រា១៣៨ និង មាត្រា១៣៩នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណា ចក្រកម្ពុជា។

-បានឃើញ ដីកាសម្រេចលេខៈ...ព.ស/ព្រ.ទ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១២របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ លើពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

## ក្រោយពីបានពិនិត្យឯកសារខាងលើ:

**០១**-នាមត្រកូល និងនាមខ្លួន: ...
ភេទប្រុស អាយុ ...ឆ្នាំ សញ្ជាតិ...
ទីកន្លែងកំណើត: ខេត្ត...
ទីលំនៅបច្ចុប្បន្ន: ភូមិ...ខេត្តបន្ទាយមានជ័យ
មុខរបរ: នៅផ្ទះ (ចាស់ជរា) សាសនា ព្រះពុទ្ធ
ប្រពន្ធឈ្មោះ ... (ស្លាប់)
ឪពុកឈ្មោះ ... (ស) ម្តាយឈ្មោះ ... (ស)
នីតិជន ☑ ឬអនីតិជន □

**០២**-នាមត្រកូល និងនាមខ្លួន: ...
ភេទប្រុស កើតថ្ងៃទី ... ខែ... ឆ្នាំ ... សញ្ជាតិខ្មែរ
ទីកន្លែងកំណើត: ភូមិ...ខេត្តស្វាយរៀង
ទីលំនៅបច្ចុប្បន្ន: ភូមិ... ខេត្តបន្ទាយមានជ័យ
មុខរបរ: ...សាសនា ព្រះពុទ្ធ
ប្រពន្ធឈ្មោះ ...

ឪពុកឈ្មោះ ... (ស) ម្ដាយឈ្មោះ ... (រ)
នីតិជន ☑ ឬអនីតិជន □

**ការសង្កេតផ្សេងៗ៖**

កាលពីថ្ងៃទី ...ឈ្មោះ ...ហៅ ...ភេទប្រុស បានមកដាក់ពាក្យប្ដឹងនៅ អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ដោយប្ដឹងឈ្មោះ ...ថា៖ បានធ្វើ និង ប្រើប្រាស់នូវឯកសារក្លែងក្លាយលើពាក្យស្នើ សុំដីស្រែ ចុះថ្ងៃទី...ខែ... ឆ្នាំ១...ដើម្បីយកមកធ្វើជាឯកសារយោងសំរាប់ចេញប័ណ្ណសំគាល់សិទ្ធកាន់កាប់ អចលនវត្ថុហើយ នៅក្នុងនោះមានឈ្មោះ ...ជាមេឃុំ... បានចូលរួមបញ្ជាក់ និងប្រព្រឹត្តអំពើក្លែងឯកសារនេះ ផងដែរ។ លុះថ្ងៃទី... ខែ... ឆ្នាំ... ឈ្មោះ ...ហៅ ...បានមកដាក់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹង
រដ្ឋប្បវេណីតាមផ្លូវអន្តរាគន៍ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៖... ចុះថ្ងៃទី... ខែ ... ឆ្នាំ... មក ចៅក្រមស៊ើបសួរ ។

**យល់ឃើញថា:**

-ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី
តាមផ្លូវអន្តរាគមន៍ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ៖
... ចុះថ្ងៃទី...ខែ...ឆ្នាំ២... របស់ឈ្មោះ ...ហៅ ...បានប្ដឹងមកចៅក្រមស៊ើបសួរហើយតាមរយៈដីកាសម្រេចលើ
ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីលេខ៖... ចុះថ្ងៃទី... ខែ...ឆ្នាំ... របស់ចៅក្រមស៊ើបសួរបានបញ្ជូនមក
អយ្យការដើម្បីអោយតំណាងអយ្យការធ្វើការពិនិត្យនិងសម្រេច។
បន្ទាប់ពីតំណាងអយ្យការទទួលបានពាក្យ បណ្ដឹងសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ឈ្មោះ ...ហៅ......តាមដីកាបញ្ជូនលេខ៖ ...រប/សលជ.បជ ចុះថ្ងៃទី ... ខែ... ឆ្នាំ ... របស់សាលាដំបូងខេត្តបន្ទាយមានជ័យ និងក្រោយពីបានអង្កេតបឋមរួចរាល់តំណាងអយ្យការបានសម្រេចតម្កល់រឿងទុកឥតចាត់ការលើសំណុំរឿងព្រហ្មទណ្ឌ លេខ ៖ ... ចុះថ្ងៃទី ... ខែ ...ឆ្នាំ ... របស់ អយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ ដោយមូលហេតុផុតអាជ្ញាយុកាលនៃបទល្មើសតាមដីកា លេខ៖... ចុះថ្ងៃទី... ខែ ...ឆ្នាំ...របស់អយ្យការអមសាលាដំបូងខេត្ត បន្ទាយមានជ័យ។

-តាមមាត្រា ១៣៩ (ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា) វាក្យខ័ណ្ឌ៣ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជ អាជ្ញា អាចសុំ ដល់ ចៅក្រមស៊ើបសួរ កុំអោយស៊ើបសួរ លើពាក្យបណ្ដឹងសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ឈ្មោះ...ហៅ ...ដោយហេតុថា៖
នៅក្នុងពាក្យបណ្ដឹងរបស់ឈ្មោះ...បានប្ដឹង ពីឈ្មោះ...និង ឈ្មោះ..
ថាបានក្លែងដោយសិកសៀតអក្សរលើពាក្យ ស្នើ សុំ ដីស្រែ របស់ ឈ្មោះ...ចុះថ្ងៃ ទី... ខែ ... ឆ្នាំ ...

ដែលពាក្យស្នើសុំនេះកើតមានឡើងតាំងពី ឆ្នាំ..... មកម្ល៉េះ ដោយយោងតាមមាត្រា ៦១០ នៃក្រមនីតិវិធី ព្រហ្មទណ្ឌបានចែងថា៖ "អាជ្ញាយុកាលនៃ បណ្ដឹង អាជ្ញា និង អាជ្ញាយុកាលនៃទោស ចំពោះបទល្មើស ដែលត្រូវបានប្រព្រឹត្ត នៅមុនក្រម នេះចូលជា ធរមាន ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃច្បាប់ចាស់" ហេតុនេះ អាជ្ញាយុកាលនៃបទល្មើសត្រូវអនុវត្តតាមច្បាប់ព្រហ្មទណ្ឌអន្តរកាល។ តាមមាត្រា៣០នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាលបានចែងថា" អាជ្ញាយុកាលសំរាប់បទ មជ្ឈិមមានរយៈពេល០៣ឆ្នាំ រីឯអាជ្ញាយុកាលសំរាប់បទ ឧក្រិដ្ឋមានរយៈពេល១០ឆ្នាំ" ដូចនេះនាំអោយផុតអាជ្ញាយុកាលនៃបទល្មើស ព្រោះថា បើគិតរយៈពេល ពីឆ្នាំ១៩៩៥មកដល់ ថ្ងៃដែល ឈ្មោះ ...ហៅ ... បានដាក់ពាក្យប្ដឹងគឺមានរយៈពេល១៦ឆ្នាំហើយ (ប្រសិនបើមើលទៅមាត្រា ១០ នៃក្រមនីតិវិធី ព្រហ្មទណ្ឌវិញ ថិរវេលានៃអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា១៥ ឆ្នាំចំពោះបទឧក្រិដ្ឋ ចំណែកឯ បទមជ្ឈិម រយៈ ពេល ៥ឆ្នាំ ដូចនេះបើតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ អាជ្ញាយុកាលនៃបទល្មើសក៏បានផុតហើយដែរ)កន្លងមក ឈ្មោះ ... ហៅ ... ពុំបានប្ដឹងតវ៉ាអំពីការក្លែងលិខិតនេះដែរ ហេតុនេះ ថេរវេលា នៃ អាជ្ញាយុកាល នៃបណ្ដឹងអាជ្ញាបានផុតហើយ គប្បីរំលត់បណ្ដឹងអាជ្ញា (តាមមាត្រា ៧នៃ ក្រ.ន.ព្រ)។

## ហេតុដូច្នេះសូមសម្រេច

-ស្នើសុំដល់ចៅក្រមស៊ើបសួរ

កុំអោយស៊ើបសួរលើពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី តាមផ្លូវអន្តរាគមន៍ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១២ របស់ឈ្មោះ...ហៅ...ដែលបាន ចុះនៅក្នុង សំណុំរឿងព្រហ្មទណ្ឌ លេខ ៖ ...ចុះថ្ងៃទី ... ខែ ...ឆ្នាំ ២... របស់អយ្យការអមសាលាដំបូងខេត្ត - បន្ទាយមាន ជ័យ ដោយ មូលហេតុនៃការផុតរំលត់អាជ្ញាយុកាលនៃបទល្មើស។

ធ្វើនៅ បន្ទាយមានជ័យ, ថ្ងៃទី ខែ ...ឆ្នាំ ...

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី១១

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ
លេខ: ៤២៦...... អ.ស.ជ

# ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់[1]

**យើង** **ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។**

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៦០៦ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូង រាជធានីភ្នំពេញ ។

-បានឃើញ របាយការណ៍លេខ៖ ១១២ វ.ប.ក ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃ ក្រសួងមហាផ្ទៃ ។

- បានឃើញ មាត្រា៤៦ មាត្រា៤៥ មាត្រា២៩១ មាត្រា២៩៥ និង មាត្រា៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ឃើញថា[2]: ឈ្មោះ និងឈ្មោះ ជាប្តីប្រពន្ធនឹងគ្នា បានស្នាក់នៅក្នុងផ្ទះរបស់ឈ្មោះ ភេទប្រុស អាយុ ៨៦ឆ្នាំ ស្ថិតនៅក្នុងភូមិអូរគោល ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប ហើយនៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឈ្មោះ និងឈ្មោះ បានឈ្លោះប្រកែកគ្នាតាមរយៈទូរស័ព្ទ ហើយស្រាប់តែនៅថ្ងៃ.ខែ.ឆ្នាំ ដដែលវេលាម៉ោងប្រហែល ០១ និង ១០ នាទី រំលងអាធ្រាត្រ ឈ្មោះ និងឈ្មោះ បានឈ្លោះគ្នាប្រតាយប្រតប់គ្នាទៅវិញទៅមកពិតមែន បណ្តាលឱ្យភាគីទាំងសងខាងរងរបួសស្រាលរៀងៗខ្លួន ។

<u>បានឃើញ</u>[3]

-បានឃើញរបាយការណ៍សំយោគលេខ៖ ១១២ វ.ប.ក ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃ ក្រសួងមហាផ្ទៃ ។

ពាក្យបណ្តឹង ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០២០ និងកំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ ភេទស្រី អាយុ៦៣ឆ្នាំ ថា៖ ខ្លួនសូមចូលឆ្លើយបំភ្លឺជូនលោកតំណាងអយ្យការនៅថ្ងៃនេះ ខ្លួនសូមរក្សាពាក្យបណ្តឹង ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៥ និងកំណត់ហេតុបណ្តឹង ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០១៥ ទុកនៅដដែលពុំកែប្រែទេ ប្តឹងពីឈ្មោះ ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ។

ខ្លួនសូមបញ្ជាក់ថាខ្លួនបានរៀបការជាមួយនឹងឈ្មោះ តាំងពីឆ្នាំ ២០០២ មក ពុំមានកូនជាមួយគ្នាទេ ពុំមានបញ្ហាអ្វីធំដុំជាមួយគ្នាទេ មានតិចតួចៗ តែប៉ុណ្ណោះ រហូតមកដល់យប់ថ្ងៃទី២៦ ខែ មេសា ឆ្នាំ

[1] ដីកានេះ [illegible] ព្រះរាជអាជ្ញា ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ចំពោះបទល្មើសជាក់ស្តែង ឬមិនជាក់ស្តែង ដែលមានទណ្ឌកម្ម[illegible] [illegible] ហើយដែលមានភស្តុតាង និងមាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ។
[2] [illegible] ព្រហ្មទណ្ឌ [illegible] សំណុំរឿង ក្រោយពីបញ្ចប់ការស៊ើបអង្កេត ។
[3] [illegible] ទៅបញ្ជាញខ្លួននៅមុខតុលាការ [illegible] (មាត្រា ៤៥៧)
[illegible] សំរាប់ធ្វើជាមូលដ្ឋាន ក្នុងការយល់ឃើញរបស់ខ្លួន ដើម្បីសម្រេចឱ្យបានត្រឹមត្រូវតាមច្បាប់ ។

២០១៩ វេលាម៉ោងប្រហែល ១១ យប់ នៅផ្ទះសុំគេស្នាក់នៅ២ ទៅ ៣ យប់ ភូមិ.ឃុំ.ស្រុក មិនចាំ ខេត្តសៀមរាប ពុំស្គាល់ម្ចាស់ផ្ទះទេ ខ្លួនបានកាន់កន្ត្រៃហើយក៏បានដួលប៉ះជើងបណ្តាលឱ្យកន្ត្រៃខ្ទាតទៅបាត់ ស្រាប់តែឈ្មោះ ងើបឡើងស្ទុះមកវាយខ្លួនពីរដៃចំក្បាល និងចាក់ទ្រូងខ្លួនសាប់យកៗតែម្តង ហើយបណ្តាលឱ្យខ្លួនដួលទៅនឹងគំនរអុសបណ្តាលឱ្យខ្លួនសន្លប់បាត់ស្មារតី ហើយពេលខ្លួនដឹងខ្លួនឡើងក៏វាឡើងទៅលើផ្ទះ ហើយខ្លួនឱ្យឈ្មោះ : ដឹកខ្លួនមកពេទ្យ តែគាត់ពុំព្រមដឹកខ្លួនទៅពេទ្យទេ ពីព្រោះខ្លួនចុកដើមទ្រូងខ្លាំង បែរជាឈ្មោះ ជេរខ្លួនយកៗ ហើយខ្លួនបានពុំតបតអ្វីទេ ហើយឈ្មោះ ថែមទាំងរកវាយខ្លួនថែមទៀត បន្ទាប់មកឈ្មោះ កំបានរត់គេចខ្លួនបាត់តែម្តង ។

បន្ទាប់មកកូនប្រុសរបស់ខ្លួនបានមកយកខ្លួននៅទីរួមខេត្តសៀមរាបទៅព្យាបាលមន្ទីរខេត្តសៀមរាប ដេកសំរាកព្យាបាលប្រហែល ១ ម៉ោង ទើបដឹកតាមរថយន្តមកព្យាបាលនៅមន្ទីរពេទ្យ ១៧៩ ដេកសំរាក ប្រហែល ១០ ថ្ងៃ សំរាប់ឯកសារពេទ្យ និងការព្យាបាលចំណាយអស់ប៉ុន្មានខ្លួនចាំទេ ភ្លេចហើយ ។

ចាប់តាំងពីពេលមានរឿងកើតហេតុនៅថ្ងៃនោះ ខ្លួន និងឈ្មោះ ពុំដែលមានបញ្ហាអ្វីជាមួយគ្នាទៀតទេ ហើយក៏បែកលំនៅសង្វាស់គ្នាចាប់តាំងពីពេលនោះមកហូតដល់សព្វថ្ងៃនេះ ។

ខ្លួនសូមសំណូមពរ លោកតំណាងអយ្យការ មេត្តាជួយផ្តន្ទាទោសជនល្មើសតាមច្បាប់ និងទាមទារសំណងជំងឺចិត្តចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក និងថ្លៃព្យាបាលជំងឺចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ។

- កំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ ភេទប្រុស អាយុ៥៧ឆ្នាំ ថា៖ ខ្លួនអាចឆ្លើយបំភ្លឺចំពោះមុខលោកតំណាងអយ្យការបាន ដោយមានកញ្ញា ជាមេធាវីការពារក្តីខ្លួន ចូលរួមស្តាប់ចម្លើយជាមួយខ្លួន ។

ខ្លួនសូមចូលឆ្លើយបំភ្លឺជូនតំណាងអយ្យការនៅថ្ងៃនេះ ពីព្រោះនៅថ្ងៃដែលតុលាការកោះហៅខ្លួន ខ្លួនមានជាប់ធុរៈពុំអាចចូលមកឆ្លើយបំភ្លឺទើបខ្លួន សូមចូលឆ្លើយបំភ្លឺជូនលោកតំណាងអយ្យការនៅថ្ងៃនេះ ។

ខ្លួនសូមបដិសេធចំពោះពាក្យបណ្តឹងចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៩ របស់ឈ្មោះ ដែលប្តឹងចោទប្រកាន់ខ្លួនថា បានប្រព្រឹត្តអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស កាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ វេលាម៉ោងប្រហែល ០១ និង ១០ នាទី រំលងអាធ្រាត្រ នោះខ្លួនសូមបដិសេធចោទទាំងស្រុង ពីព្រោះខ្លួនពុំបានប្រព្រឹត្តអំពើហិង្សាទៅលើគាត់ឡើយ ។

ខ្លួនសូមបញ្ជាក់ថា ខ្លួនសូមរៀបការជាមួយឈ្មោះ តែពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ក្នុងការរស់រួមជាប្តីប្រពន្ធគ្នាពុំមានកូនទេ ហើយពួកខ្លួនទាំងពីរនាក់ បានរស់នៅបែកលំនៅសង្វាសគ្នាចាប់តាំងពីថ្ងៃដែលមានរឿងនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៩ ដែលគាត់ប្តឹងចោទប្រកាន់ខ្លួនថាបានវាយទៅលើគាត់ នោះពុំពិតទេ គឺរឿងហេតុប្រពន្ធរបស់ខ្លួនឈ្មោះ គាត់រករឿងឈ្លោះជាមួយខ្លួនរហូតមក តែនៅថ្ងៃកើតនោះ គាត់មករករឿងឈ្លោះជាមួយនឹងខ្លួនខ្លាំងតែម្តង ហើយពេលនោះខ្លួនកំពុងតែដេកលើអង្រឹងវេលាម៉ោង ៩ ទៅ ១០ យប់ នៅផ្ទះជួល ភូមិគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប ស្រាប់តែឈ្មោះ គាត់យកកន្ទោរទឹកនោម មកវាយក្បាលខ្លួន ហើយគាត់បានមកស្ទុះច្របាច់កខ្លួន ហើយខ្លួនក៏បានរើសបំរាស់ចេញពីគាត់ គាត់ក៏បានមកប្រតាយប្រតប់ជាមួយនឹងខ្លួន ហើយខ្លួនក៏ចាប់ដៃគាត់កុំឱ្យគាត់វាយខ្លួនតទៀត ហើយក៏ប្រតាយប្រតប់គ្នាទៅវិញទៅមក ទើបបណ្តាលឱ្យគាត់ដួលទៅលើអុស ស្រាប់ពេលនោះម្ចាស់ផ្ទះមកទាន់ក៏ចាប់បំបែកគ្នា ហើយក៏ឈ្លោះជជែកគ្នាប្រហែលជិត ១ ម៉ោងទៀត ហើយក៏បែកឈប់ឈ្លោះគ្នា ពេលនោះខ្លួនពុំបានគេចទៅណាទេ ។ លុះព្រឹកឡើងទើបប្រពន្ធរបស់ខ្លួនទៅក្រុងសៀមរាប ពេលនោះខ្លួនបានឱ្យប្រាក់គាត់ចំនួន ៥ ម៉ឺនរៀល ដើម្បីធ្វើដំណើរ

ចាប់តាំងពីពេលនោះមក ខ្លួន និងឈ្មោះ ពុំដែលបានរួមរស់នៅជាមួយគ្នាទៀតទេ ធ្លាប់ជួបមុខគ្នាពេលមកតុលាការ និងតាមរយៈទូរស័ព្ទតែប៉ុណ្ណោះ ហើយគាត់ និងកូនដើមគាត់ នៅតែជេរប្រមាថខ្លួន តាម រយៈទូរស័ព្ទ និងតាមបណ្ដាញទំនាក់ទំនងសង្គម Facebook រហូតមក ។

រហូតមកដល់អំឡុងថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៩ ទើបខ្លួនសម្រេចចិត្តដាក់ពាក្យបណ្ដឹងសុំផ្ដាច់អនីតិសង្វាសពីឈ្មោះ សុំបែងចែកទ្រព្យរួម និង បំណុលរួម ជាពីរស្មើគ្នា តែរឿងសំណុំរឿងនេះ សាលាដំបូងរាជធានីភ្នំពេញកំពុងតែចាត់ការនៅឡើយ ។

ខ្លួនសូមបញ្ជាក់បន្ថែមទៀតថា ខ្លួនធ្លាប់ដាក់ពាក្យបណ្ដឹងពីឈ្មោះ មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ពីបទ៖ ប៉ុនប៉ងមនុស្សឃាត ពាក្យបណ្ដឹងចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០២០ តែតំណាងអយ្យការបានតម្កល់រឿងទុកឥតចាត់ការរួចហើយ តាមរយៈដីកាតម្កល់លេខ៖ ៩១៧ អ.យ.ជ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០ ហើយខ្លួនបានប្ដឹងឧទ្ធរណ៍នឹងដីកាសម្រេចនេះហើយសាលាឧទ្ធរណ៍កំពុងតែចាត់ការ ។

ខ្លួននឹងដាក់ភស្តុតាងបន្ថែមទៀត ព្រមទាំងសាក្សី ក្នុងរឿងនេះ មកតំណាងអយ្យការពិនិត្យនៅពេលក្រោយទៀត ហើយខ្លួនបានដាក់សេចក្ដីឆ្លើយបំភ្លឺ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០២០ ជូនតំណាងអយ្យការពិនិត្យរួចហើយពីរឿងហេតុទាំងមូល ។

ខ្លួនសូមសំណូមពរលោកតំណាងអយ្យការមេត្តាជួយយុត្តិធម៌ឱ្យខ្លួនផង ពីព្រោះខ្លួនពុំបានប្រព្រឹត្តអំពើដូចឈ្មោះ ចោទប្រកាន់ឡើយ សូមលោកតំណាងអយ្យការមេត្តាតម្កល់រឿងទុកឥតចាត់ ។

-កំណត់ហេតុស្ដាប់ចម្លើយរបស់ឈ្មោះ ភេទប្រុស អាយុ ៥៦ឆ្នាំ ថា៖ កាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឈ្មោះ ភេទស្រី អាយុ ៦៥ឆ្នាំ ប្ដីគាត់ឈ្មោះ (ត្រូវជាម្ដាយឪពុកធម៌របស់ខ្លួន) បានទៅលេងខេត្តសៀមរាបហើយស្នាក់នៅផ្ទះរបស់ខ្លួននៅភូមិអូរគោល ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប បានពិភាក្សាគ្នាចូលផ្ទះខ្លួនដើម្បីបើកគ្លីនិក និងបានធ្វើកិច្ចព្រមព្រៀងផងដែរ ។ នៅវេលាម៉ោង ១២ ថ្ងៃត្រង់ ខ្លួនបានឃើញឈ្មោះ ឈ្លោះគ្នាជាមួយនឹងឈ្មោះ តាមទូរស័ព្ទ ។ លុះដល់ម៉ោងប្រហែល ៩ ជាង ពេលយប់ ខ្លួនបានឃើញឈ្មោះ កាន់កន្ត្រាទឹកនោម ដើរចេញពីក្នុងផ្ទះដើរសំដៅទៅរកប្ដីគាត់ដែលកំពុងដេកលើអង្រឹងនៅក្នុងរោងមុខផ្ទះ បន្ទាប់មកខ្លួនក៏ឃើញឈ្មោះ យកកន្ត្រាវាយក្បាលរបស់ឈ្មោះ ដោយវាយយកៗ ពេលនោះខ្លួនក៏ចូលទៅឃាត់ តែឈ្មោះ មិនព្រមស្ដាប់ នៅតែវាយក្បាលប្ដីគាត់បន្ត ហើយឈ្មោះ ។ បានចាប់កដៃឈ្មោះ ជាប់ ហើយឈ្មោះ បានប្រាប់ប្ដីគាត់បណ្ដាលឱ្យគាត់ដួលលើគំនរអុសខ្លួនឯង ខ្លួនក៏បានដឹកដៃគាត់ចូលផ្ទះកុំឱ្យឈ្លោះគ្នាទៀត ។ ពេលចូលក្នុងផ្ទះហើយឈ្មោះ បានចេញមកក្រៅម្ដងទៀត និងបានស្រែកជេរបញ្ចោរឈ្មោះ ថែមទៀត ខ្លួនឃើញបែបនោះក៏បានទៅលួងគាត់ឱ្យឈប់ឈ្លោះគ្នាហើយចូលទៅសម្រាកក្នុងផ្ទះវិញ ចំណែកប្ដីគាត់ឈ្មោះ បានទៅសម្រាកនៅបន្ទប់ផ្សេង ។ លុះព្រឹកឡើងគាត់បានជេរប្ដីគាត់ទៀត ខ្លួនឃើញដូច្នេះ ក៏បានឱ្យឪពុកម្ដាយខ្លួនជូនឈ្មោះ ទៅផ្ទះបងបង្កើតរបស់ខ្លួននៅ ខេត្ត ដើម្បីចាំកូនប្រុសរបស់គាត់មកយកគាត់ទៅភ្នំពេញវិញ ។

-ពិនិត្យភស្តុតាង និង ឯកសារផ្សេង ... ។

## យល់ឃើញថា[4]:

-តាមពាក្យបណ្តឹងចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០២០ និងកំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ          ភេទស្រី អាយុ ៦៣ឆ្នាំ ,របាយការណ៍សំយោគលេខ៖ ១១២ រ.ប.ក ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃក្រសួងមហាផ្ទៃ , កំណត់ហេតុចម្លើយរបស់ឈ្មោះ.          ភេទប្រុស អាយុ ៤៧ឆ្នាំ និងកំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ          ភេទប្រុស អាយុ៤៦ឆ្នាំ ខាងលើ និងពិនិត្យភស្តុតាងមានភាពសង្ខាក់គ្នាថាឈ្មោះ ।          ភេទស្រី អាយុ ៦៣ឆ្នាំ និងឈ្មោះ ।          ភេទប្រុស អាយុ៤៧ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ ហិង្សាដោយចេតនាទៅវិញទៅមកពិតមែន កាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០២០នៅ ខេត្តសៀមរាប ។

-មានភស្តុតាងគ្រប់គ្រាន់ ដើម្បីដាក់បន្ទុកលើជនជាប់ចោទ ឈ្មោះ          ភេទស្រី អាយុ៦៣ឆ្នាំ និងឈ្មោះ          ភេទប្រុស អាយុ៤៧ឆ្នាំ ពីបទៈហិង្សាស្រាលទៅវិញទៅមក កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០នៅ ខេត្តសៀមរាប បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២២៨ នៃ ក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច[5]

១-ចោទប្រកាន់ ៖

ក.ឈ្មោះ          ភេទស្រី អាយុ ៦៤ឆ្នាំ (ក្រៅឃុំ) ទីលំនៅបច្ចុប្បន្នផ្ទះលេខ២៦ ផ្លូវលេខ៤៧៨ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ខ.ឈ្មោះ          ភេទប្រុស អាយុ៤៧ឆ្នាំ (ក្រៅឃុំ) ទីលំនៅបច្ចុប្បន្នលេខ២៦ ផ្លូវលេខ៤៧៨ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ពីបទៈ ហិង្សាស្រាលទៅវិញទៅមក ប្រព្រឹត្តនៅកាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០២០នៅ ខេត្តសៀមរាប បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៨ នៃ ក្រមព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជា ។

ខ-បញ្ជូនជនជាប់ចោទ ដូចមានឈ្មោះខាងលើនិងសំណុំរឿងព្រហ្មទណ្ឌលេខៈ ៨៦០៦ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០២០ និងវត្ថុតាង ដែលទាក់ទិនក្នុងសំណុំរឿង នេះទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីជំនុំជម្រះតាមច្បាប់ ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២០

**តំណាងអយ្យការ**

[4] សន្និដ្ឋានតាមជំនឿ គឺអំពើរបស់ជនត្រូវចោទ ទៅលើធាតុផ្សំនៃបទល្មើស សំរបបញ្ជាក់ថា មានឬគ្មានភស្តុតាងគ្រប់គ្រាន់ ឬស្លាប់ ឬគេចខ្លួនបាត់ មានឬគ្មានភស្តុតាងគ្រប់គ្រាន់ ។

[5] ផ្នែកនេះសំអាងហេតុ និងការយល់ឃើញរបស់ខ្លួន តំណាងអយ្យការត្រូវសំអាងឱ្យបានច្បាស់លាស់ អំពីការចោទប្រកាន់ ការបង្កបណ្ដឹងអាជ្ញា និងការលើកបណ្ដឹងអាជ្ញា ដោយលើក យកមាត្រាច្បាប់មកសំអាងឱ្យបានត្រឹមត្រូវ ។

**ឧបសម្ព័ន្ធទី១២**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តបន្ទាយមានជ័យ**

លេខ:.............................................

**********

**<u>ដីកាសម្រេចឱ្យយកជនជាប់ចោទមកជំនុំជំរះ</u>**

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី ...ខែ ... ឆ្នាំ ២០១២ ដែលមានជនជាប់ចោទ:

១-ឈ្មោះ ... ភេទ ប្រុស អាយុ ... ឆ្នាំ (ក្នុងឃុំ)
២-ឈ្មោះ ... ភេទ ប្រុស អាយុ ... ឆ្នាំ (ក្នុងឃុំ)
៣-ឈ្មោះ ... ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

ជាប់ចោទពីបទ**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិគីឡូម៉ែត្រលេខ...សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី... ខែ... ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤៥** និងមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២។

**<u>ហេតុដូច្នេះសម្រេច</u>**

**<u>ឱ្យជនជាប់ចោទ</u>**

១-ឈ្មោះ .... ភេទប្រុស អាយុ ... ឆ្នាំ

២-ឈ្មោះ .... ភេទប្រុស អាយុ ... ឆ្នាំ

ទៅកាន់សាលាដំបូងខេត្តបន្ទាយមានជ័យ ទីកន្លែងជំនុំជម្រះសាលាដំបូងខេត្ត **នៅថ្ងៃទី... ខែ... ឆ្នាំ២០១២ វេលាម៉ោង ៨. ០០ នាទី ព្រឹក** ដើម្បីជំនុំជម្រះពីបទដែលបានចែងដូចខាងលើ ។

**<u>ចៅក្រមជំនុំជំរះ</u>**

- លោក ... ចៅក្រមសាលាដំបូងខេត្ត

**<u>តំណាងអយ្យការ</u>**

- លោក ... ព្រះរាជអាជ្ញារង

**<u>ក្រឡាបញ្ជីសវនាការ</u>**

- លោក .... ក្រឡាបញ្ជី

ឱ្យដំណឹងដល់ជនជាប់ចោទស្តីពីសិទ្ធិរបស់ខ្លួន
នៅចំពោះមុខតុលាការដូចតទៅ:

- សិទ្ធិពីការដឹងឮពីដីកាសន្និដ្ឋានស្ថាពរ និងដីកាកោះឱ្យចូលរួមសវនាការ
- សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី ឬសំណូមពរផ្សេងៗ
- សិទ្ធិប្តឹងជំទាស់ចិត្តចៅក្រមជំនុំជម្រះ

- សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងពាក់មេធាវីជួយការពារ

បន្ទាយមានជ័យ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០១២

**ព្រះរាជអាជ្ញារង**

**ឧបសម្ព័ន្ធទី១៣**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ៥២០៦
ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០

# កំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

លេខ: 0៤3...... អ.ព.ប

ឆ្នាំពីរពាន់ម្ភៃ ខែមិថុនា ថ្ងៃទីដប់មួយ វេលាម៉ោងដប់ប្រាំ និងសាមសិបនាទីរសៀល

យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-របាយការណ៍លេខ ២០៤/២០ ព្រ.ទ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ ។

បុគ្គលដែលនៅចំពោះមុខយើង បានផ្ដល់ព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម៖

១. នាមត្រកូល-នាមខ្លួន ហៅម៉ាប់ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ៣៤៣E, ភូមិ០៩ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ មុខរបរកម្មករសំណង់ នៅលីវ ឪពុកឈ្មោះ រស់ ម្ដាយឈ្មោះ រស់ ជាទីតិជន ទោសពីមុនគ្មាន ។ (ឃាត់ខ្លួននៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០)

២. នាមត្រកូល-នាមខ្លួន ហៅ ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតសង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះលេខ៤៤០E, ផ្លូវលេខ២១៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ មុខរបរសន្តិសុខ នៅលីវ ឪពុកឈ្មោះ ស្លាប់ ម្ដាយឈ្មោះ រស់ កម្រិតវប្បធម៌ថ្នាក់ទី០៨ ជាទីតិជន ទោសពីមុនគ្មាន ។ (ឃាត់ខ្លួននៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០)

យើងប្រាប់ដល់បុគ្គលនេះនូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ: កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១២ និង១០នាទី កម្លាំងរបស់ការិយាល័យប្រឆាំងគ្រឿងញៀន បានចុះល្បាតក្នុងមូលដ្ឋាន ដើម្បីការពារ ទប់ស្កាត់ករណីពាក់ព័ន្ធគ្រឿងញៀនផ្សេងៗ លុះល្បាតដល់ចំណុចលើផ្លូវលេខ១៣២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ក៏ប្រទះឃើញជនសង្ស័យឈ្មោះ ហៅ ភេទប្រុស និងឈ្មោះ ហៅ ភេទប្រុស កំពុងដើរនៅតាមផ្លូវ សមត្ថកិច្ចមានការសង្ស័យ ក៏ហៅឱ្យឈប់ធ្វើការត្រួតពិនិត្យ រកឃើញមានថ្នាំញៀនចំនួនមួយកញ្ចប់តូចទម្ងន់ ០.២៩ក្រាម ដែលជនសង្ស័យឈ្មោះ ហៅ លាក់ទុកក្នុងហោប៉ៅខោមុខខាងស្ដាំ សមត្ថកិច្ចដកហូតថ្នាំញៀនទាំងនោះ និងបញ្ជូនជនសង្ស័យមកកាន់ការិយាល័យប្រឆាំងគ្រឿងញៀន ។ ក្រុមមន្ត្រីជំនាញបច្ចេកទេសនៃការិយាល័យ បានធ្វើតេស្តជំហានដំបូងលើវត្ថុតាងខាងលើ ចំពោះមុខជនសង្ស័យជាមួយតេស្តប្រភេទ ជាលទ្ធផលបង្ហាញថាក្រោមពណ៌សថ្លាចេញពណ៌លឿងទុំសង្ស័យមានតម្រុយជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ហើយជនសង្ស័យទាំងពីរនាក់បានឆ្លើយសារភាពថា "នៅថ្ងៃកើតហេតុពួកខ្លួនបានចូលលុយគ្នាម្នាក់ ១០.០០០រៀល ទិញថ្នាំញៀនចំនួន ០១កញ្ចប់ចង់តូចនៅម្ដុំផ្លូវបេតុង ហើយយកមកប្រើប្រាស់នៅម្ដុំជិតវត្តនាគវន្ត ស្រាប់តែជួបសមត្ថកិច្ចចុះមកបង្ក្រាបឃាត់ពួកខ្លួនតែម្ដង ។

អង្គហេតុនេះជាបទល្មើស៖ ស្តុកទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចលើ ផ្ទះលេខ១៣២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

យើងបានទទួលចម្លើយពីជននេះដូចតទៅ:

១ ឈ្មោះ ហៅ ភេទប្រុស អាយុ ៣១ឆ្នាំ បានឆ្លើយទៅជំណាក់កាលសមត្ថកិច្ច និងតំណាងអយ្យការដូចតទៅ៖ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១២ និង១០នាទី ខ្ញុំបាន ចូលលុយគ្នាជាមួយឈ្មោះ ហៅ ម្នាក់ ១០,០០០៛ រួចនាំគ្នាដើរទៅទិញថ្នាំញៀននៅ មុំផ្ទះចេភ្លើងបានចំនួន ០១កញ្ចប់ថង់តូច តម្លៃ ២០,០០០៛ ហើយបំរុងយកថ្នាំញៀនដែលទិញបាននោះ ប្រើប្រាស់នៅមុំដីឡូត៍វត្តនាគវន្ត ក៏ជួបកម្លាំងសមត្ថកិច្ចហៅខ្ញុំឆែកឆេរកឃើញថ្នាំញៀននៅក្នុងហោប៉ៅមុខ ខាងស្តាំរបស់ខ្ញុំ រួចសមត្ថកិច្ចឃាត់ខ្លួនខ្ញុំទាំងពីរនាក់តែម្តង ។

២ ឈ្មោះ ហៅ ភេទប្រុស អាយុ ៣៤ឆ្នាំ បានឆ្លើយទៅជំណាក់កាលសមត្ថកិច្ច និងតំណាងអយ្យការដូចតទៅ៖ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១២ និង១០នាទី ខ្ញុំបាន ចូលលុយគ្នាជាមួយឈ្មោះ ហៅ ម្នាក់ ១០,០០០៛ រួចនាំគ្នាដើរទៅទិញថ្នាំញៀននៅមុំ ផ្ទះចេភ្លើង បានចំនួន ០១កញ្ចប់ថង់តូច តម្លៃ ២០,០០០៛ ហើយបំរុងយកថ្នាំញៀនដែលទិញបាននោះ ប្រើប្រាស់នៅមុំដីឡូត៍វត្តនាគវន្ត ក៏ជួបកម្លាំងសមត្ថកិច្ចហៅខ្ញុំឆែកឆេរកឃើញថ្នាំញៀននៅក្នុងហោប៉ៅ មុខខាងស្តាំរបស់ឈ្មោះ ហៅ រួចសមត្ថកិច្ចឃាត់ខ្លួនខ្ញុំទាំងពីរនាក់តែម្តង ។

យើងបានប្រាប់ដល់ជននេះថា៖ ខ្លួនមានសិទ្ធិសុំពឹងមេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬ ស្នើសុំ ឱ្យមានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់ ។

ជនទាំងពីរនេះបានឆ្លើយថា: ពួកខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ ពួកខ្ញុំអាចការពារដោយ ខ្លួនឯងបាន ។

បានឃើញមាត្រា ៤៧ មាត្រា ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

<u>**ហេតុដូច្នេះសម្រេច:**</u>

បញ្ជូនជនជាប់ចោទ៖

ក ឈ្មោះ ឈ្មោះ ហៅ ភេទប្រុស អាយុ ៣១ឆ្នាំ (ឃាត់ខ្លួន)

ខ ឈ្មោះ ហៅ ភេទប្រុស អាយុ ៣៤ឆ្នាំ (ឃាត់ខ្លួន)

មកតុលាការដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការជំនុំជម្រះ តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះ អង្គហេតុ និងបទល្មើស ដូចខាងលើ។

ក្រោយពីបានអានឱ្យ ជនជាប់ចោទស្តាប់ ជននេះយល់ព្រមផ្តិតមេដៃជាមួយយើង។

ជនជាប់ចោទ

ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា

**ឧបសម្ព័ន្ធទី១៤**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តពោធិ៍សាត់**
**សំណុំរឿងព្រហ្មទណ្ឌលេខ: ...**
**ចុះថ្ងៃទី...ខែ... ឆ្នាំ..**
**លេខ:......................អ.យ/០១៦**

## ដីកាសន្និដ្ឋានស្ថាពរ

**យើង............ តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ។**

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់តំណាងអយ្យការអមសាលាដំបូងពោធិ៍សាត់ ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ:... ចុះថ្ងៃទី ... ខែ... ឆ្នាំ... របស់សាលាដំបូងខេត្តពោធិ៍សាត់ ។

បានឃើញ ដីកាបញ្ជូនឲ្យឆ្លើយដើម្បីបិទបញ្ចប់ការស៊ើបសួរលេខ: ... ពស ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តពោធិ៍សាត់ ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា:**

១-នាមត្រកូល៖...នាមខ្លួន ... ហៅ... ភេទ... កើតនៅឆ្នាំ ...
-សញ្ជាតិ៖... សាសនា ៖ មុខរបរ៖... ទោសពីមុនគ្មាន
-ទីកន្លែងកំណើត៖ ភូមិ... ខេត្តពោធិ៍សាត់
-ទីលំនៅបច្ចុប្បន្ន៖ ភូមិ...ខេត្តពោធិ៍សាត់
-ឪពុកឈ្មោះ ... (រ) ម្តាយឈ្មោះ ... (រ) នៅរស់ ជានីតិជន។
២-នាមត្រកូល៖... នាមខ្លួន ... ភេទប្រុស កើតនៅឆ្នាំ ...
-សញ្ជាតិ៖... សាសនាព្រះពុទ្ធ ៖ មុខរបរ៖ធ្វើស្រែ ទោសពីមុនគ្មាន
-ទីកន្លែងកំណើត៖ ភូមិ...ខេត្តពោធិ៍សាត់
-ទីលំនៅបច្ចុប្បន្ន៖ ភូមិ...ខេត្តពោធិ៍សាត់
-ឪពុកឈ្មោះ ... (រ) ម្តាយឈ្មោះ ... (រ) នៅរស់ ជានីតិជន។
៣-នាមត្រកូល៖... នាមខ្លួន ... ភេទប្រុស កើតនៅឆ្នាំ ...
-សញ្ជាតិ៖ សាសនា៖

-ទីកន្លែងកំណើត៖ ភូមិ...ខេត្តពោធិ៍សាត់

-ទីលំនៅបច្ចុប្បន្ន៖ ភូមិ...ខេត្តពោធិ៍សាត់

-ឪពុកឈ្មោះ៖ ... (រ) ម្តាយឈ្មោះ៖... (ស) ប្រពន្ធឈ្មោះ ... (រ)

កាលពីថ្ងៃទី...ខែ...ឆ្នាំ...វេលាម៉ោង...នាទីរសៀល មានអំពើ...របស់ជនរងគ្រោះឈ្មោះ...ដែលបានចងទុកនៅក្រោមផ្ទះនៅភូមិ...ខេត្តពោធិ៍សាត់។ ដល់ថ្ងៃខែឆ្នាំដដែលវេលាម៉ោងប្រហែល...និង...នាទី ឈ្មោះ...ហៅ... និងឈ្មោះ...បានហៅឈ្មោះ ...ឲ្យយកឡានមកដឹកក្របី ពេលកំពុងរៀបចំយកក្របីនោះដាក់ឡាន ពេលនោះឈ្មោះ...បានឃើញក៏រាយការណ៍ប្រាប់សមត្ថកិច្ច រួចសមត្ថកិច្ចក៏ចុះដេញតាមឡានដឹកក្របីដល់ភូមិ ...ខេត្តពោធិ៍សាត់ បានតាមទាន់ហើយ ក៏ឃាត់ខ្លួនឈ្មោះ ...ហៅ... និងឈ្មោះ... ជាអ្នកបើកឡានដឹកក្របី។

បានឃើញ ឈ្មោះ ...ត្រូវបានឃុំខ្លួនបណ្តោះអាសន្នតាមដីកាលេខ: ...ចុះថ្ងៃទី...ខែ... ឆ្នាំ...របស់ចៅក្រមស៊ើបសួរ។ (ឯកសារលេខ: ...)

បានឃើញ ឈ្មោះ ...ត្រូវបានឃុំខ្លួនបណ្តោះអាសន្នតាមដីកាលេខ: ... ចុះថ្ងៃទី...ខែ...ឆ្នាំ... របស់ចៅក្រមស៊ើបសួរ។ (ឯកសារលេខ:...)

បានឃើញ កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ... ថាខ្លួនមិនបានកត់កំណត់ហេតុថា ក្របីខ្លួនបានពេលណា រកឃើញពេលណាទេ គ្រាន់តែនគរបាល ហៅឲ្យយកក្របី។ ក្របីនោះខ្លួនទាក់បង្គន់ក្របី(ក្រោល) ព្រឹកឡើងលែងចោលដោយដើរមើល។ ក្របីខ្លួនមានចំនួន ០៤ក្បាល ពេលព្រឹកឡើងឃើញបាត់មួយនៅសល់០៣ក្បាល។ ការបាត់នោះដោយដឹកខ្សែដើរចេញតែមួយ។ក្របីនោះរកឃើញវិញហើយខ្លួនមិនទាមទារសំណងទេ សុំធ្វើតាមច្បាប់។ ខ្លួនមិនថាអ្នកណាចូលលួចទេ ហើយក៏គ្មានសង្ស័យអ្នកណាទេ ពេលដែលសមត្ថកិច្ចចាប់បានក្របី និងមនុស្ស គឺមនុស្សនោះដែលមិនមែនជាអ្នកភូមិខ្លួនទេ ដែលអ្នកនោះមិនស្គាល់ខ្លួន ហើយខ្លួនមិនស្គាល់គាត់ ដែលមើលទៅមិនមែនជាអ្នកលួចដឹកពីផ្ទះខ្លួនទេ ព្រោះគេមិនដែលឃើញ និងស្គាល់ផ្ទះខ្លួនទេ។ តាមខ្លួនគិតគឺមានអ្នកជិតភូមិខ្លួនជាអ្នកដឹកដើរចេញពីក្រោយរបស់ខ្លួន ចំណែកអ្នកដែលសមត្ថកិច្ចចាប់ខ្លួននេះមិនដឹងថាទំនាក់ទំនងជាមួយអ្នកនៅជិតៗខ្លួនយ៉ាងណាទេ។ សំណូមពរសុំផ្តន្ទាទោសតាមច្បាប់។

បានឃើញ កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់សាក្សី ឈ្មោះ...ខ្លួនធ្លាប់ស្គាល់ឈ្មោះ... រយៈពេល...ឆ្នាំហើយ។ តាំងពីស្គាល់គាត់ ឃើញគាត់ប្រកបមុខរបរជាអ្នកទិញ

គោក្របី។ កន្លងមកឈ្មោះ......ធ្លាប់ទិញក្របីយកមកផ្ញើនៅផ្ទះខ្លួនម្តង ហើយក្របីនោះបាន រួចពីចំណង ហើយដេញចាប់ភ្លាមៗ មិនមានបាត់ទេ ក៏ឡើងឡានបាត់ទៅ។ក្រោយមក ប្រហែល២អាទិត្យវេលាម៉ោង ប្រហែល ១០ ទៅ ១១ ថ្ងៃត្រង់ ឈ្មោះ...បានចូលលេងផ្ទះខ្លួន ហើយក៏បាននិយាយថាឈ្មោះ... នៅ...បានហៅឲ្យទៅទិញក្របី ដោយឈ្មោះ... នៅ... គាត់ទិញបានក្របីមួយ ហើយហៅឈ្មោះ...ទៅមើល និងទិញបន្ត។ ពេលនោះឈ្មោះ... ទៅបាត់មួយ ប្រហែលម៉ោង ... រសៀលក៏ឈ្មោះ...ទូរស័ព្ទប្រាប់ថានគរបាលបានចាប់។ខ្លួន ធ្លាប់ស្គាល់ឈ្មោះ...នៅ...នោះដែរ ធ្លាប់ទៅលេងកន្លែងខ្ទមស្រែរបស់ឈ្មោះ... នៅកន្លែង ស្រែតែមិនស្គាល់នោះទេ។ ឈ្មោះ... នោះខ្លួនធ្លាប់ជួបមុខចំនួន២ ដងហើយ ស្គាល់មុខ ច្បាស់។ កន្លងមកឈ្មោះ...ជាអ្នកទិញពីណាពីណីមកហើយទើបលក់ឲ្យឈ្មោះ...។កាលពី ថ្ងៃដែលគេចាប់ខ្លួននោះ គឺឈ្មោះ...បានប្រាប់ខ្លួនថា មានលុយចំនួន ៨.០០០.០០០ (ប្រាំលានរៀល) ហើយដើររកក្របី នៅភូមិខ្លួនផង និងកន្លែងផ្សេងៗ។ពេលនគរបាលចាប់ នោះខ្លួនទៅមើលឈ្មោះ...បានប្រាប់ថាលុយបានឲ្យទៅឈ្មោះ ... នៅ...អស់ហើយ។ កន្លង មកការរាប់អានគ្នា ខ្លួនធ្លាប់បានដើរលេង ជាមួយឈ្មោះ...ពេលគេទិញក្របីដែរ ដោយ ឃើញមានលិខិតស្នាមត្រឹមត្រូវ តែចំពោះថ្ងៃដែលគេចាប់ខ្លួននេះមិនដឹងថាមានសំបុត្រអត់ នោះទេ។ ក្របីនោះខ្លួនជឿជាក់ថាឈ្មោះ... ទិញពីឈ្មោះ...នៅ...ចំពោះការចាប់ខ្លួន ឈ្មោះ...ខ្លួននិងសហការ។

បានឃើញ កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ ឈ្មោះ...ហៅ... ខ្លួនជាអ្នក ប្រកបមុខរបរលក់ទិញគោក្របីអស់ រយះពេល ៣-៤ ឆ្នាំហើយ។កាលពីថ្ងៃទី មិនចាំខែ ធ្នូ ឆ្នាំ២០១៥វេលាម៉ោង ១០ព្រឹក ឈ្មោះ... អ្នករកស៊ីទិញគោ ក្របី បានដឹកខ្ញុំដោយម៉ូតូគាត់ ដើម្បីទៅមើលក្របីនៅកំរ៉ែង។ ពេលនោះខ្លួនមិនបានសួរអំពីដំណើរទំនងអំពីក្របីនោះ ឡើយដោយខ្លួននិងឈ្មោះ...ធ្លាប់រកស៊ីជាមួយ ហើយកន្លងមកឈ្មោះ...ជាអ្នកផ្ញើ។ ខ្លួនបាន ព្រមព្រៀងជាមួយឈ្មោះ... ក្នុងតម្លៃ៣.០០០.០០០(បីលានរៀល)។ ខ្លួនមិនបានផ្ដិតមេដៃពី ឈ្មោះ... ឡើយ។ ឈ្មោះ... មានផ្ទះនៅផ្ដុំភូមិ...ខេត្តពោធិ៍សាត់ ដែលខ្លួនកូនប្រុសគាត់ម្នាក់ ឈ្មោះ...(កំលោះ)នៅម្តុំផ្លូវកោង ទូរស័ព្ទលេខ ០៩៧...។ពេលនោះនគរបាលបានចាប់ខ្លួន បានប្រាប់នគរបាលតាមដំណើររឿង ហើយនគរបាលបានយក ទូរស័ព្ទខ្លួនទៅទាក់ទង ឈ្មោះ... ហើយឈ្មោះ... បាននិយាយជាមួយនគរបាលថាគាត់ធានា ឲ្យខ្លួនទៅទៅតែ ដោយគ្មានសំបុត្រនគរបាលមិនឲ្យទៅទេ។ការទិញនេះឈ្មោះ... បានឲ្យសំបុត្រដែលទិញ

ក្របីពីគេនោះមកខ្លួនកាន់ដែរ តែពេលជិះតាមផ្លូវជ្រុះបាត់ ដោយខ្លួនដាក់ជាមួយទូរស័ព្ទក្នុងហោប៉ៅ។ ក្រោយពីបិទទូរស័ព្ទ ដែលទាក់ទងគ្នាម្តងរួចហើយ ទាក់ទងគ្នាលែងចូលរហូត។ ចំណែកអ្នកស៊ីឈ្នួលដឹកគាត់បានទារថ្លៃ១០.០០០០(ដបម៉ឺនរៀល) ហើយគាត់សួរខ្លួនថាមានសំបុត្រទេ ខ្លួនប្រាប់ថាមាន ព្រោះសំបុត្រនោះខ្លួនមានមែនខ្លួនទទួលពីឈ្មោះ... មកខ្លួនមិនបានមើលទេខ្លួនបានដាក់ជាមួយទូរស័ព្ទក្នុងហោប៉ៅ ហើយបាត់ទៅ។

បានឃើញ កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ ឈ្មោះ...ពេលនោះខ្លួនបានសួរអំពីដំណើរទំនងអំពីក្របីនោះ គាត់ថាមានច្បាប់ត្រឹមត្រូវអស់ហើយ។ក្រោយពីតថ្លៃដប់ម៉ឺនរៀល ខ្លួនក៏ចេញទៅ ពេលទៅដល់ឃើញគាត់ មានគ្នា២នាក់ ហើយបន្ទាប់ពីឡើងក្របីរួចខ្លួនក៏សួររកក្រដាសស្នាម គាត់ថាមាន ហើយគាត់ទាញឲ្យខ្លួនមើលដោយមិនចេះអក្សរ ឃើញគាត់ដកឯកសារមកជាច្រើនខ្លួនក៏ជឿទៅ ដោយមិនបានដឹងថាក្រដាសនោះ ពីថ្ងៃណានោះទេ។ ពេលដឹកប្រហែលបាន ៣ គីឡូម៉ែត ខ្លួនឃើញនគរបាលបានជិះម៉ូតូតាមក្រោយ ហើយស៊ីផ្លេខ្លួនឃើញតាមកញ្ចក់ខ្លួនក៏ឈប់ ហើយគាត់ទារមើលឯកសារ (គឺឈ្មោះ...កំពុងជិះម៉ូតូជាមួយខ្លួនក៏បានបង្ហាញឯកសារ) មិនដឹងថាឯកសារនោះយ៉ាងណាទេ ក៏គេឲ្យមកប៉ុស្តិ៍នគរបាលទាំងអស់គ្នា។ ពេលនគរបាលសួរខ្លួនឆ្លើយតាមដំណើររឿងដូចឆ្លើយនៅពេលនេះដែល ចំណែកចម្លើយឈ្មោះ... នោះយ៉ាងណាខ្លួនមិនដឹងទេ។ ខ្លួនមិនបានដឹងថាក្របីនោះ ខុសច្បាប់នោះទេ បើខ្លួនដឹងថាខុសច្បាប់ខ្លួនក៏មិនដឹកឡើយ ឈ្មោះ... អះអាងថាមានសំបុត្រ(ច្បាប់)។

យល់ឃើញថា

- មានភស្តុតាងគ្រប់គ្រាន់លើឈ្មោះ ...ភេទប្រុស អាយុ ...ឆ្នាំ និងឈ្មោះ...ភេទប្រុស អាយុ ...ឆ្នាំ ពីបទៈ អំពើលួច ប្រព្រឹត្តនៅភូមិ... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី... ...ខែ... ឆ្នាំ២...បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាម បញ្ញត្តិមាត្រា ៣៥៣,៣៥៦ នៃក្រមព្រហ្មទណ្ឌ។

-មិនមានភស្តុតាងគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ ...ភេទប្រុស អាយុ ...ឆ្នាំ

ពីបទះសមគំនិតក្នុងអំពើលួច តាមមាត្រា ២៩,៣៥៣,៣៥៦ នៃក្រមព្រហ្មទណ្ឌប្រព្រឹត្តនៅភូមិ... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ... ខែ... ឆ្នាំ២...

<u>ដូច្នេះសម្រេច</u>

I. ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចៈ

១.បញ្ជូនជនត្រូវចោទលើ ៖

ក-ឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំ

ខ-ឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំ

ពីបទ: អំពើលួច តាមមាត្រា៣៥៣,៣៥៦ ប្រព្រឹត្តនៅភូមិ... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី...ខែ... ឆ្នាំ២... ទៅ ជំនុំ ជម្រះ។

២.លើកលែងជនត្រូវចោទ៖

- ឈ្មោះ...ភេទប្រុស អាយុ ... ឆ្នាំ

ពីបទ៖ សមគំនិតក្នុងអំពើលួច តាមមាត្រា២៩,៣៥៣,៣៥៦នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ...ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ... ខែ... ឆ្នាំ២...។

ធ្វើនៅអយ្យការ, ថ្ងៃទី.........ខែ............ ឆ្នាំ២...

**តំណាងអយ្យការ**